ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ប្រធានាធិបតី រ៉ូឌ្រីហ្គោ ឌូធើតេ គួរតែសិក្សាអំពីគោលនយោបាយ
- ការផ្លាស់ប្ដូរទស្សន និងបរិស្ថាន នៅអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៣ ខែវិច្ឆិកា ឆ្នាំ២០១៦

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ២០៣ ខែវិច្ឆិកា ឆ្នាំ២០១៦

## មាតិកា

◆ ប្រធានាធិបតី រ៉ូឌ្រីហ្គោ ឌូធឺតេ គួរតែសិក្សាអំពីគោល ......................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ស្វាយ អាន សមាជិកមន្ទីរប-១ ..........................៤

◆ ពង្រឹង និងពង្រីក គ្រប់ថ្នាក់ គ្រប់មូលដ្ឋានឲ្យបាន..........................១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង ៖ តំបន់កាន់កាប់ចុងក្រោយ ..........១៦

◆ អតីតកាលនៅតែដក់ជាប់ក្នុងចិត្ត ................................................២១

◆ រម្លឹកពីអតីតកាល ជាការព្យាបាលរបួសផ្លូវចិត្ត...............................២២

◆ ជីវិតយាយ ម៉ក់ សោភ័ណ្ឌ ក្នុងរបបខ្មែរក្រហម ............................២៣

◆ ជំនឿសាសនា ត្រូវបានខ្មែរក្រហមលុបបំបាត់ ..............................២៤

◆ អន្លង់វែង ៖ ការប្រតិបត្តិសាសនាដើម្បីផ្សះផ្សាផ្លូវចិត្ត.....................២៥

◆ ជុំ វង់ ៖ ពីយោធាមកធ្វើគ្រូបង្រៀននៅអន្លង់វែង.........................២៧

◆ ជាង៤០ឆ្នាំ ទើបដឹងថាឪពុកស្លាប់នៅទួលស្លែង ..............................២៩

◆ ទើបតែទទួលសំបុត្របួន ............................................................៣១

**ផ្នែកច្បាប់**

◆ សាលដីកាស្ថាពរនៃសំណុំរឿង០០២ វគ្គ១ ..................................៣៣

◆ ដើមបណ្ដឹងរដ្ឋប្បវេណី ៖ ខ្មែរក្រហមលុបចោលទាំងស្រុងនូវ ..............៣៥

◆ អ្នកជំនាញបានផ្ដល់សក្ខីកម្ម ៖ គូស្វាមីដែលមិនត្រូវបានបង្ខំឲ្យ ..............៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ទស្សនៈប្រជាជនចំពោះការប្រកាសសាលដីកាស្ថាពរ ....................៥២

◆ ការផ្លាស់ប្ដូរបរិស្ថាន និងសង្គម នៅអន្លង់វែង ................................៥៤

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ គេរង់ចាំណែលដេះដង់ពីរបបខ្មែរក្រហម .......................................៥៧



ព្រះសង្ឃនៅវត្តស្វាយទន្ទឹមអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

### រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ចៅ ព្រហស្បតិ៍, គ្រីស្តូហ្វ័រ ឌៀរីង, ឌី ខាំបូលី, ហេង អៀ, អ៊ុន សុដាវី, អ៊ិន វណ្ណារ៉ា, ទាន ថង, សួន សុភ័ក្ត្រ, ចាន់ ឡាត, អាលីស មើហ្គើរ, សារ៉ា ហេមមើល និង សៀវ សុផុន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ និង ឆេង រ៉េង **អ្នកបកប្រែ ៖** ឈឹម អមរ័ត្ន និង អែម សីលា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** សន ល័ក្ខ

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ប្រធានាធិបតី រ៉ូឌ្រីហ្គោ ឌូធើតេ គួរតែសិក្សាអំពីគោលនយោបាយការបរទេសរបស់កម្ពុជា


## *សេចក្តីសង្ខេប*

*គោលនយោបាយការបរទេសអាចនឹងត្រូវបានកែតម្រូវ ដើម្បីឲ្យស្របទៅនឹងតម្រូវការនាពេលបច្ចុប្បន្ន ក៏ប៉ុន្តែ ជានិច្ចកាល គោលនយោបាយនេះ មានកំណើតចេញពីអតីតកាល ។ ខណៈដែល ប្រវត្តិសាស្ត្រជះឥទ្ធិពលយ៉ាងសំខាន់លើគោលនយោបាយការបរទេសនៃប្រទេសទាំងអស់ ប្រវត្តិសាស្ត្រធ្វើឲ្យមានស្រមោលអន្ធកាលដែលគ្របដណ្តប់លើប្រទេសដែលធ្លាប់ស្ថិតនៅក្រោមអាណានិគម ។ ខ្ញុំគោរពចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោកប្រធានាធិបតី ឌូធើតេ ក្នុងការ "ធ្វើឲ្យប្រសើរ" ចំពោះគោលនយោបាយការបរទេសរបស់ប្រទេសហ្វីលីពីន ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំជំរុញឲ្យលោកសិក្សាអំពីប្រទេសកម្ពុជា និងប្រើប្រាស់ទស្សនៈរួមបញ្ចូលនៃប្រទេសរបស់លោក និងអនាគតនយោបាយរបស់តំបន់អាស៊ីអាគ្នេយ៍ ។*

*អត្ថបទនេះប៉ុនប៉ងផ្តល់ជាការបកស្រាយចំពោះសំណួរដែលថា «ហេតុអ្វីបានជាបញ្ហាអាណានិគមនៅតែជាប់ពាក់ព័ន្ធ?» ពិភាក្សាលើការដាក់អាណានិគម យោងតាមផ្នត់គំនិតនៃប្រទេសកម្ពុជា ខ្ញុំនឹងផ្តល់ឧទាហរណ៍ថាតើទម្ងន់នៃប្រវត្តិសាស្ត្រអាចបន្តគ្រប់គ្រងលើសម្បជញ្ញៈជាតិក្នុងប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគមដោយរបៀបណា ។ ជាចុងក្រោយ ភាពជោគជ័យនៃគោលនយោបាយការបរទេសនឹងមិនអាចសម្រេចបានតាមរយៈ*




*រូបជួរខាងមុខ រាប់ពីឆ្វេង ៈ ខៀវ សំផន គណប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ អមដំណើរគណប្រតិភូប្រទេសឡាវ ព្រះអង្គម្ចាស់ សុផានុវង្ស នៅព្រលានយន្តហោះពោធិចិនតុង មកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា ។*

ការអះអាងយ៉ាងដាច់អហង្ការ គោលការណ៍ ឬសេចក្តីសម្រេចទេ ក៏ប៉ុន្តែ ជោគជ័យនោះ អាចប្រព្រឹត្តទៅបានតាមរយៈគោលការណ៍រួមបញ្ចូល ដែលឲ្យតម្លៃលើមេរៀនប្រវត្តិសាស្ត្រ ។ គោលនយោបាយការបរទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នឹងមិនមែនជាល្បែងឈ្នះចាញ់នោះទេ ក៏ប៉ុន្តែ គោលនយោបាយនេះគឺជាការខ្នះខ្នែងមួយ ក្នុងការធ្វើឲ្យមានតុល្យភាពនៃតម្លៃ និងផលប្រយោជន៍ ក្នុងបែបផែនមួយដែលតម្រូវឲ្យមានការបញ្ចូលគ្នា និងយន្តការពហុកម្មមួយ ។

## កូនព្រះយេស៊ូនៅម៉ានីឡាៈ ប្រធានាធិបតីរ៉ូឌ្រីហ្គោ ឌូធឺតេ បញ្ហាប្រឈមនានាក្នុងប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគម

គោលនយោបាយការបរទេស គឺត្រូវបានសម្រេចដោយបញ្ហាដែលចោទនាពេលបច្ចុប្បន្ន ក៏ប៉ុន្តែ គោលនយោបាយនេះតែងតែឆ្លុះបញ្ចាំងអំពីអតីតកាល ។ ទន្ទឹមនឹងនេះ នៅក្នុងប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគម ប្រវត្តិសាស្ត្រធ្វើឲ្យមានស្រមោលអតីតកាលដ៏វែងអន្លាយ ។ អ្នកអាចនឹងយល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់លោកប្រធានាធិបតី ឌូធឺតេ ក្នុងការធ្វើឲ្យប្រសើរនូវគោលនយោបាយការបរទេសរបស់ប្រទេសហ្វីលីពីន ។ ទោះបីជាយ៉ាងណាក្តី ខ្ញុំជំរុញឲ្យលោកប្រធានាធិបតី ឌូធឺតេ ធ្វើការសិក្សាអំពីប្រទេសកម្ពុជា និងប្រើប្រាស់ទស្សនៈរួមបញ្ចូលនៃទំនាក់ទំនងការបរទេសរបស់ប្រទេសលោក ក៏ដូចជា អនាគតនយោបាយរបស់តំបន់អាស៊ីអាគ្នេយ៍ ។

ដូចគ្នាទៅនឹងប្រទេសហ្វីលីពីនដែរ ប្រទេសកម្ពុជាបានតស៊ូជាមួយអតីតកាលនៃអាណានិគមរបស់ខ្លួន ។ ប្រទេសបារាំង បានអភិរក្សប្រទេសកម្ពុជា និងរារាំងប្រទេសនេះពីការញាំញីរបស់ប្រទេសជិតខាង គឺប្រទេសថៃ និងប្រទេសវៀតណាម ។ រដ្ឋបាលបារាំងក៏បានគាំទ្រដល់វប្បធម៌ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ក៏ដូចជាកំណែទម្រង់រដ្ឋបាលដែលជួយឲ្យប្រទេសកម្ពុជារីកចម្រើន ។ យ៉ាងណាមិញ ក្នុងនាមជាប្រទេសក្រោមអាណានិគមបារាំង សម្បជញ្ញៈជាតិរបស់ប្រជាជនកម្ពុជា ត្រូវបានគ្រប់គ្រងដោយភាសាបែបចក្រពត្តិរបស់ជនជាតិបារាំង ។ ស្ថិតក្រោមសណ្ឋាននៃកំណែទម្រង់ និង «អារ្យធម៌យានកម្ម» ពាក្យនានា រួមមាន «សញ្ជាតិដើម» «យុគសម័យដើម» ឬ ពាក្យដែលមានន័យអវិជ្ជមានជាងនេះទៅទៀត ត្រូវបានដាក់បញ្ចូលឲ្យប្រើប្រាស់ជាទូទៅ នៅក្នុងឃ្លាងឃ្លានៃភាសា បារាំង-ខ្មែរ ។

ការរួចផុតពីរដ្ឋបាលអាណានិគមបារាំង មិនបានលុបបំបាត់ឥទ្ធិពលនៃភាសាទាំងនេះ និងឥទ្ធិពលរបស់ភាសាទាំងនេះលើអត្តសញ្ញាណជាតិកម្ពុជាទេ ។ ការរួមដៃគ្នារបស់កម្ពុជាចំពោះការតស៊ូក្រោយនឹមអាណានិគមជាមួយប្រទេសជិតខាងគឺប្រទេសវៀតណាម ក៏ដូចជាការតស៊ូរបស់ប្រទេសកម្ពុជាផ្ទាល់ចំពោះអត្តសញ្ញាណជាតិរបស់ខ្លួន បានជួយត្រួសត្រាយផ្លូវដល់ជំហរងាកទៅរកកុម្មុយនីស្តជ្រុលនិយមខ្មែរក្រហម ។ ទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រែក្លាយទៅជាគ្មានលំនឹង ហើយប្រទេសកម្ពុជាបានងាកចេញពីអំឡុងពេលមួយដែលមានការគ្រប់គ្រងដ៏តានតឹង ដោយរដ្ឋាភិបាលយោធា មានបស្ចិមប្រទេសជាខ្នងបង្អែក ទៅកាន់របបជ្រុលនិយមមួយផ្សេងទៀត ពោលគឺអ្នកសាងអនាគត ប្រឆាំងនឹងការគ្រប់គ្រងនៃបស្ចិមប្រទេសរបស់ខ្មែរក្រហម ។

របបខ្មែរក្រហមបំផ្លិចបំផ្លាញដល់ប្រទេសកម្ពុជា ដោយប្រព្រឹត្តនូវអំពើឃោរឃៅប្រឆាំងនឹងមនុស្សជាតិ ពលកម្មដោយបង្ខំ និងការបង្អត់អាហារទ្រង់ទ្រាយធំ ។ ជាចុងក្រោយរបបខ្មែរក្រហមបានបង្កឲ្យមានការស្លាប់ប្រជាជនកម្ពុជាជាងពីរលាននាក់ ។ ប្រជាជនកម្ពុជាជាច្រើនបានភៀសខ្លួនពីប្រទេសបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនេះ ។ ខ្ញុំក៏ជាមនុស្សម្នាក់ក្នុងចំណោមប្រជាជនទាំងនោះដែរ ។ បន្ទាប់ពីរបបខ្មែរក្រហមនេះចាញ់កងកម្លាំងវៀតណាមបានមួយរយៈ ខ្ញុំបានចាកចេញពីប្រទេសកម្ពុជានៅទសវត្សរ៍ទី៨០ និងបានភៀសខ្លួនទៅកាន់ប្រទេសថៃ ជាទីតាំងដែលមន្ត្រីអន្តោប្រវេសន៍សហរដ្ឋអាមេរិកជួយដល់ខ្ញុំ ។ ចេញពីប្រទេសថៃ ខ្ញុំត្រូវបានបញ្ជូនទៅ ខេត្តម៉ូរ៉ុង (Morong Bataan) ដែលជាជំរំជនភៀសខ្លួនមួយនៅក្នុងប្រទេសហ្វីលីពីន ។ នៅទីនោះខ្ញុំទទួលបានក្តីសប្បុរសពីសំណាក់ប្រជាជនហ្វីលីពីន ។ ប្រជាជនហ្វីលីពីន ដែលខ្ញុំបានជួបមិនមានទ្រព្យស្តុកស្តម្ភទេ ក៏ប៉ុន្តែអ្នកទាំងនោះបានស្វាគមន៍ខ្ញុំ និងប្រជាជនកម្ពុជាដទៃទៀត ជាមួយនឹងភាពសប្បុរសរបស់ខ្លួនតាមដែលអាចធ្វើទៅបាន ។

ប្រជាជនកម្ពុជា និងប្រជាជនហ្វីលីពីន មានភាពជាសាច់

ញាតិពីកំណើត នេះមិនមែនដោយសារតែការស្វាគមន៍ដ៏កក់ក្តៅពីប្រជាជនហ្វីលីពីនចំពោះជនភៀសខ្លួនកម្ពុជាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងដោយសារតែភាពស្រដៀងគ្នានៃប្រវត្តិសាស្ត្ររបស់យើងក្នុងនាមជាប្រជាជនស្ថិតក្រោមអាណានិគមបរទេស ។ ខណៈដែលសង្គមរបស់យើង ត្រូវបានដៅដោយប្រវត្តិសាស្ត្រផ្សេងគ្នា ចំណុចនេះហើយដែលជាការតស៊ូរួមរបស់យើង ក្នុងនាមជាប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគម ដែលគេអាចមើលឃើញនូវមនោសញ្ចេតនារួមមួយនេះ ។

លើសពីបីភាគបួននៃប្រជាជនដែលរស់នៅក្នុងពិភពលោកសព្វថ្ងៃ មានជីវិតរស់រានដែលរងឥទ្ធិពលពីបទពិសោធន៍នៃអាណានិគមនិយម ក៏ប៉ុន្តែគោលគំនិតនៃប្រទេសស្ថិតក្រោមអាណានិគមមិនត្រូវទទួលបានការគោរពដ៏សមស្របទេ ។ សកលភាវូបនីយកម្មបញ្ជ្រៀបចូលទៅក្នុងវប្បធម៌របស់ជាតិ ដោយលុបបំបាត់នូវរនាំងនិងបង្កើតជាវប្បធម៌ថ្មីមួយ ។ ក៏ប៉ុន្តែ ខណៈដែលអាណានិគមនិយមគឺជាអ្វីៗគ្រប់យ៉ាង តែត្រូវបានលុបបំបាត់ចេញពីសន្ទានុក្រមនៃទ្រឹស្តីនយោបាយដែលអាចទទួលយកបាន «ប្រទេសស្ថិតក្រោមអាណានិគម» នៅតែបន្តរស់រានមានជីវិត ។

ប្រសិនបើមាននូវអ្វីដូចទៅនឹងបែបផែនដែលលោកប្រធានាធិបតី ឌូធឺតេ លើកឡើង នោះគឺជាកាលៈទេសៈមួយដែលអាណានិគម នៅតែជាប្រធានបទពាក់ព័ន្ធមួយនៃសន្ទនាបែបនយោបាយរវាងអតីតប្រទេសម្ចាស់អាណានិគម និងប្រទេសដែលស្ថិតក្រោមអាណានិគម ។ ជារួម ទម្ងន់នៃប្រវត្តិសាស្ត្រអាណានិគម នៅតែបន្តបង្កើតជាកម្លាំងដ៏វិសេសវិសាលមួយចំពោះសម្បជញ្ញៈជាតិរបស់ប្រជាជននៃប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគម ។ ពាក្យសម្តីរបស់លោកប្រធានាធិបតី ឌូធឺតេ ទាមទារឲ្យមានការយកចិត្តទុកដាក់លើស្ថានភាពនេះ ដេញដោលចំពោះស្ថានភាពដែលមាន និងថាតើមានភាពសមស្របទេ ចំពោះផ្នត់គំនិតនៃវោហាសព្ទបែបចក្រពត្តិ ។

ក៏ប៉ុន្តែ ផ្ទុយពីប្រជាជនមួយចំនួននៅក្នុងប្រទេសហ្វីលីពីនដែលយល់ថា ការលើកឡើងរបស់លោកប្រធានាធិបតី ឌូធឺតេ ហាក់ដូចជាធ្វើឲ្យប្រសើរឡើង លើកទឹកចិត្ត ព្រមទាំងធ្វើការកែទម្រង់ ខ្ញុំជំរុញឲ្យលោក ឌូធឺតេ ពិចារណាលើមេរៀនប្រវត្តិសាស្ត្រ ។

គោលនយោបាយការបរទេស ត្រូវតែមិនស្ថិតក្នុងទម្រង់ឈ្នះ-ចាញ់នោះទេ ។ ការដឹកនាំប្រទេសគឺជាការខិតខំធ្វើឲ្យមានតុល្យភាពចំពោះតម្លៃ និងផលប្រយោជន៍ ក្នុងបែបផែនមួយដែលទទួលស្គាល់ពីសារសំខាន់នៃការរួមបញ្ចូលគ្នា ។ មិនមែនរាល់ការជំទាស់ជាសាធារណៈទាំងអស់ កើតចេញពីអំណាចនៃអាណានិគមដែលបង្កើតឡើងដោយការតាំងខ្លួនជាម្ចាស់អាណានិគមទេ ហើយមិនមែនរាល់ប្រទេសទាំងអស់សុទ្ធតែគោរពចំពោះអធិបតេយ្យភាពរបស់ប្រទេសមួយ ដែលបានជ្រោមជ្រែង នៅក្នុងលក្ខខណ្ឌភូមិសាស្ត្រនយោបាយរយៈពេលដ៏វែងនោះដែរ ។

ដូចគ្នាទៅនឹងអតីតប្រទេសស្ថិតក្រោមអាណានិគមដទៃទៀតដែរ ប្រទេសកម្ពុជាបានខិតខំស្វែងរកអត្តសញ្ញាណជាតិរបស់ខ្លួន ។ ប្រទេសនេះបានឆ្លងកាត់រយៈពេលរាប់ទសវត្សរ៍នៃសង្គ្រាម អំពើឃោរឃៅទ្រង់ទ្រាយធំ និងភាពខ្វះខាតនានា ដើម្បីសម្រេចបានសន្តិភាពមួយដែលប្រហាក់ប្រហែលទៅនឹងការរំពឹងទុក ។ ប្រទេសកម្ពុជាបានបន្តតស៊ូរហូតមកដល់សព្វថ្ងៃ ។ ក៏ប៉ុន្តែ ប្រសិនបើមានមេរៀនណាមួយដែលគួរទទួលយកពីប្រទេសកម្ពុជា នោះគឺគួរតែជាភាពជោគជ័យនៃគោលនយោបាយក្នុងស្រុក និងការបរទេសដែលនឹងមិនអាចសម្រេចបានតាមរយៈការអះអាងយ៉ាងដាច់អហង្ការគោលការណ៍ ឬការសម្រេចចិត្តទេ ។ ប្រទេសមួយមិនអាចគេចវេះពីប្រវត្តិសាស្ត្ររបស់ខ្លួនបានទេ ក៏ប៉ុន្តែប្រទេសនោះក៏មិនចាំបាច់ស្ថិតនៅជាទាសករនៃប្រវត្តិសាស្ត្ររបស់ខ្លួនឯងដែរ ។

*ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត (www.cambodiasri.org) ដែលមានទីតាំងប្រចាំនៅរាជធានីភ្នំពេញ ។ លោកគឺជាអ្នករស់រានមានជីវិតមួយរូបពីរបបពិឃាតខ្មែរក្រហម ។ លោកត្រូវបានចាត់តាំងដោយកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍កម្ពុជានៃសាកលវិទ្យាល័យ យ៉េល ឲ្យធ្វើការស្រាវជ្រាវ បណ្តុះបណ្តាល និងចងក្រងឯកសារទាក់ទងនឹងរបបខ្មែរក្រហម ។ មតិដែលបានបញ្ចេញនៅក្នុងអត្ថបទនេះគឺជាមតិផ្ទាល់របស់អ្នកនិពន្ធប៉ុណ្ណោះ ។*

# ចម្លើយសារភាព ស្វាយ អាន សមាជិកមន្ទីរប-៦៤

*ដកស្រង់ចេញពីឯកសារលេខ៨៦៣ បបគ២*

ស្វាយ អាន ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិត្រពាំងជ្រូក ឃុំសំបូរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងមានប្រពន្ធឈ្មោះ នី បច្ចុប្បន្នជាយុវនារីកាត់ដេររដ្ឋនៅផ្សារអូរឫស្សី ភ្នំពេញ ។

ឆ្នាំ១៩៦៦ ឪពុកម្តាយបានឲ្យ អាន ទៅនៅវត្តសំបូរ ក្នុងឃុំសំបូរ ។ កាលនោះ អាន បានស្គាល់អ្នកនៅវត្តជាមួយគ្នា៣នាក់មានឈ្មោះ ធឿង នៅភូមិជាមួយគ្នា (បច្ចុប្បន្នមិនដឹងទៅណា) , ឈ្មោះ ឈឿង នៅភូមិត្រពាំងថ្ម ស្រុកកំពង់ស្វាយ (បច្ចុប្បន្នមិនដឹងទៅណា) និងឈ្មោះ ធី នៅភូមិកំពង់ដូង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

ជារៀងរាល់ថ្ងៃ ក្រោយពេលសម្រាកពីរៀន អាន តែងនាំ ធឿង, ឈឿង និង ធី ទៅលេងនៅមុខផ្ទះ ជីហ៊ែល ជាមេព្រៃនៅភូមិសំបូរ មានចម្ងាយពីវត្តសំបូរ ប្រហែលកន្លះគីឡូម៉ែត្រ ។ ថ្ងៃមួយ ជីហ៊ែល បានហៅ អាន, ធឿង, ឈឿង និង ធី ទៅអង្គុយលេងនៅក្រោមផ្ទះរបស់គាត់ ហើយគាត់បានសាកសួរពីប្រវត្តិរបស់ម្នាក់ៗមានស្រុកកំណើតនៅឯណា? អាន និងមិត្តភក្តិក៏បានរៀបរាប់ពីប្រវត្តិរបស់ខ្លួនប្រាប់ទៅគាត់វិញ ។ ពេលនោះគាត់ក៏និយាយអប់រំ អាន និងបក្ខពួកឲ្យជួយតាមដានខ្មែរក្រហម បើឃើញខ្មែរក្រហមនៅកន្លែងណា ត្រូវមករាយការណ៍ប្រាប់គាត់ៗនឹងឲ្យលុយចាយ ។ ពេលឮថាគាត់ឲ្យលុយចាយ អាន និងបក្ខពួកក៏យល់ព្រមធ្វើការឲ្យគាត់ពុំមានប្រកែកទេ ហើយជីហ៊ែល ក៏បានប្រាប់ឲ្យ អាន និងបក្ខពួក វិលត្រឡប់ទៅវត្តសំបូរវិញ ។

ចុងឆ្នាំ១៩៦៦ ជីហ៊ែល បានហៅ អាន, ធឿង, ឈឿង និង ធី ទៅធ្វើការនៅផ្ទះគាត់ ។ ពេលទៅដល់ អាន បានឃើញសែបឈុំ ដែលជាប៉ូលីសនៅប៉ុស្តិ៍កំពង់ឈើទាល ក្នុងឃុំសំបូរ និងសែបនិត, សែបសុខ នៅនោះដែរ ។ ពេលនោះ ជីហ៊ែល បានខទ្មុសនាមសែប ឈុំ, និត, សុខ ឲ្យទទួលស្គាល់ អាន និងបក្ខពួក ។ គាត់បាននិយាយថា បើពួកយើងស៊ើបការណ៍ឃើញខ្មែរក្រហមនៅកន្លែងណា ត្រូវរាយការណ៍មកសែបឈុំ, សែបនិត និងសែបសុខ រួចហើយបានចាត់ឲ្យ អាន និងបក្ខពួកចុះធ្វើការតាមភូមិ-ឃុំរបស់ខ្លួនម្នាក់ៗ ហើយបានកំណត់ឲ្យប្រាក់ខែម្នាក់ៗ ១.០០០រៀល និងពេលធ្វើការចប់ ជីហ៊ែល បានឲ្យលុយម្នាក់ៗ ៣.០០០រៀលថែមទៀត ។

ដើមឆ្នាំ១៩៦៧ បក្ខពួករបស់ អាន ឈប់នៅវត្ត ហើយបានត្រឡប់ទៅនៅតាមផ្ទះរៀងៗខ្លួនវិញ ។ ដោយឡែក អាន និង ធឿង ដែលនៅភូមិជាមួយគ្នា បានដើរធ្វើកិច្ចការនេះជាប់ និងបានស៊ើបឃើញខ្មែរក្រហមបីនាក់កំពុងដាំបាយនៅទួលកក់ស្វាយ ។ អ្នកទាំងពីរក៏បានរាយការណ៍ឲ្យសែបឈុំ យកកម្លាំងទៅព័ទ្ធចាប់ តែចាប់មិនបាន ព្រោះខ្មែរក្រហមចេញពីទីនោះផុត ។ ក្រោយមក សែបឈុំ បានតាមដានឃើញ និងចាប់ខ្មែរក្រហមទាំងបីនាក់នោះ បាននៅព្រៃអូរទឹទុយ ក្នុងស្រុកកំពង់ស្វាយ ។ ចុងឆ្នាំ១៩៦៧ សែបឈុំ បានហៅ អាន និងធឿង


រណ្តៅសាកសពរួម ត្រូវបានគាស់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ឆ្នាំ១៩៧៩

ឲ្យទៅធ្វើការនៅប៉ុស្តិ៍កំពង់ឈើទាល ឃុំសំបូរ ។ សែបឈុំ បានខ្ទេសនាមឲ្យ ធឿង និង អាន ទាក់ទងធ្វើគិញជាមួយឈ្មោះ ម៉ប់ សុត និង ស៊ិន ។

ឆ្នាំ១៩៦៨ អាន, ម៉ប់, ធឿង, ស៊ិន និង សុត បានធ្វើការស៊ើបអង្កេតឃើញខ្មែរក្រហមចំនួន៥នាក់ កំពុងដាំបាយនៅក្នុងព្រៃបឹងវនាមដូវរទេះ ។ អាន និង សុត បានយកដំណឹងនេះទៅរាយការណ៍ឲ្យសែបឈុំ យកកម្លាំងចុះទៅព័ទ្ធចាប់បាន២នាក់ ឯ៣នាក់ទៀតរត់រួច ។

ក្រោយរដ្ឋប្រហារ ១៨ មីនា ១៩៧០ ពួកវៀតណាមបានចូលទៅវាយដល់ប៉ុស្តិ៍កំពង់ឈើទាល ។ ជីហ៊ែល, សែបនិត, សែបឈុំ និងសែបសុខក៏បាននាំគ្នារត់បាត់អស់ ដោយបក្ខពួករបស់ អានក៏ទៅធ្វើការរកស៊ីនៅតាមផ្ទះរៀងៗខ្លួនជាធម្មតា ។

ខែឧសភា ឆ្នាំ១៩៧១ ឈ្មោះហុង (ពីមុនធ្វើការនៅជាមួយ ជីហ៊ែល បច្ចុប្បន្នមិនដឹង) បានចូលមកទាក់ទង អាន, ធឿង, ម៉ប់, សុត និង ស៊ិន ហើយបានឲ្យអ្នកទាំងនេះ ទៅធ្វើការនៅក្នុងព្រៃក្រោយភូមិត្រពាំងជ្រូក ។ ហុង បានខ្ទេសនាមប្រាប់ អាន និងបក្ខពួកថា ជីហ៊ែល បានរត់ចូលទៅដល់ក្រុងកំពង់ធំហើយៗឲ្យ បក្ខពួករបស់ អាន ចូលធ្វើការជាមួយខ្លួន (ខ្មែរស) ព្រោះបន្តិចទៀត ខ្មែរក្រហមចូលពេញភូមិ យើងមិនបាននៅក្នុងភូមិទេ ។ ហុង បានបញ្ជាក់ទៀតថា បើ អាន និងបក្ខពួកចូលធ្វើការជាមួយគាត់ៗ អាចជូនទៅជួប ជីហ៊ែល ថ្ងៃណាក៏បាន ។

ប្រហែលកន្លះខែក្រោយមក ហុង ក៏បានមកយក អាន, ធឿង, ម៉ប់, សុត និង ស៊ិន នាំចូលទៅក្នុងព្រៃអូរកប់ប្រមាត់ (ស្រុកកំពង់ស្វាយ) កាលនោះបានឃើញកម្លាំងខ្មែរសរបស់ ហុង ចំនួន៦នាក់កំពុងហាត់បច្ចេកទេសយោធានៅទីនោះ ។ ហុង ក៏បានឲ្យបក្ខពួករបស់ អាន ចូលហាត់ជាមួយគ្នា ។

ដល់ខែមិថុនា ឆ្នាំ១៩៧១ ហុង បានចាត់តាំងឈ្មោះ មីន អនុប្រធានខ្មែរស (បច្ចុប្បន្នមិនដឹង) នាំ អាន, សុត និងខ្មែរសចំនួន៤នាក់ផ្សេងទៀត ទៅវាយដណ្តើមកាំភ្លើងពីយោធានៅសាលាវិស័យ ក្នុងស្រុកកំពង់ស្វាយ តែកាលនោះយោធាដឹងមុន ក៏បានបាញ់រះមកវិញ ហើយបក្ខពួករបស់អាន ក៏នាំគ្នារត់ត្រឡប់មកក្រោយវិញអស់ ។ ខែកក្កដា ១៩៧១ ហុង បានចាត់តាំង អាន, សុត, ម៉ប់, ស៊ិន ឲ្យជូនឈ្មោះមីន និង យាង ជាសមាជិកខ្មែរស បច្ចុប្បន្នមិនដឹង ឡើងទៅកាត់ផ្លូវនៅម្តុំព្រៃអូរពោ ចាំបាញ់ខ្មែរក្រហម ដែលចេញពីសាលាវិស័យ ឡើងទៅស្រុកសណ្តាន់ ។ ចុងខែសីហា ១៩៧១ ហុង បាននាំខ្មែរសទាំងអស់ជាង៦០នាក់ ធ្វើដំណើរឡើងទៅស្រុកស្ទោង ហើយក៏បានពើបប្រទះជាមួយខ្មែរក្រហមនៅម្តុំសាលាវិស័យ និងបានវាយប្រយុទ្ធគ្នា ហើយរត់បាក់បែកគ្នាអស់ ។ ដោយឡែក អាន និង ធឿង ក៏បាននាំគ្នារត់ត្រឡប់មកផ្ទះវិញ ។ ខែវិច្ឆិកា ១៩៧១ បងថ្លៃ អាន ឈ្មោះ គី ជាប្រធានភូមិត្រពាំងជ្រូក ក៏បានអប់រំឲ្យ អាន ចូលធ្វើបដិវត្តន៍ ពេលនោះ អាន ក៏យល់ស្រប ។ ឈ្មោះ គី ក៏បាននាំ អាន ទៅឲ្យឈ្មោះ ញែម ជាលេខាស្រុកកំពង់ស្វាយ (ក្រោយរំដោះឃើញនៅខាងពាណិជ្ជកម្មកំពង់ស្វាយ បច្ចុប្បន្នអង្គការចាប់ហើយ នៅមន្ទីរស្រុកកំពង់ស្វាយ) ។

ខែកុម្ភៈ ១៩៧២ បងឃួន ជាលេខាភូមិភាគឧត្តរ (ក្រោយរំដោះជាប្រធានពាណិជ្ជកម្មរដ្ឋ បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) បានយក អាន ទៅនៅក្នុងមន្ទីរហ-៨៣ ជាមួយខ្លួន នៅក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ខែឧសភា ឆ្នាំ១៩៧២ បងផេង សេដ្ឋកិច្ចមន្ទីរភាគ (បច្ចុប្បន្នមិនដឹង) បាននាំ អាន បញ្ចូលជាសម្ព័ន្ធយុវកកដែលមានឈ្មោះ ហម ប្រធានកងចល័តមន្ទីរភាគ (បច្ចុប្បន្ននៅរោងអារឈើចាក់អង្រែ) ជាអ្នកខ្ទេសនាម ឈ្មោះ ធី ប្រធានមន្ទីរភាគឧត្តរ (បច្ចុប្បន្ននៅផ្សារមិត្តភាព) ជាអ្នកទទួលស្គាល់ ។ លុះចុងខែឧសភា ឆ្នាំ១៩៧២ ឈ្មោះ ញែម បានលើកពីប្រវត្តិរបស់ អានរាយការណ៍ឲ្យ ឃួន ហើយបានណែនាំ អាន ឲ្យធ្វើសកម្មភាពតាមផែនការដូចជាៈ

១) បំផុសយុវវ័នឲ្យឃើញតែការសប្បាយស៊ីផឹកសេរីតាមចិត្ត

២) បំផុសប្រជាជនឲ្យរត់ចូលខ្មាំង

៣) បំផ្លាញបដិវត្តន៍តាមការងារប្រចាំថ្ងៃ

៤) កសាងកម្លាំង

នៅពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៧២ បង ឃួន បានចាត់តាំងឈ្មោះ សាន ដែលជាអ្នកបើកឡានឲ្យ ឃួន-៧៦ សមាជិកគណៈយានដ្ឋានពាណិជ្ជកម្មក្រៅប្រទេស (បច្ចុប្បន្នក្តាប់មិនបាន)

ឲ្យបើកឡានទៅយកឈ្មោះ ឆុន ប្រធានមន្ទីរលេខ២២ សាខារបស់ ហ-៨៣-៧៦ នៅឃុំវាំងសាំងបុស្សី ។ ឈ្មោះ ធុង ប្រធានរោងពុម្ពភាគខត្តរ-៧៥ ឃើញនៅរោងចក្រប្រេងកាតកំពង់សោម (បច្ចុប្បន្នមិនដឹង) ។ ឈ្មោះ ឈាង ប្រធានចម្ការម្នាស់ភាគខត្តរ-៧៥ ឃើញនៅមន្ទីរចាត់ការពាណិជ្ជកម្មរដ្ឋនៅម្តុំផ្សារចាស់ (បច្ចុប្បន្នមិនដឹង) ។ ឈ្មោះនិត ប្រធាននីរសាររមន្ទីរភាគខត្តរនៅសង្កាត់ខ្វយ ស្រុកស៊ឹងត្រង់ (បច្ចុប្បន្នមិនដឹង) ឲ្យមកជួបគ្នានៅមន្ទីរហ-៨៣ ហើយនៅពេលនោះ អាន និង សាន ក៏បានទទួលបញ្ជាពីបងប្អូនឲ្យចូលរួមដែរ ។

ដើមឆ្នាំ១៩៧៣ អាន និង សាន បានបំផ្លាញឡានហេ្សអឹមសេ ឲ្យខូចអស់មួយគ្រឿងដោយយកដីខ្សាច់ដាក់ក្នុងប៊ុស្តុង ។ ក្រោយមក បងប្អូន បានចាត់តាំង អាន, សាន, ធុង, និត ឲ្យបើកឡានឡង់រ៉ូវែរមួយគ្រឿងយកទៅកម្ទេចចោលនៅចម្ការកៅស៊ូភ្នំព្រៃសង្កែ ។

ឆ្នាំ១៩៧៤ បងប្អូន បានប្តូរមកនៅមន្ទីរង-៦៤ ជិតភូមិខ្វយ ស្រុកស៊ឹងត្រង់ លុះដល់ខែមេសា ឆ្នាំ១៩៧៤ បងប្អូន បានចាត់តាំង អាន ឲ្យធ្វើជានីរសាររមន្ទីរង-៦៤ ។ ក្រោយមក នៅខែឧសភា អាន, និត និង ឆុន បានបំផុសប្រជាជនចំនួន៣គ្រួសារនៅភូមិកប់មាន់ឲ្យរត់ចូលខ្មាំង ដោយបំផុសឲ្យឃើញថាការធ្វើបដិវត្តន៍មានការលំបាក ។

ក្រោយរំដោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បងប្អូន បានចាត់តាំង អាន ឲ្យទៅនៅខាងពាណិជ្ជកម្មកំពង់សោម លុះដល់ពាក់កណ្តាលខែកក្កដា ១៩៧៥ ធុង បានចាត់ អាន ឲ្យមកជួបជុំគ្នាដោយមានឈ្មោះ ឆុន, ធុង, អាន, លី ប្រធានកម្មករលីសែង យុន អនុក្រុមកម្មករលីសែង, ធា សមាជិកកម្មករលីសែង, ដែលខ្លឹមសារគឺឲ្យ៖

១) បំផុសយុវ័នឲ្យភ្លើតភ្លើន នឹងការសប្បាយស្រីស្រា

២) មិនឲ្យសកម្មនឹងការងារ

៣) បំផុសយុវ័នឲ្យសេរី មិនគោរពការចាត់តាំងរបស់អង្គការ

ខែកញ្ញា ឆ្នាំ១៩៧៥ បងប្អូន បានចាត់តាំង អាន ឲ្យមកនៅមន្ទីរ៧៥ នៅប្រាំងចម្រេះ ភ្នំពេញ ខាងធ្វើស្រែ ។ ពេលនោះ អាន បានជួប សាន ដែលជាខ្មែរយេះចាស់ធ្វើជាប្រធាននៅមន្ទីរ៧៥ ។ ដល់ខែតុលា ឆ្នាំ១៩៧៥ បងប្អូន បានណែនាំ អាន ឲ្យស្គាល់ ធួន ជាខ្មែរសង្កាក់ ហើយបានចាត់តាំង អាន ឲ្យទាក់ទងធ្វើការងាររក្សត់ជាមួយ ធួន ។ បន្ទាប់មកបងប្អូន បានណែនាំ អាន ឲ្យបំផុសយុវជន និងយុវនារីនៅក្នុងមន្ទីរ៧៥ ឲ្យធ្វើខុសសីលធម៌ ។

ពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៦ សាន បានចាត់តាំង អាន ឲ្យទៅជួបនារី រឿន នៅផ្សារមិត្តភាព (បច្ចុប្បន្នអង្គការចាប់ហើយ) នៅផ្ទះមួយស្វាត់នៅប្រាំងចម្រេះ វេលាម៉ោង១២ថ្ងៃត្រង់ ហើយបានខទ្មេសនាមឲ្យ អាន បានស្គាល់ នារី រឿន ជាខ្មែរសង្កាក់សម្រាប់ទាក់ទងធ្វើសកម្មភាពក្បត់ជាមួយគ្នា ។ ក្រោយមក នារីរឿន បានដក អាន ចេញពីមន្ទីរ៧៥ ហើយចាត់តាំងឲ្យមកនៅមន្ទីរប-៦៤ ធ្វើជាសមាជិកគណៈមន្ទីរប-៦៤ ផ្នែកខាងដាំបន្លែនៅតាខ្មៅ ។ បន្ទាប់មក នារីរឿន បានចាត់តាំងនីរសាររបស់ខ្លួនឲ្យមកហៅ អាន និង សាង ទៅជួបនៅក្នុងព្រៃដើមស្វាយ ដើម្បីទាក់ទងធ្វើសកម្មភាពជាមួយគ្នានៅកន្លែងដាំបន្លែ ដោយបំផុសយុវជន និងយុវនារីឲ្យខូចសីលធម៌នឹងគ្នា ។

ចុងខែវិច្ឆិកា ឆ្នាំ១៩៧៦ នារីរឿន ត្រូវបានអង្គការដកចេញពីអង្គភាព ។ ចាប់ពីពេលនោះមក មិនដែលឃើញនារីរឿនមកជួបនឹង អាន ឡើយ ។ ដល់ខែធ្នូ ឆ្នាំ១៩៧៦ អង្គការបានដកឈ្មោះ សាង ចេញទៀតមិនដឹងជាដកទៅទីណា ។ អាន ក៏បានធ្វើសកម្មភាពដឹកនាំបងប្អូននៅមន្ទីរប-៦៤ យកថ្នាំលាយនឹងទឹកក្រស៊ីល ហើយយកទៅបាញ់លើបន្លែឆៃថាវខ្លោចខូចអស់៦០រោង (ក្នុងមួយរោង ស្មើនិង១៥ម៉ែត្រ) ។

ខែមីនា ឆ្នាំ១៩៧៧ ពេល អាន ទៅរៀន បានឮអង្គការប្រកាសពីការចាប់ខ្លួននារីរឿន ។ ខែឧសភា ១៩៧៧ អាន បានទៅលេងគ្រួសារនៅអូរឫស្សី លុះដល់ពេលយប់ក៏បានឆ្លៀតទៅជួបឈ្មោះម៉ន និងហូ នៅផ្សារមិត្តភាព ដើម្បីរកទឹកក្រូចហូប ។ ពេលហូបរួច ម៉ន និងហូ បាននាំ អាន ទៅយកស្ករស៦បាវ ពីឃ្លាំងមួយនៅឆ្ងាយពីផ្សារមិត្តភាពប្រហែល៣០០ម៉ែត្រ នៅឈៀងខាងលិចមកវះមាត់បាវ ហើយចាក់បង្ហូរចូលទៅក្នុងលូទឹកស្អុយ ។ ពេលធ្វើការងារហើយ អាន ក៏បានត្រឡប់មកកន្លែងវិញ ។ លុះដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានចាប់ អាន បញ្ជូនមកទីនេះតែម្តង ។ **ចៅ ព្រហស្បតិ៍**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង ៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ៖ ម៉ែន ពិចិត្រ ទូរស័ព្ទលេខ ៖ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthmpechet@dccam.org*

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*



















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthmpechet@dccam.org ។

**◆ទីកន្លែង : អគារ “ក” ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ពិធីផ្សព្វាយបន្តការប្រកាសសាលដីកាស្ថាពរសំណុំរឿង០ នួន ជា និង ខៀវ សំផន នៅវត្តស្វាយធន្ទឹម









# ០២ វគ្គ១ ទាក់ទងបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ឃុំត្រពាំងស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀង









# ពង្រឹង និងពង្រីកបក្សគ្រប់ថ្នាក់ គ្រប់មូលដ្ឋានឱ្យខ្លាំងក្លា ដើម្បីសកម្មប្រយុទ្ធ ដឹកនាំអនុវត្តផែនការកសាងសង្គមនិយមរបស់បក្ស ក្នុងរយៈយូរឆ្នាំ ឱ្យបានមហាជោគជ័យ មហាលោតផ្លោះ

*(ដកស្រង់ចេញឯកសារទង់បដិវត្តន៍លេខ៨ ខែសីហា ឆ្នាំ១៩៧៦ D២១៤១៧)*

បក្សយើងបានរៀបចំផែនការកសាងសង្គមនិយមរយៈយូរឆ្នាំ ។ ផែនការយើងរៀបចំបានត្រឹមត្រូវជាអតិបរមា ។ បើផែនការត្រឹមត្រូវជាមូលដ្ឋានហើយ ទុកជាជ័យជម្នះជាមូលដ្ឋាន ។ ផែនការនេះត្រូវយកទៅអនុវត្តជាក់ស្តែង ។

តើអ្នកណាជាអ្នកអនុវត្ត ធ្វើឲ្យផែនការបានសម្រេចជ័យជម្នះ ។ អនុវត្តនឹងសម្រេចបានល្អ ឬមិនល្អ គឺអាស្រ័យលើកម្លាំងដែលត្រូវធ្វើ លើអ្នកដែលត្រូវធ្វើ ។ ដើម្បីសម្រេចបានជោគជ័យនូវផែនការរបស់បក្ស សំខាន់បំផុតត្រូវមានកត្តាបក្សដឹកនាំរឹងប៉ឹងនិងខ្លាំងក្លា ។ ទន្ទឹមនេះ ត្រូវមានកម្លាំងសម្ព័ន្ធភាពកម្មករ កសិករខ្លាំងក្លា ត្រូវមានកម្លាំងការពារប្រទេសខ្លាំងក្លា ។ កត្តារួមផ្សំមួយទៀតគឺត្រូវមានមិត្តភក្តិលើសកលលោកឲ្យច្រើន ។

សរុបមកវិញគឺមានកត្តាបក្ស ប្រជាជន កងទ័ពបដិវត្តន៍ និងការបរទេស ។ តែកត្តាសំខាន់នៅលើបក្ស ។ បើបក្សជ្រួតជ្រាប និងប្តេជ្ញាចិត្តអនុវត្តខ្ពស់ ប្រជាជន និងកងទ័ពបដិវត្តន៍ក៏ជ្រួតជ្រាប និងប្តេជ្ញាចិត្តអនុវត្តខ្ពស់ដែរ ។

កត្តាផ្សេងៗ យើងមានទាំងអស់ហើយ ។ ឥឡូវនៅតែបក្សដឹកនាំឲ្យបានល្អ ។ ការដឹកនាំនេះ ក៏កាន់តែចម្រើនបានល្អជាលំដាប់ហើយ ។ តែសមត្ថភាពដឹកនាំកសាងសង្គមនិយមតាមផែនការរយៈយូរឆ្នាំរបស់បក្សត្រូវឲ្យកាន់តែរឹងមាំខ្លាំងក្លា រស់រវើក ច្នៃប្រឌិតថែមទៀត ។ បើដោះស្រាយបញ្ហាបក្សបានផែនការមុខជាសម្រេច



កសិករនៅតាមសហករណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នាំគ្នាលើកប្រព័ន្ធភ្លឺស្រែ

បានពី៨០ ទៅ១០០ភាគរយ តាមកាលកំណត់ ។

តើដោះស្រាយបញ្ហាបក្សយ៉ាងណា? យើងសូមរួមយោបល់មួយចំនួនជាបឋម ដូចខាងក្រោមនេះ ៖

**១) ជាបឋមត្រូវដាច់ខាតកម្ចាត់ឲ្យអស់នូវសំណល់ចាស់ដែលមិនបដិវត្តន៍ឲ្យអស់រលីងពីក្នុងបក្ស**

ជាក់ស្តែង ត្រូវកម្ចាត់ឲ្យអស់នូវកម្មសិទ្ធិឯកជន ។ ជាខាងសម្ភារ ជាខាងទស្សនគោលជំហរ សតិអារម្មណ៍ ដែលមិនអធន ។ បញ្ហានេះត្រូវប្រយុទ្ធឲ្យខ្លាំងក្លា នៅក្នុងបក្សគ្រប់ថ្នាក់ និងគ្រប់មូលដ្ឋាន គ្រប់អង្គភាពជាប់ជានិច្ច ។ កម្មាភិបាលគ្រប់ថ្នាក់ ពិសេសកម្មាភិបាលថ្នាក់មធ្យម និងថ្នាក់លើត្រូវធ្វើជាគំរូក្នុងការប្រយុទ្ធកម្ចាត់កម្មសិទ្ធិឯកជនគ្រប់ប្រភេទ ។ គុណភាពរបស់បក្សត្រូវប្រែប្រួលឲ្យឆាប់រហ័ស ។ ធាតុវណ្ណៈអធនរបស់បក្ស ត្រូវខ្លាំងក្លា ទើបដឹកនាំអនុវត្តផែនការបានសម្រេច ។

ជាងមួយឆ្នាំកន្លងមកនេះ ធាតុវណ្ណៈអធនរបស់បក្ស វិវត្តទៅល្អ ។ តែបើប្រៀបធៀបនឹងចលនាបដិវត្តន៍ក្នុងដំណាក់កាលថ្មីនៃបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមឃើញថា នៅមិនទាន់គ្រប់គ្រាន់ នៅខ្វះខាត ។ បើឈរលើសំណូមពរនៃផែនការកសាងសង្គមនិយមរបស់បក្សរយៈយូរឆ្នាំ យើងកាន់តែត្រូវយកចិត្តទុកដាក់ ពង្រឹងឲ្យខ្លាំងក្លាថែមទៀត ទុំមួយជាដប់ ជាមួយរយនូវគោលជំហរនៃវណ្ណៈអធនរបស់បក្សនៅក្នុងជួរកម្មាភិបាល ជួរបដិវត្តន៍យើង ទើបបម្រើសំណូមពររបស់បក្សបាន ។

ទាល់តែប្រយុទ្ធកម្ចាត់កម្មសិទ្ធិឯកជនគ្រប់ប្រភេទឲ្យអស់ ហើយកសាងគោលជំហរវណ្ណៈអធនរបស់បក្សឲ្យរឹងមាំ ទើបបក្សខ្លាំង ។ បើបក្សខ្លាំងហើយ សម្រេចអ្វីៗក៏បានទាំងអស់ ។

**២) បំផុសស្មារតីសកម្មប្រយុទ្ធរបស់បក្ខជន**

រួមជាមួយប្រជាជន មហាជន កម្លាំងប្រយុទ្ធមួយខ្លាំងក្លាទៀត គឺនៅលើបក្ខជន ។ បើបក្ខជនជ្រួតជ្រាបផែនការ មានជំនឿលើផែនការ ឃើញអនាគតនៃការកសាងប្រទេសតាមផែនការដែលបក្សលើកឡើងបានច្បាស់នោះ កម្លាំងប្រយុទ្ធអនុវត្តផែនការមុខជាខ្លាំងក្លា គ្មានអ្វីមករារាំងបានទេ ។ ដូច្នោះ ចំណុចផែនការណាដែលមិនសម្ងាត់ ហើយពាក់ព័ន្ធដល់បក្ខជននៅកន្លែងនោះត្រូវអនុវត្តត្រូវចាត់តាំងរៀនសូត្រឲ្យហ្មត់ចត់ ។ ត្រូវឲ្យបក្ខជនពិភាក្សាឲ្យផុសផុល ។ ប្រែក្លាយផែនការរបស់បក្ស ទៅជាកម្លាំងខាងទស្សនៈខាងគោលជំហរ សតិអារម្មណ៍ និងចាត់តាំងឲ្យបក្ខជន ។ បើបក្ខជនជ្រួតជ្រាបផែនការ ជាសាច់ជាឈាមហើយ មុខជាមានស្មារតីភ្ញាក់រលឹក គោរពអង្គការចាត់តាំង គោរពវិន័យខ្ពស់ក្នុងការអនុវត្តផែនការ ។

បើជ្រួតជ្រាបផែនការ ហើយថែមទាំងភ្ញាក់រលឹកខាងវិន័យអង្គការខ្ពស់ទៀត កម្លាំងទាំងពីរនេះ ប្រយុទ្ធវាយសម្រុក បានខ្លាំងក្លាណាស់ ហើយមិនចេះហត់ហេវ ។ វាយសម្រុកកសាងសង្គមនិយម តាមផែនការបក្សបានទាំងប្រាំង ទាំងវស្សា ទាំងយប់ទាំងថ្ងៃ ទាំងពេលលំបាក ទាំងពេលស្រួល ។ ដូច្នេះផែនការ កុំទុកនៅត្រឹមថ្នាក់ដឹកនាំ ។ ត្រូវបំផុសប្រជាធិបតេយ្យ ក្នុងការពិភាក្សាផែនការ ក្នុងន័យជាទស្សនៈគោលជំហរ សតិអារម្មណ៍ និងក្នុងន័យអនុវត្តជាក់ស្តែង ឲ្យបានទូលាយក្នុងបក្ខជន តាមក្របខណ្ឌដែលមានការទាក់ទងដល់ការងារតាមភារៈ នាទីរបស់បក្ខជននោះ ។

**៣) ជ្រើសរើសកម្មាភិបាលគ្រប់ថ្នាក់ គ្រប់មូលដ្ឋានឲ្យបានល្អ**

ត្រូវប្រកាន់ខ្ជាប់តាមលាក់ការណ៍ជ្រើសរើសកម្មាភិបាលរបស់បក្ស ។ បញ្ហានេះ ជាមូលដ្ឋាន ។ ព្រមជាមួយគ្នានេះ ត្រូវជ្រើសរើសកម្មាភិបាលឲ្យស្របតាមសំណូមពរនៃភារកិច្ចបច្ចុប្បន្ន ។ បច្ចុប្បន្ននេះ ត្រូវការកម្មាភិបាលដែលមានការយល់ដឹងខាងកិច្ចការកសាងសង្គមនិយម ។ ជាក់ស្តែង គឺមានការយល់ដឹងខាងសេដ្ឋកិច្ច ទើបមានគោលជំហរ សមត្ថភាពដឹកនាំខាងសេដ្ឋកិច្ចគ្រប់ផ្នែកបាន ។ និយាយថា ត្រូវយល់ដឹងខាងសេដ្ឋកិច្ចនេះ មិនមែនយល់ដឹងអ្វីក្រៅពីត្រូវធ្វើ ត្រូវកសាងជាក់ស្តែងនោះទេ ។ ឧទាហរណ៍ៈ កម្មាភិបាលគ្រប់ថ្នាក់ គ្រប់មូលដ្ឋាន ដើម្បីដឹកនាំធ្វើស្រែឲ្យបានបីតោនក្នុងមួយហិកតាតាមផែនការរបស់បក្ស ត្រូវដឹងថាតើនៅក្នុងជួរមូលដ្ឋានរបស់ខ្លួន ដីត្រង់ណាខ្លាញ់ ត្រង់ណាមិនខ្លាញ់ ។ សភាពទឹកយ៉ាងម៉េច ។ ដីណាធ្វើស្រែពីរដងបាន មានប៉ុន្មានហិកតា ។ ដីណាដាំសណ្តែកបាយ សណ្តែកដីបាន ។ ធ្វើស្រែស្រូវស្រាល ត្រូវធ្វើនៅកន្លែងណា ។ បញ្ហាដីកព្រែក ដីកប្រឡាយ ត្រូវដីកត្រង់ណា ទើបបម្រើសំណូមពរដោះស្រាយទឹកបាន ។ បញ្ហាជី បញ្ហាថ្នាំកម្ចាត់សត្វល្អិត បញ្ហាពូជស្រូវត្រូវទុកដាក់យ៉ាងណាឲ្យបានល្អ ។ បញ្ហាចិញ្ចឹមគោ ក្របី សេះ ជ្រូក មាន់ ទា ត្រូវចិញ្ចឹមយ៉ាងណាកុំឲ្យឈឺ ។ល ។

ឯកម្មាភិបាលខាងឧស្សាហកម្ម ក៏ត្រូវយល់ដឹងពីគ្រឿង

ម៉ាស៊ីនពីវត្ថុធាតុដើម ។ល។ ទើបដឹកនាំខាងឧស្សាហកម្មបានល្អ ។

កម្មាភិបាលគ្រប់ផ្នែកសេដ្ឋកិច្ចឯទៀតៗ ក៏ត្រូវយល់ដឹងផ្នែករបស់ខ្លួនឲ្យច្បាស់លាស់ជាបន្ទូរដែរ ទើបដឹកនាំកិច្ចការកសាងសង្គមនិយមបាន ។

ការយល់ដឹងនេះ គឺយល់ដឹងដោយឈរលើគោលជំហរនៃវណ្ណៈអធនរបស់បក្ស ។ យល់ដឹងដើម្បីច្នៃប្រឌិត អនុវត្តផែនការកសាងសង្គមនិយមរបស់បក្សបានល្អ ។ មិនមែនយល់ដឹងខាងសេដ្ឋកិច្ចតាមគោលជំហររបស់វណ្ណៈនាយទុនទេ ។

ឧទាហរណ៍ៈ បញ្ហាដោះស្រាយរឿងទឹក ត្រូវយល់ដឹងពីប្រភេទដីជាក់ស្តែងថាត្រូវជីកប្រឡាយយ៉ាងណា ធ្វើអាងយ៉ាងណា ។ មិនមែនថា ត្រូវតែប្រើម៉ាស៊ីន ដើម្បីដោះស្រាយទឹកគ្រប់ពេលវេលា គ្រប់ទីកន្លែងទេ ។ ម៉ាស៊ីនយើងខ្វះខ្មៅ ខ្វះឧបករណ៍បញ្ហាសំខាន់ត្រូវច្នៃប្រឌិតធ្វើខ្មៅ ធ្វើឧបករណ៍ ។ មិនមែនធ្វើអ្វីបន្តិចក៏ទិញ ខ្វះអ្វីបន្តិចក៏ទិញនោះទេ ។ ទាល់តែកម្មាភិបាលដឹកនាំមានការយល់ដឹង និងមានគំនិតច្នៃប្រឌិតក្នុងការកសាងសង្គមនិយម ទើបគោលជំហរស្នេហាជាតិរបស់ប្រជាជនយើង មិនសាបរលាប ផ្ទុយទៅវិញ កាន់តែពង្រឹង និងពង្រីក ព្រោះយើងមិនរណបបរទេសខាងសម្ភារៈ ។

### ៤) អង្គការដឹកនាំគ្រប់ថ្នាក់ ត្រូវទាក់ទងគ្នាឲ្យបានល្អ

ត្រង់ខនេះ សុំសង្កត់តែលើចំណុចការងារតាមដានត្រួតពិនិត្យការអនុវត្តផែនការ ក្នុងការតាមដាន ត្រួតពិនិត្យការអនុវត្តផែនការមានប្រយោជន៍ពីរយ៉ាង ។ ម្យ៉ាងតាមដានអំពីលទ្ធផលដែលធ្វើបាន ហើយម្យ៉ាងទៀត តាមដានពិនិត្យអំពីផែនការ តើមានខ្វះខាតចំណុចណា ដើម្បីបំពេញបន្ថែមឲ្យទាន់ពេលវេលា ។

ដូច្នេះ ការតាមដានត្រួតពិនិត្យ អនុវត្តផែនការ មានសារសំខាន់ណាស់ ក្នុងការជំរុញផែនការឲ្យមានល្បឿនស្ទុះលោតផ្លោះ ។ សំខាន់ម្យ៉ាងទៀតត្រង់ថា បច្ចុប្បន្នបញ្ហាកសាងសង្គមនិយម មិននៅត្រឹមតែឧត្តមគតិ ត្រឹមតែទស្សនៈ ត្រឹមតែទិសដៅ ឬមាគ៌ារួមៗ ទៀតទេ ។ កសាងសង្គមនិយមនេះ វាជាផែនការហើយ ។ វាជាសាច់ការត្រូវធ្វើជាក់ស្តែងជាប្រចាំថ្ងៃ ។ សព្វថ្ងៃ ធ្វើអ្វីក៏ដោយ តូចក្តី ធំក្តី សុទ្ធតែចូលក្នុងកិច្ចការកសាងសង្គមនិយមទាំងអស់ ។ ធ្វើឲ្យម៉ាស៊ីនខូច ក៏ប៉ះពាល់ជាក់ស្តែងដល់ការកសាងសង្គមនិយម ។ បាក់ទំនប់ ទឹកលិចខូចសំណាប ខូចសន្ទូង ខូចពោត សុទ្ធតែប៉ះពាល់ដល់ការកសាងសង្គមនិយមទាំងអស់ ។ ការដឹកជញ្ជូនយឺតយ៉ាវការផលិតម៉ាស៊ីនបូមទឹកបម្រើសហករណ៍មិនទាន់ពេលវេលា ។ល។ ទាំងអស់ អ្វីទាំងអស់ សុទ្ធតែទាក់ទងនឹងកិច្ចការកសាងសង្គមនិយមរបស់យើងជាក់ស្តែង ។

យើងចង់ល្បឿន ចង់លោតផ្លោះ មហាលោតផ្លោះ តែក្នុងកិច្ចដំណើរការ បើគុណវិបត្តិច្រើនជាងគុណសម្បត្តិ មុខជាមិនបានល្បឿនទេ ។

ដូច្នេះ ថ្នាក់ដឹកនាំពីលើទៅក្រោម ពីក្រោមឡើងលើ ត្រូវឯកភាពគ្នាខាងទស្សនៈ គោលជំហរត្រួតពិនិត្យ តាមដានការអនុវត្តផែនការឲ្យផ្លូងមួយ ដើម្បីឯកភាពគ្នាខាងរបៀបរបបដឹកនាំធ្វើការងារ ដូចជារបៀបចុះទៅមូលដ្ឋាន របៀបរាយការណ៍ របៀបប្រជុំ របៀបសន្និបាត ។ល។ ដើម្បីជំរុញកិច្ចការអនុវត្តផែនការឲ្យបានល្អ មានគុណសម្បត្តិជាអតិបរមា ហើយបន្ថយគុណវិបត្តិឲ្យនៅតិចបំផុត ។ ការតាមដានត្រួតពិនិត្យ ការអនុវត្តផែនការ ធានាអះអាងបានល្អ ដល់លាក់ការណ៍ដឹកនាំតាមរបបសមូហភាព ដឹកនាំតាមប្រជាធិបតេយ្យប្រមូលផ្តុំ បុគ្គលទទួលខុសត្រូវដោយឡែក ។

### ៥) សាខាបក្សត្រូវជាប់ស្អិតក្នុងចលនាប្រយុទ្ធអនុវត្តផែនការ

ជាប់ស្អិតក្នុងចលនាប្រយុទ្ធអនុវត្តផែនការនេះ គឺសាខាបក្សត្រូវជាប់ស្អិត ក្តាប់ខាងទស្សនៈគោលជំហរសតិអារម្មណ៍របស់មហាជនក្នុងមូលដ្ឋានខ្លួនជាសំខាន់ ដើម្បីដោះស្រាយសតិអារម្មណ៍ខុសឆ្គង ជំរុញសតិអារម្មណ៍សកម្មប្រយុទ្ធឲ្យកាន់តែសកម្មប្រយុទ្ធខ្លាំងថែមទៀត ។

ក្នុងការអនុវត្តផែនការកសាងសង្គមនិយមរបស់បក្សអាចមានទស្សនៈគោលជំហរ សតិអារម្មណ៍បីប្រភេទៈ

**១)** ឈរលើគោលជំហរ ទស្សនៈ សតិអារម្មណ៍របស់ចក្រពត្តិ វណ្ណៈសក្តិភូមិ នាយទុន ដើម្បីពិនិត្យវាយតម្លៃ ។ ជួនមានជាប្រតិកម្មប្រឆាំង ។ ជួនមិនពេញចិត្ត ទុកក្នុងចិត្តមិននិយាយ ។ សមាសភាពនេះ មានចំនួនតិចណាស់ ហើយអាចមានសមាសភាពជាខ្លាំងនៅក្នុងប្រភេទទី១នេះ ដើម្បីបំផុសពាក្យចចាមអារ៉ាមបំផ្លាញ រារាំងការអនុវត្តផែនការរបស់បក្ស ។

**២)** ឈរលើគោលជំហរ ទស្សនៈ សតិអារម្មណ៍នៃវណ្ណៈអនុធន វណ្ណៈកសិករកណ្ដាល ពិនិត្យវាយតម្លៃផែនការបក្ស ។ ប្រភេទនេះ ពេលស្រួលសកម្ម ។ ពេលលំបាករាថយ ។ ជឿខ្លះមិនជឿខ្លះ ហើយជួនកាលអាចទទួលឥទ្ធិពលពីសមាសភាពប្រភេទទី១ ទៀតផង បើកាលណាមានការលំបាក ។

**៣)** ឈរលើគោលជំហរកម្មករ កសិករក្រ កណ្ដាលក្រោម ពិនិត្យវាយតម្លៃផែនការបក្ស ។ ប្រភេទនេះ សកម្មប្រយុទ្ធខ្លាំងក្លារីករាយ ជឿជាក់ ។ ជាកម្លាំងសំខាន់ក្នុងការអនុវត្តផែនការ ។

ដូច្នេះ សាខាបក្ស ត្រូវជំរុញឲ្យខ្លាំង ការផ្សារឃោសនា អប់រំចាត់តាំង បំផុសចលនាក្នុងកម្មករ កសិករក្រ និងកសិករកណ្ដាលថ្នាក់ក្រោមឲ្យខ្លាំងក្លា ។ ខិតខំពង្រឹងពង្រីកអង្គការស្នូល ដើម្បីជាកម្លាំងជួយដឹកនាំចលនា ។ ព្រមជាមួយនេះ យកចិត្តទុកដាក់អប់រំឃោសនាជំរះសតិអារម្មណ៍ប្រភេទទី២ ឲ្យយល់ហេតុយល់ផល ឲ្យឃើញអនាគតនៃការកសាងប្រទេសជាតិ ។ ចំពោះពួកប្រភេទទី១ សមាសភាពណាដែលមិនមែនជាពួកប្រតិកិរិយាផុតលេខ បំផ្លាញកិច្ចការកសាងសង្គមនិយមទេ ត្រូវស៊ិតស្មាញអប់រំ កសាងឲ្យគេភ្ញាក់រលឹកចូលរួមអនុវត្តផែនការកសាងសង្គមនិយមរបស់បក្ស ។

## ៦) ការពារភោគចក្រ ការពារសហករណ៍ឲ្យបានល្អ

ត្រូវយកចិត្តទុកដាក់បំផុសគោលជំហរ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ ដើម្បីការពារទ្រព្យសម្បត្តិរបស់រោងចក្រ ការពារមធ្យោបាយបង្កបង្កើនផល ភោគផលរបស់សហករណ៍ឲ្យបានល្អជាអតិបរមា ។ ឈរលើគោលជំហរស្នេហាជាតិ ស្នេហាវណ្ណៈ បំផុសនូវកំហឹងចំពោះខ្មាំងសត្រូវ ដែលវាមានបំណងបំផ្លាញកិច្ចការកសាងសង្គមនិយមរបស់យើង ហើយមានវិធានការកម្ចាត់វាឲ្យទាន់ពេកវេលា ដើម្បីការពាររោងចក្រ ការពារសហករណ៍ការពារផែនការកសាងសង្គមនិយមរបស់បក្សក្នុងរយៈកាលយូរឆ្នាំ ។

បក្សគ្រប់ថ្នាក់ ត្រូវក្ដាប់គោលជំហរណែនាំជាមូលដ្ឋានដើម្បីអនុវត្តផែនការកសាងរបស់បក្សរយៈពេលយូរឲ្យបានសម្រេចគឺៈ

១) ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាខ្លួនដោយខ្លួនឯង ។

២) ស្នេហាជាតិនិយមបដិវត្តន៍ កិត្តិយសបដិវត្តន៍ចំពោះជាតិខ្លួន បដិវត្តន៍ខ្លួន ប្រជាជនខ្លួន បក្សខ្លួន និងមោទកភាពបដិវត្តន៍ចំពោះជាតិខ្លួន បដិវត្តន៍ខ្លួន ប្រជាជនខ្លួន បក្សខ្លួន ។

៣) ជំនឿជឿជាក់លើបក្ស បដិវត្តន៍ ប្រជាជនកម្មករ កសិករ សមូហភាព និងកងទ័ពបដិវត្តន៍ខ្លួន ។

៤) បំផុសមហាចលនាបដិវត្តន៍របស់មហាជន តាមល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ។ **ឆេង ម៉េង**



កសិករនៅតាមសហករណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នាំគ្នាលើកទំនប់

# ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែងៈ តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម

***(តពីលេខមុន)***

***ជំពូក៣***

***អន្លង់វែងស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម***

***មេដឹកនាំខ្មែរក្រហមនៅតំបន់អន្លង់វែង***

*នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) អន្លង់វែង ស្ថិតនៅក្រោមរបបគ្រប់គ្រងមួយប្រកបដោយភាពប្រឬកប្របល់ ដោយសារតែការធ្វើបន្សុទ្ធកម្ម ការចាប់ខ្លួន និងភាពចលាចលផ្នែកនយោបាយ ដែលបានគ្របដណ្តប់លើតំបន់នេះ ។ នៅក្នុងអំឡុងពេលនៃសង្រ្គាមស៊ីវិល (១៩៧០-១៩៧៥) អន្លង់វែងស្ថិត នៅក្រោមការគ្រប់គ្រងរបស់តំបន់សៀមរាប-ឧត្តរមានជ័យ ដែលត្រូវបានស្គាល់ថា ជាតំបន់៣៥របស់ខ្មែរក្រហម ។ ស្រុកអន្លង់វែង ត្រូវបានបែងចែកជា៤ឃុំ ដែលរួមមានឃុំអន្លង់វែង លំទង ត្រពាំងតាវ និងថ្លាវ ។ ឃុំទាំងបួននេះត្រូវបានបែងចែកបន្ត ទៀតទៅជាសហករណ៍ដែលប្រជាជននៅអន្លង់វែងត្រូវរស់នៅ និងបំពេញការងារ ។*

*ដូចតំបន់ដទៃទៀតនៅទូទាំងប្រទេសកម្ពុជាដែរ ការចាប់ខ្លួន បន្សុទ្ធកម្ម និងការសម្លាប់តែងតែកើតឡើងជាញឹកញាប់នៅអន្លង់វែង ។ ទោះបីជាថ្នាក់ដឹកនាំខ្មែរក្រហមភាគច្រើន នៅអន្លង់វែងគឺជាគោលដៅនៃបន្សុទ្ធកម្ម និងការសម្លាប់ក៏ដោយ ក៏មេដឹកនាំទាំងនេះបានអនុវត្តទង្វើដូចគ្នានេះទៅលើប្រជាជនរបស់ខ្លួន ។ ទីស្នាក់ការធំរបស់ខ្មែរក្រហមនៅអន្លង់វែង មានទីតាំងស្ថិតនៅភូមិរំចេក ឃុំលំទង ។ សមមិត្ត រ៉ុង ដែលជាកម្មាភិបាលមកពីខេត្តកំពង់ចាមគឺជាលេខាស្រុកអន្លង់វែងពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៧ ។ រ៉ុង ត្រូវបាន*



*ពិធីរៀបការរបស់ប្រជាជននៅតំបន់អន្លង់វែង កាលពីទសវត្សរ៍៨០ ក្រោមការគ្រប់គ្រងរបស់ តាម៉ុក*

ចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងនៅស្រុកសំរោង ខេត្តឧត្តរមានជ័យ ។ សមមិត្ត ទុយ បានឡើងជាលេខាស្រុកអន្លង់វែងជំនួស រ៉ុង ។ ប៉ុន្តែ បន្ទាប់ពីឡើងជាលេខាបានរយៈពេល បីខែ ទុយ បានបាត់ខ្លួន ។ វ៉ន ដែលជាកម្មាភិបាលមកពីភូមិភាគនិរតី បានក្លាយជាមេដឹកនាំទីបី នៅអន្លង់វែង ។ ប្រជាជននៅអន្លង់វែងនិយាយថា វ៉ន និងអនុលេខា របស់ខ្លួនឈ្មោះ តៅ បានចាប់ខ្លួន និងសម្លាប់ប្រធានសហករណ៍ អស់ជាច្រើនរូប ។ ដើម្បីការពារព្រំដែន ខ្មែរក្រហមបានដាក់កង វរសេនាតូចមួយកងឲ្យប្រចាំការនៅស្រុកអន្លង់វែង ដែលទទួល ខុសត្រូវយាមកាម និងការពារព្រំដែនជាមួយប្រទេសថៃ ។

កងវរសេនាតូចនេះដឹកនាំដោយ សមមិត្ត កៃ ជាប្រធាន, សមមិត្តថេន ជាអនុប្រធាន និងសមមិត្ត ជុំ ជាសមាជិកទីបី ។ កងទ័ពនៅក្នុងកងវរសេនាតូចនេះ បានទទួលការហ្វឹកហាត់ ចំនួនបីខែ មុននឹងត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅតាមព្រំដែន ដែលនៅ ទីនោះជម្លោះជាមួយថៃបានកើតឡើងជារឿយៗ ។ កងទ័ពត្រូវ បានបញ្ជាឲ្យយាមព្រំដែនដីកដីដាំចម្រូង និងការពារលទ្ធភាពនៃ ការវាយប្រហារពីសំណាក់ក្រុមខ្មែរស (ខ្មែរសសំដៅទៅលើកង ទ័ព ដែលនៅសេសសល់របស់ លន់ នល់) ។

ជីវិតជាកងទ័ពជួបការលំបាក ប៉ុន្តែ នៅតែស្ថិតនៅក្នុង ជីវភាពល្អប្រសើរជាងប្រជាជនភាគច្រើន ។ កងទ័ពដែលប្រចាំការ នៅតាមបណ្តោយព្រំដែន មិនមានអាហារហូបចុកគ្រប់គ្រាន់ទេ ។ កងទ័ពទាំងអស់នោះត្រូវជីកដំឡូងព្រៃ និងក្តួចយកមកបរិភោគ បន្ថែម ទោះបីជាមេដឹកនាំផ្គត់ផ្គង់ស្រូវរៀងរាល់ពីរសប្តាហ៍ម្តងក៏ ដោយ ។ ជាទូទៅអង្គភាព នីមួយៗត្រូវតែពឹងផ្អែកលើខ្លួនឯងដើម្បី រស់ ហើយកងទ័ពត្រូវបានលើកទឹកចិត្តឲ្យទៅបរបាញ់សត្វព្រៃ និង ស្វែងរកអាហារដោយខ្លួនឯង ។ ដោយសារអន្លង់វែងគ្របដណ្តប់ ទៅដោយព្រៃ តំបន់នេះសំបូរសត្វព្រៃណាស់ (ដូចជាសត្វខ្លា) កងទ័ពខ្មែរក្រហមមួយចំនួន បានក្លាយទៅជាអ្នកប្រមាញ់សត្វព្រៃ យ៉ាងស្ទាត់ជំនាញ ។

## ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតំបន់អន្លង់វែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ប្រជាជនត្រូវបានអនុញ្ញាត ឲ្យរស់នៅ និងហូបអាហារ នៅតាមផ្ទះរៀងៗខ្លួន ។ ប៉ុន្តែ នៅពេល ដែលខ្មែរក្រហមទទួលបានអំណាចកាន់តែច្រើន ជីវភាពរស់នៅ ប្រចាំថ្ងៃរបស់ប្រជាជនបានផ្លាស់ប្តូរបន្តិចម្តងៗពីជីវិតគ្រួសារ ការធ្វើស្រែចម្ការ និងការរស់នៅក្នុងសហគមន៍ ទៅជាជីវិតដែល គ្របដណ្តប់ដោយការរស់នៅជាលក្ខណៈសមូហភាពនៅក្នុងសហ ករណ៍ ។ បន្ទាប់ពីឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហម បានឲ្យប្រជាជន ប្រគល់សម្ភារផ្ទះបាយរបស់ខ្លួនទៅឲ្យសហករណ៍សម្រាប់ការប្រើ ប្រាស់រួម ។ ជីវិតរស់នៅរបស់ប្រជាជនចាប់ផ្តើមជួបការលំបាក កាន់តែធ្ងន់ទៅៗ នៅពេល ដែលប្រជាជនត្រូវបានតម្រូវឲ្យហូបរួម ហើយពេលវេលាសម្រាប់គ្រួសារត្រូវបានចំណាយទៅលើការងារ ពលកម្មតាមវាលស្រែ ។ នៅក្នុងការរស់នៅជាសហករណ៍ ប្រជាជន ត្រូវធ្វើការច្រើនម៉ោង និងទទួលរងការធ្វើទុក្ខបុកម្នេញ ។ ប្រជាជន ត្រូវធ្វើការពីព្រលឹមទល់ព្រលប់ ហើយពេលខ្លះត្រូវធ្វើការរហូត ដល់ពាក់កណ្តាលយប់ ។ អ្វីៗទាំងអស់ រួមទាំងទម្លាប់ការងារស្រែ ចម្ការប្រចាំថ្ងៃផង ត្រូវបានកំណត់ដោយខ្មែរក្រហម ។

ជីវិតមានការលំបាកហើយប្រជាជនមិនមានពេលវេលា ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារនោះទេ ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើ ការពីម៉ោង៦ដល់ម៉ោង១១ព្រឹក បន្ទាប់មកត្រូវបានអនុញ្ញាតឲ្យ សម្រាកមួយភ្លែត ។ នៅម៉ោង១រសៀល ប្រជាជនទាំងអស់ត្រូវ ត្រឡប់ទៅកាន់ការដ្ឋានការងារវិញរហូតដល់ម៉ោង៥ល្ងាច ។ មនុស្សគ្រប់រូបមានការនឿយហត់យ៉ាងខ្លាំង ហើយទន្ទឹងរង់ចាំស្នូរ គោះជួង ដែលជាសញ្ញាប្រកាសថា ការងារនៅថ្ងៃនោះ បានបញ្ចប់ ហើយ ។ ទោះបីជាធ្វើការច្រើនម៉ោងក្នុងមួយថ្ងៃយ៉ាងណាក៏ដោយ ក៏នៅពេលខ្លះ ខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើការរហូតដល់យប់ ជ្រៅបន្ថែមទៀត ដែលជួនកាលរហូតដល់ម៉ោង១០យប់ ។

ក្នុងគោលបំណងពង្រឹងខ្សែសង្វាក់ការងារ ខ្មែរក្រហមបាន បែងចែកប្រជាជនឲ្យទៅជាកងផ្សេងៗគ្នាទៅតាមវ័យ និងភេទ ។ កងទាំងនោះរួមមាន កងចល័ត កងកុមារ កងស្ត្រី និងកងដឹកជញ្ជូន ។ ប្រជាជននៅក្នុងកងទាំងនោះត្រូវប្រឹងប្រែងធ្វើការងារ មិនថាឈឺ ឬអស់កម្លាំងនោះទេ ។ ប្រជាជនទាំងឡាយណាដែលបដិសេធ ឬ មិនអាចបំពេញការងារ បាននឹងត្រូវទទួលទារុណកម្ម ឬបាត់ខ្លួននៅ ក្នុងករណីមួយចំនួន ។

## ជីវិតរស់នៅក្នុងសហករណ៍

មិនខុសពីតំបន់ដទៃទៀតនៃប្រទេសកម្ពុជា ភូមិជាច្រើននៅតំបន់អន្លង់វែងត្រូវបានប្រែក្លាយឲ្យទៅជាសហករណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាយើងអាចសន្មតថា ជីវិតរបស់ប្រជាជន ប្រហែលជាមិនខុសគ្នាខ្លាំងពេកទេ យ៉ាងណាក៏ដោយក៏ពីសហករណ៍មួយទៅសហករណ៍មួយទៀតនៅក្នុងតំបន់នេះ យើងអាចនឹងមានការភាន់ច្រឡំដោយសារតែស្ថានភាពនៅក្នុងសហករណ៍នីមួយៗអាចមានស្ថានភាពខុសគ្នាខ្លាំង អាស្រ័យទៅលើប្រធានសហករណ៍នីមួយៗ និងការងាររដ្ឋបាលរបស់កម្មាភិបាលខ្មែរក្រហមនៅតំបន់នោះ ។ ការសិក្សាស្រាវជ្រាវរបស់យើងមិនបានពិនិត្យមើលឲ្យស៊ីជម្រៅទៅលើស្ថានភាពជាក់ស្តែងនៅក្នុងសហករណ៍នីមួយៗទេ ។ ទោះជាយ៉ាងនេះក្តី ក្នុងគោលបំណងផ្តល់ឲ្យអ្នកអានអំពីទិដ្ឋភាពទូទៅមួយនៃជីវិតរស់នៅក្នុងសហករណ៍យើងបានសង្ខេបអំពីជីវិតរស់នៅក្នុងសហករណ៍មួយដែលមានឈ្មោះថា សហករណ៍តាដេវ ។

តាដេវ គឺជាឈ្មោះភូមិមួយនៅក្នុងឃុំត្រពាំងតាវ ដែលជាភូមិចាស់មួយរបស់ឃុំរនាមនៃស្រុកប្រាសាទវៀង ។ ភូមិនេះមានប្រជាជនរស់នៅប្រហែល២៥គ្រួសារនៅក្នុងរបបរបស់សម្តេចព្រះនរោត្តម សីហនុ ។ ភូមិនេះមិនមានរចនាសម្ព័ន្ធសង្គមនោះទេ ហើយមន្ត្រីរដ្ឋាភិបាលកម្រចុះមកត្រួតពិនិត្យភូមិដាច់ស្រយាលមួយនេះណាស់ ។

របាយការណ៍មួយចំនួនបានលើកឡើងថា ប្រជាជនជាច្រើនមកពីភូមិត្រពាំងតាវ គោកក្តាន់ និងភូមិផ្គាំរមាស ត្រូវបានប្រមូលឲ្យមករស់នៅក្នុងសហករណ៍តាដេវ ដែលមានសមមិត្ត ម៉ុល ជាប្រធានសហករណ៍ និងសមាជិកមួយចំនួនទៀត ដែលរួមមាន សាក់, ជឿម និង ឯក ។ កម្មាភិបាលទាំងអស់នេះត្រូវបានស្គាល់ថាជាមេដឹកនាំកាចសាហាវដែលឲ្យប្រជាជនហូបតែបបររាវ ។ ទោះជាយ៉ាងនេះក្តី ក្រុមគ្រួសាររបស់កម្មាភិបាលខ្មែរ ក្រហមភាគច្រើនមានបាយហូប ។ ស៊ីន ហួង បានរំឭកអំពីជីវិត របស់គាត់នៅក្នុងសហករណ៍ តាដេវ ដូចតទៅ ៖

យើងត្រូវបានបំបែកឲ្យធ្វើការងារផ្សេងគ្នា ។ ឪពុករបស់ខ្ញុំធ្វើការនៅក្នុងរោងម៉ាស៊ីនកិនស្រូវ ។ ខ្ញុំទៅឃ្វាលគោ ។ ម្តាយរបស់ខ្ញុំទៅធ្វើការងារស្រែចម្ការ ។ ប្អូនប្រុសរបស់ខ្ញុំដើរកាត់ស្មៅសម្រាប់ធ្វើជី ។ បងប្រុសរបស់ខ្ញុំទៅធ្វើការនៅរោងម៉ាស៊ីនកិនស្រូវសហករណ៍ជាមួយឪពុករបស់ខ្ញុំ ។ យើងធ្វើការពីព្រលឹមទល់ព្រលប់ និងសម្រាកនៅពេលហូបអាហារថ្ងៃត្រង់ ។ យើងទទួលបានបបរមួយចានតូចពីរពេលក្នុងមួយថ្ងៃ ។ ដើម្បីបំពេញក្រពះ យើងបានដើរបេះត្រកួនមកហូបជាមួយអំបិល ។

ដូចភូមិផ្សេងៗទៀតនៅក្នុងតំបន់នេះដែរ ការរស់នៅក្នុងភូមិតាដេវ ត្រូវបានបង្កើតឡើងជារបៀបសហករណ៍ ។ ទោះជាយ៉ាងនេះក្តីគ្រួសារជាច្រើនបន្តរស់នៅក្នុងភូមិរៀងៗខ្លួន (ប៉ុយ៉ាងហោចណាស់ រស់នៅក្នុងរង្វង់នៃបរិវេណភូមិរបស់ខ្លួន) រហូតដល់ឆ្នាំ ១៩៧៧ ។ នៅឆ្នាំ១៩៧៧ ភូមិទាំងអស់នៅក្នុងតំបន់អន្លង់វែងគ្មានមនុស្សរស់នៅ ។ អ្នកភូមិត្រូវបានជម្លៀសទៅកាន់ស្រុកក្រឡាញ់ ក្នុងខេត្តសៀមរាប ។

**កុមារ**



ក្រុមគ្រួសារប្រជាជននៅតំបន់អន្លង់វែង កាលពីទសវត្សរ៍៨០

យោងតាមបទសម្ភាសន៍ជាមួយប្រជាជនដែលរស់នៅតំបន់អន្លង់វែង កុមារដែលរស់នៅតំបន់នេះក្នុងរយៈកាលនៃរបបខ្មែរក្រហម ត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្លួនអស់រយៈពេលយ៉ាងយូរ ។ ក្មេងប្រុសស្រីត្រូវបានដាក់ឲ្យរស់នៅដាច់ដោយឡែកពីគ្នា ។ មុត សៅ ដែលជាអតីតគ្រូបង្រៀន គឺជាប្រធានកងកុមារ ។ កុមារត្រូវបានបញ្ជាឲ្យដើរកាត់ស្មៅ និងចិញ្ច្រាំធ្វើជី ។ ជាទូទៅ កុមារទាំងនោះត្រូវបានតម្រូវឲ្យធ្វើការងារធ្ងន់ ដូចជា ជីកដី និងលើកភ្លឺស្រែ ។ កុមារជាច្រើនស្ទើរតែពុំមានកម្លាំងគ្រប់គ្រាន់ ដើម្បីលើកចបកាប់ដីនោះទេ ។

ដូចប្រជាជនកម្ពុជាភាគច្រើន ដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជីវិតរបស់កុមារហាក់ដូចជាកំពុងស្ថិតនៅក្នុងល្បោនដ៏ចម្លែកមួយ ។ កុមារត្រូវបានប្រើដូចជាគោក្របី ឲ្យធ្វើស្រែ ជីកដី និងធ្វើការងារផ្សេងៗទៀត ដូចជាឪពុកម្ដាយរបស់ខ្លួនដែរ ។ ភាពសប្បាយរីករាយបែបយុវវ័យបានក្លាយទៅជាការចងចាំមួយដែលស្ថិតនៅសែនឆ្ងាយ ។ ចំណែកឯកុមារភាពដែលគ្មានទោសពៃរ៍ ប្រែជាទទួលរងនូវសោកនាដកម្មដែលគួរឲ្យខ្លាច និងរួមរឹតទៅដោយជំងឺ និងការស្លាប់ ។ អគ្គភាពកុមាររួមមានកុមារពី៣០០ទៅ៤០០នាក់ ។ កុមារទាំងនេះរស់នៅ និងហូបចុករួមគ្នា ។ បន្ថែមពីលើការងារដែលប្រើប្រាស់កម្លាំងពលកម្មជារៀងរាល់ថ្ងៃ កុមារទាំងនោះត្រូវបានតម្រូវឲ្យរៀនសូត្រ មនោគមន៍វិជ្ជា និងអក្សរបន្តិចបន្តួច ។ កុមារទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ នៅម៉ោង១១ព្រឹក និងម៉ោង៥ល្ងាច ។ កុមារម្នាក់ៗទទួលបានបបរមួយកូនចានតូចក្នុងមួយពេល ។

## ការចាប់ខ្លួន និងការសម្លាប់

ការចាប់ខ្លួន និងការសម្លាប់គឺជាដំណើរការជាទូទៅ ហើយជីវិតរស់នៅប្រចាំថ្ងៃ ផ្សារភ្ជាប់នឹងការឃ្លាំមើលទៅលើទម្លាប់ និងការនិយាយស្ដី ។ កាយវិការសាមញ្ញ ពាក្យសម្ដី ឬទម្លាប់របស់បុគ្គលម្នាក់ អាចបង្ហាញអំពីការខ្វះការគោរពស្រលាញ់ ចំពោះរបបខ្មែរក្រហម ហើយគ្រាន់តែការសង្ស័យ ក៏គ្រប់គ្រាន់សម្រាប់ចាប់ខ្លួនអ្នកណាម្នាក់បានដែរ ។

កែ ជាប្រធានកងវរសេនាតូច និងជាប្រធានមន្ទីរសន្តិសុខនៅអន្លង់វែង ។ មន្ទីរសន្តិសុខនេះក្រោយមក បានក្លាយជាកន្លែងដ៏គួរឲ្យភ័យខ្លាចមួយសម្រាប់ចាប់ខ្លួនមនុស្សទាំងឡាយណាដែលទទួលការសង្ស័យ ។ ខ្មែរក្រហមបានស្វែងរកជនទាំងឡាយណា ដែលជាប់ទាក់ទងជាមួយរបបរបស់សម្ដេចព្រះនរោត្តមសីហនុ និងរបបលន់ នល់ ។ ប្រសិនបើជនណាម្នាក់ត្រូវបានរកឃើញថា មានជាប់ពាក់ព័ន្ធនឹងរបបមុន ជននោះនឹងត្រូវបញ្ជូនទៅកាន់ភូមិរំចេក ដើម្បីធ្វើការតាមដាន និងសម្លាប់ ។ ជាងនេះទៅទៀត ខ្មែរក្រហមបានចាប់ និងសម្លាប់ចោលជនទាំងឡាយណា ដែលរត់គេចខ្លួនទៅប្រទេសថៃ ។

សាក្សីមួយរូបបានរំឭកថា គាត់បានឃើញ កែ ចាប់ខ្លួនមនុស្ស៥នាក់ ដែលបានព្យាយាមរត់គេចទៅប្រទេសថៃ ។ គាត់បានរៀបរាប់ថាៈ

*ខ្ញុំបានឃើញកងទ័ពចាប់មនុស្ស៥នាក់ដែលបានព្យាយាមរត់ទៅប្រទេសថៃ ។ តា កែ បានមកដល់ជាមួយអង្គរក្សរបស់គាត់ចំនួន៤ ឬ៥នាក់ ។ គាត់បានវាយមនុស្សដែលរត់គេចខ្លួនទាំង៥នាក់នោះ ។ មនុស្សម្នាក់ៗ ទទួលរងយ៉ាងហោចណាស់ម្នាក់៣០រំពាត់ ។ តាកែបានសួរអ្នកទាំងនោះថា មកពីណា និងចង់ទៅណា ។ ពួកគេបាននិយាយថា ពួកគេមកពីខេត្តកំពង់ធំ និងសៀមរាប និងមានបំណងទៅប្រទេសថៃ ។ តា កែ បានវាយប្រជាជនទាំងនោះរហូតដល់បែកខ្នងហូរឈាម ។ បន្ទាប់មក អ្នកទាំង៥នាក់នោះត្រូវបានខ្មែរក្រហមនាំយកទៅបាត់ ។ ខ្ញុំមិនជឿថា អ្នកទាំង៥នាក់នោះ អាចនៅមានជីវិតនោះទេ ។*

ប្រជាជនជាច្រើនមកពីខេត្តផ្សេងៗទៀត ត្រូវបានជម្លៀសទៅអន្លង់វែងដែរ ប៉ុន្តែប្រជាជនទាំងនេះ មិនត្រូវបានកម្មាភិបាលខ្មែរក្រហមជឿទុកចិត្តនោះទេ ។ ប្រជាជនទាំងនេះក៏មិនមានសាច់ញាតិ ឬមិត្តភក្តិ សម្រាប់ពឹងអាស្រ័យបានដែរ ហើយជាញឹកញាយត្រូវបានខ្មែរក្រហមសម្លាប់ដោយសារការសង្ស័យ ។ មន្ទីរសន្តិសុខរបស់ខ្មែរក្រហម ត្រូវបានបង្កើតឡើងនៅចំទីតាំង ដែលជាអនុវិទ្យាល័យហ៊ុន សែន នាពេលបច្ចុប្បន្ន ។ គុក នោះត្រូវបានសង់អំពីឈើដំបូលប្រក់ស្បូវដែលមានទទឹង៥ម៉ែត្រ និងបណ្ដោយ៧ម៉ែត្រ ។ អ្នកទោសត្រូវបានបង្ខំឲ្យដេកជាជួរ ដោយជើងរបស់អ្នកទោសទាំងនោះត្រូវបានដាក់ខ្នោះជើងដែលធ្វើអំពីឈើ ។ របៀបឃុំឃាំងអ្នកទោសនៅទីនោះ ស្រដៀងនឹងរបៀបឃុំឃាំងអ្នកទោសនៅមន្ទីរស-២១ នៅភ្នំពេញ ។ ជាទូទៅអ្នកទោសត្រូវបានឃុំខ្លួនរយៈពេលមួយសប្ដាហ៍មុននឹងត្រូវបានយកទៅសម្លាប់នៅក្នុងទីតាំងសម្លាប់ជាច្រើនកន្លែង ដែលទីតាំងមួយស្ថិតនៅក្បែរវត្តអន្លង់វែងបច្ចុប្បន្ន ។ ការសម្លាប់អ្នកទោសភាគច្រើន ត្រូវបានធ្វើឡើងនៅពេលយប់ ។

ការជម្លៀសប្រជាជនដោយបង្ខំទៅស្រុកក្រឡាញ់នៅឆ្នាំ១៩៧៧ នៅចុងឆ្នាំ១៩៧៧ វ៉ន ដែលជាប្រធានថ្មីនៃស្រុកអន្លង់វែង បានបញ្ជាឲ្យជម្លៀសប្រជាជននៅអន្លង់វែងទាំងអស់ឲ្យទៅរស់នៅតាមសហករណ៍ នៅក្នុងឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ប្រជាជនអន្លង់វែងមួយចំនួនត្រូវបានបញ្ជូនទៅស្រុកវ៉ារិន្ទ ស្រីស្នំសំរោង និងចុងកាល់ ។ ចាប់ពីចុងឆ្នាំ១៩៧៧ ដល់

*ដើមឆ្នាំ១៩៧៩ តំបន់អន្លង់វែង បានក្លាយទៅជាមូលដ្ឋានកងទ័ពរបស់ខ្មែរក្រហម ។*

*យឹម ឡាហឿ ដែលជាអតីតកងទ័ពការពារព្រំដែននៅអន្លង់វែង ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ បានរៀបរាប់អំពីបទពិសោធដ៏គួរឲ្យរន្ធត់របស់ខ្លួននៅពេលដែលគាត់ទៅសួរសុខទុក្ខគ្រួសាររបស់គាត់បន្ទាប់ពីការជម្លៀស ។ ឡាហឿ បាននិយាយថា៖*

*នៅពេលដែលខ្ញុំទៅដល់ផ្ទះ ខ្ញុំបានឃើញឆ្នាំងដាំបាយរបស់ជីដូនខ្ញុំត្រូវបានព្យួរទុកចោលដោយគ្មានអ្នកណាប្រើ ។ នៅក្នុងភូមិពោរពេញទៅដោយភាពស្ងាត់ជ្រងំ ។ ប្រជាជនទាំងអស់ត្រូវបានជម្លៀសទៅស្រុកក្រឡាញ់ ។ នៅពេលបានឃើញទិដ្ឋភាពបែបនេះ ខ្ញុំមានអារម្មណ៍អស់សង្ឃឹម ។ ខ្ញុំបានលះបង់គ្រប់បែបយ៉ាងដើម្បីបម្រើប្រទេសជាតិ ប៉ុន្តែលះបង់ដើម្បីអ្វី? ខ្ញុំបាត់បង់អ្វីៗគ្រប់យ៉ាង ។ ខ្ញុំបាត់បង់អស់នូវភាពជឿជាក់ ។ ខ្ញុំមិនដឹងថា ត្រូវធ្វើយ៉ាងម៉េចនោះទេ មានតែទទួលយកស្ថានភាពនេះ ហើយបន្តរស់នៅតទៅទៀត ។*

*ប្រជាជនធ្វើដំណើរទៅស្រុកក្រឡាញ់ដោយមធ្យោបាយផ្សេងៗគ្នា តាមរយៈរទេះគោ ដោយថ្មើរជើង និងតាមរយៈរថយន្តរបស់ខ្មែរក្រហម ។ នៅពេលទៅដល់ស្រុកក្រឡាញ់ ប្រជាជនមកពីតំបន់អន្លង់វែងត្រូវបានបែងចែកឲ្យរស់នៅតាមសហករណ៍នានា និងត្រូវបានចាត់តាំងទៅតាមកងផ្សេងៗជាមួយប្រជាជនដែលមកពីតំបន់ផ្សេង ។ មានតែកុមារតូចៗតែប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្ដាយនៅពេលយប់ ។ នៅពេលថ្ងៃកុមារត្រូវបានតម្រូវឲ្យទៅរៀន និងកាត់ស្មៅយកទៅធ្វើជីសម្រាប់ដាក់ក្នុងស្រែ ។ កុមារក៏ត្រូវបានតម្រូវឲ្យដើរប្រមូលកណ្ដាប់ស្រូវ ឬដើរដេញចាបកុំឲ្យស៊ីស្រូវ ។ ប្រជាជនត្រូវធ្វើការទាំងរដូវប្រាំង និងរដូវវស្សា និងត្រូវទៅលើកទំនប់ និងជីកប្រឡាយ ។ នៅក្បែរទំនប់ស្ពានស្រែងមានវាលពិឃាតមួយកន្លែងនៅស្រុកក្រឡាញ់ដែលមានឈ្មោះថា “ឡ ពិឃាតភ្នំទ្រង់បាត” ។*

*ជីវិតរស់នៅរបស់ប្រជាជនមានការលំបាក ។ នៅទីនោះប្រជាជនពុំមានអាហារបរិភោគគ្រប់គ្រាន់ និងត្រូវរស់នៅក្នុងភាពសង្ស័យគ្នាទៅវិញទៅមក ។ សូម្បីតែទង្វើប្រចាំថ្ងៃជាធម្មតារបស់មនុស្ស ក៏អាចបង្កទៅជាការសង្ស័យបានដែរ ។ ជាក់ស្ដែង អ្នកនៅរស់រានមានជីវិតម្នាក់បាននិយាយថា គាត់ធ្លាប់បានឃើញខ្មែរក្រហមដឹកមនុស្សយកទៅសម្លាប់ចោល ដោយសារតែបុគ្គលនោះចំណាយពេលវេលាយូរពេកក្នុងការបន្ទោរបង់ ។ ទីតាំងពិឃាតនៅស្រុកក្រឡាញ់ត្រូវបានស្គាល់ថា នៅក្បែរឡពិឃាដភ្នំទ្រង់បាត ដែលមនុស្សរាប់រយពាន់នាក់ត្រូវបានសម្លាប់ ។*

## ***សេចក្ដីបញ្ចប់***

*មុនឆ្នាំ១៩៧០ អន្លង់វែងគឺជាតំបន់ដាច់ស្រយាលមួយនៅក្នុងប្រទេសកម្ពុជា និងជាតំបន់មួយនៅក្រៅការគ្រប់គ្រងរបស់រដ្ឋទាំងផ្នែកសេដ្ឋកិច្ច និងកិច្ចការរដ្ឋបាល ។ រដ្ឋាភិបាលកណ្ដាលកម្រធ្វើដំណើរទៅកាន់តំបន់នេះណាស់ ហើយប្រជាជនរស់នៅតាមទម្លាប់ដែលធ្លាប់រស់នៅរាប់ជំនាន់មកហើយ ដោយពឹងផ្អែកលើការធ្វើស្រែចម្ការ ការជួញដូរ និងដំណាំដាំដុះនៅក្នុងភូមិ ។ នៅពេលដែលខ្មែរក្រហមចូលមកដល់តំបន់នេះ នៅដើមឆ្នាំ១៩៧០ វប្បធម៌នៅតំបន់អន្លង់វែងចាប់ផ្ដើមប្រែប្រួល ។ ប្រជាជនត្រូវបានបង្ខំឲ្យទទួលយកមនោគមន៍វិជ្ជាបដិវត្តន៍បែបថ្មីរបស់ខ្មែរក្រហមដែលមានបំណងលុបបំបាត់ចោលនូវការអនុវត្តបែបប្រពៃណី ជំនឿ និងឥរិយាបថ ។ ប្រជាជនជួបប្រទះនូវការលំបាកយ៉ាងខ្លាំង ដូចជាការរស់នៅបែបសហករណ៍ ការបង្ខំឲ្យធ្វើការងារជាទម្ងន់ ការខ្វះខាតអាហារ និងការបំបិទសិទ្ធិសេរីភាព ដែលបានបង្កជាផលលំបាកដល់បុគ្គល និងសហគមន៍ទាំងមូល ។ ការសម្លាប់ដោយគ្មានការកាត់ទោស ការផ្លាស់ប្ដូរទីលំនៅដោយបង្ខំ និងការបន្តការគំរាមកំហែងដោយជម្លោះបានបង្កនូវភាពភ័យខ្លាច និងភាពមិនប្រាកដប្រជាដល់ប្រជាជន ។ នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបង្ខំប្រជាជនទាំងអស់ ឲ្យផ្លាស់ទៅធ្វើការនៅស្រុកក្រឡាញ់ ដោយធ្វើឲ្យតំបន់អន្លង់វែងក្លាយទៅជាមូលដ្ឋានកងទ័ពរបស់ខ្មែរក្រហម ។ ទោះបីជាការផ្លាស់ប្ដូរនេះប្រហែលជាត្រូវបានរៀបចំឡើងជាយុទ្ធសាស្ត្រមួយដើម្បីប្រមូលកម្លាំងធ្វើការនៅស្រុកក្រឡាញ់ វាក៏អាចជាយុទ្ធសាស្ត្រមួយសម្រាប់ទប់ស្កាត់ប្រជាជនកុំឲ្យរត់ទៅប្រទេសថៃ ។ យោងតាមបទសម្ភាសប្រជាជនមានបំណងរត់ឆ្លងព្រំដែនទៅប្រទេសថៃ ដោយឆ្លងកាត់តាមអន្លង់វែង ប៉ុន្តែត្រូវបានខ្មែរក្រហមចាប់ខ្លួន ។ មិនមានព័ត៌មានណាមួយបង្ហាញថា មានប្រជាជនប៉ុន្មាននាក់អាចរត់គេចខ្លួនរួចនោះទេ ។*

**(តទៅលេខក្រោយ)** **គ្រីស្ទូហ្វ័រ ឌៀរីង និង ឌី ខាំបូលី**

# អតីតកាលនៅតែដក់ជាប់ក្នុងចិត្ត

អតីតកាលនៃរបបខ្មែរក្រហមតែងតែដក់ជាប់នៅក្នុងចិត្តអ្នកដែលធ្លាប់ឆ្លងកាត់របបនេះជានិច្ច ទោះបីជារឿងរ៉ាវទាំងនេះបានកន្លងផុតទៅជាច្រើនឆ្នាំក៏ដោយ ដែលក្នុងចំណោមអ្នករស់រានទាំងនោះក៏មាន អ៊ំប្រុស អាន ដែរ ។



រូបភាពផ្តិត ៖ ហេង អៀ និង អាន នៅស្រុកអន្លង់វែង

ថ្ងៃជ័យជម្នះ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលរីករាយសម្រាប់ខ្មែរក្រហម ប៉ុន្តែចំពោះ អាន ថ្ងៃនេះគឺជាថ្ងៃចាប់ផ្តើមនៃការឃ្លាតឆ្ងាយពីគ្រួសារ បងប្អូន និងញាតិមិត្ត ។ ខ្មែរក្រហមបានប្រែក្លាយទីក្រុង ទីប្រជុំជននានា ដែលធ្លាប់តែមានមនុស្សអ៊ូអរទៅទីជាទីស្ងាត់ជ្រងំ ។ អាន បានបែកពីគ្រួសារក្នុងអំឡុងពេលខ្មែរក្រហមជម្លៀសប្រជាជនលើកដំបូង ។ គាត់បានធ្វើដំណើរជាមួយ អ្នកជម្លៀសដទៃទៅកាន់ទីកន្លែងដែលគាត់មិនដែលស្គាល់ពីមុនមក ។ អាន ត្រូវដើរកាត់វាល កាត់ព្រៃយ៉ាងលំបាកអស់រយៈពេលជាច្រើនថ្ងៃ ហើយមនុស្សជាច្រើនបានស្លាប់នៅតាមផ្លូវធ្វើដំណើរ ។ អ្នកទាំងនោះ ស្លាប់ដោយសារជំងឺគ្រុនចាញ់ និងអត់អាហារ ។ ពេលធ្វើដំណើរ អាន មានស្បៀងបន្តិចបន្តួចជាប់នឹងខ្លួនប៉ុណ្ណោះ ដូច្នេះគាត់ត្រូវបេះស្លឹកឈើព្រៃហូបបន្ថែមដើម្បីចម្អែតក្រពះ ។ អាន បានធ្វើដំណើរប្រហែលពីរខែ ទើបមកដល់តំបន់មួយនៅក្បែរភ្នំដងរែក ដែលក្រោយមកទើបគាត់ដឹងថា តំបន់នេះ ជាតំបន់អន្លង់វែង ។

មកដល់អន្លង់វែង អ្នកជម្លៀសទាំងអស់ត្រូវបានអង្គការបែងចែកជាក្រុម ដែលក្នុងមួយក្រុមមានមនុស្ស១២នាក់ ។ ក្រុមរបស់ អាន មានភារកិច្ចធ្វើស្រែ និងធ្វើជីដាក់ស្រែ ។ អាន ត្រូវងើបទៅធ្វើការពីព្រលឹមរហូតដល់ម៉ោង១១ ទើបសម្រាកហូបអាហារ រួចហើយបន្តធ្វើការរហូតដល់ម៉ោង៥ល្ងាច ។ អាន បានរម្លឹកប្រាប់ថា រៀងរាល់មួយអាទិត្យម្តង អង្គការមានរបបបន្អែមឲ្យហូប ដែលភាគច្រើនគឺ ស្ករទាញ ម្នាក់មួយដុំ ។

អាន ធ្វើការនៅវាលស្រែបានមួយរយៈ អង្គការក៏បានចាត់គាត់ឲ្យចូលធ្វើយោធា និងមកឈរជើងនៅភ្នំដងរែក ។ អាន បន្តថា គាត់បានចូលធ្វើយោធា ទាំងមិនដែលបានធ្វើការហ្វឹកហាត់អ្វីឡើយ ហើយការរស់នៅលើភ្នំពិតជាលំបាកខ្លាំងណាស់ ជាពិសេសការហូបចុក ។ នៅឆ្នាំ១៩៧៨ អង្គការបានរៀបគ្រួសារឲ្យគាត់ ។ អាន បានឲ្យដឹងថា ការរៀបការនេះ មិនធ្វើតាមប្រពៃណីនោះទេ ហើយក៏មិនមានបងប្អូនញាតិមិត្តណាមកចូលរួមដែរ គឺមានតែកូនកម្លោះ កូនក្រមុំ ឡើងចាប់ដៃគ្នាប្តេជ្ញានៅចំពោះគណៈអធិបតីប៉ុណ្ណោះ ។

ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ តំបន់អន្លង់វែងនៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដែលនៅសេសសល់ ដែលប្រមូលផ្តុំកម្លាំងដើម្បីប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញ ។ ទោះបីយ៉ាងណា អាន មិនបានត្រឡប់ទៅស្រុកកំណើតវិញទេគឺគាត់សម្រេចចិត្តរស់នៅអន្លង់វែងរហូតមកដល់បច្ចុប្បន្ន ។

អាន បានរម្លឹកថា បន្ទាប់ពីតា ម៉ុក មកគ្រប់គ្រងអន្លង់វែងមានការផ្លាស់ប្តូររបបដឹកនាំថ្មី ។ ក្រោមការគ្រប់គ្រងរបស់ តាម៉ុក យោធា និងប្រជាជនបានធូរស្រាលជាងមុន ដោយ តាម៉ុក អនុញ្ញាតឲ្យមានថ្ងៃឈប់សម្រាក ថ្ងៃបុណ្យទាន ហើយ តាម៉ុក ក៏ចាប់ផ្តើមធ្វើស្ពាន មន្ទីរពេទ្យ សាលារៀន ។

អាន និងគ្រួសារបានចាប់ផ្តើមសាងជីវិតជាថ្មី បន្ទាប់ពីតំបន់អន្លង់វែងធ្វើ សមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ។ ដោយសារតែសង្គ្រាម ទើប អាន មិនបានរៀនសូត្រខ្ពង់ខ្ពស់ និងធ្វើឲ្យគាត់បែកបាក់គ្រួសារ រហូតដល់បច្ចុប្បន្ន ។ **ហេង អៀ**

# រម្លឹកអំពីអតីតកាល ជាការព្យាបាលរបួសផ្លូវចិត្ត

ជួបគ្នាដោយចៃដន្យនៅការិយាល័យផ្តល់ព័ត៌មានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ំប្រុសម្នាក់បានសួរនាំខ្ញុំយ៉ាងច្រើនថាតើសៀវភៅណាខ្លះដែលសរសេរទាក់ទងនឹងរបបខ្មែរក្រហម ។ តាមរយៈកាយវិការរបស់គាត់ ហាក់ដូចជាចង់ដឹងយ៉ាងខ្លាំងអំពីរឿងរ៉ាវដែលទាក់ទងនឹងរបបខ្មែរក្រហម ។ ជួយរកសៀវភៅជូនគាត់បណ្តើរ ខ្ញុំឆ្លៀតសួរនាំគាត់បណ្តើរអំពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម ។



ហាវ ហ៊ុង មកផ្តល់បទសម្ភាសនៅមជ្ឈមណ្ឌលឯកសាកម្ពុជា

ឆ្លើយតបមកខ្ញុំដោយភាពរួសរាយថា គាត់ឈ្មោះ ហាវ ហ៊ុង ។ នៅក្នុងរបបខ្មែរក្រហម គាត់វ័យប្រហែល១៦ឆ្នាំ ហេតុដូច្នេះ គាត់មិនសូវចងចាំព្រឹត្តិការណ៍ដែលគាត់ធ្លាប់បានជួបប្រទះទាំងស្រុងនោះទេ ។ ទោះបីជាយ៉ាងណា គាត់រៀបរាប់យ៉ាងយកចិត្តទុកដាក់នូវអ្វីដែលគាត់ចងចាំប្រាប់ខ្ញុំថា គាត់ជាអ្នកដែលមានស្រុកកំណើតនៅខេត្តក្រចេះ ។ គាត់មានបងប្អូន៦នាក់ (ប្រុស៣ ស្រី៣នាក់) ។

នៅក្នុងរបបខ្មែរក្រហម ហ៊ុង ត្រូវអង្គការចាត់ចូលក្នុងកងចល័ត ។ ការងារនៅក្នុងកងចល័តរបស់គាត់ គឺលើកទំនប់ និងជីកប្រឡាយ ។

ហ៊ុង នៅចាំបានថា ការងារនៅការដ្ឋានការងារពិតជាលំបាកណាស់ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំង ហើយផ្តល់ឲ្យវិញត្រឹមតែបបរបី-បួនវែកប៉ុណ្ណោះ ។ ព្រោះតែការហូបចុកមិនគ្រប់គ្រាន់ បានធ្វើឲ្យមនុស្សជាច្រើនស្លាប់ ដោយសារជំងឺ និងការអត់ឃ្លាន ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ហ៊ុង បានស្ម័គ្រចិត្តចូលធ្វើទាហាន ដើម្បីប្រយុទ្ធជាមួយកម្លាំងខ្មែរក្រហមដែលនៅសេសសល់ ។ ក្រោមហេតុផលដែលធ្វើឲ្យគាត់ សម្រេចចិត្តបែបនេះ គឺគាត់មិនពេញចិត្តនឹងអ្វីដែលខ្មែរក្រហមធ្វើមកលើគាត់ ក្រុមគ្រួសារគាត់ និងប្រជាជនខ្មែរទូទាំងប្រទេស ។ គាត់បន្តប្រាប់ខ្ញុំដោយទឹកមុខក្រៀមក្រំថា ខ្មែរក្រហមបានចាប់បង្ខំឲ្យបងប្រុសរបស់គាត់ធ្វើជាទាហាន ហើយក្រោយមកក៏បានស្លាប់នៅសមរភូមិ ចំណែក បងប្អូនជីដូនមួយមួយចំនួនទៀតបានស្លាប់ដោយសារជំងឺគ្មានថ្នាំព្យាបាលក្នុងអំឡុងរបបខ្មែរក្រហម ។ រឿងរ៉ាវជាច្រើនដែល ហ៊ុង បានជួបប្រទះក្នុងរបបខ្មែរក្រហមដូចជា ការសម្លាប់ ការជម្លៀសប្រជាជន ការបំបែកចេញពីក្រុមគ្រួសារ និងការធ្វើទារុណកម្ម ហើយទិដ្ឋភាពទាំងនេះនៅតែដក់នៅក្នុងចិត្តរបស់គាត់រហូតដល់បច្ចុប្បន្ន ។

ទោះបីបច្ចុប្បន្ន ហ៊ុង បានចាប់ផ្តើមជីវិតថ្មីជាមួយនឹងគ្រួសារដ៏កក់ក្តៅតូចមួយក៏ដោយ ប៉ុន្តែ ហ៊ុង មិនអាចភ្លេចនូវអ្វីដែលបានកើតឡើងចំពោះគាត់ និងគ្រួសារឡើយ ។ រហូតមកទល់ពេលនេះ គាត់នៅតែមិនយល់អំពីមេដឹកនាំខ្មែរក្រហមថា ហេតុអ្វីបានជាដឹកនាំប្រទេសធ្លាក់ក្នុងគ្រោះមហន្តរាយបែបនេះ? ។ ទោះបីជាគាត់មិនមែនជាអ្នកដែលបានរៀនសូត្រខ្ពង់ខ្ពស់ ប៉ុន្តែគាត់ពិតជាចង់ស្វែងយល់បន្ថែមអំពីរបបខ្មែរក្រហម ។ គាត់ក៏ជំរុញឲ្យអ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហម គួរតែប្រាប់នូវបទពិសោធជីវិតរបស់ខ្លួនដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមទៅក្មេងៗជំនាន់ក្រោយឲ្យបានដឹង និងស្វែងយល់ពីការពិត ។ សម្រាប់ ហ៊ុង ការរម្លឹកឡើងវិញនូវអតីតកាលដ៏ជូរចត់នេះ មិនមែនមានន័យថាយើងបន្តរស់នៅក្នុងអតីតកាលនៃការឈឺចាប់នោះទេ ប៉ុន្តែវាជាការព្យាបាលរបួសផ្លូវចិត្ត ។ **អ៊ុន សុជាទី**

# ជីវិតរបស់យាយ ម៉ក់ សោភ័ណ្ឌ ក្នុងរបបខ្មែរក្រហម

យាយ ម៉ក់ សោភ័ណ្ឌ មានអាយុ៧៨ឆ្នាំ ។ គាត់មានកូនប្រុសស្រីប្រាំមួយនាក់ ។ កូនរបស់គាត់ពីរនាក់បានស្លាប់ដោយសារជំងឺ នៅសល់កូនបួននាក់ រស់នៅខេត្តតាកែវ កំពត និងភ្នំពេញ ដោយមានមុខរបររៀងៗខ្លួន ។ កូនរបស់គាត់ខ្លះមិន បានរៀនខ្ពស់ទេ ដោយសារកើតក្នុងសម័យសង្គ្រាម ។

សព្វថ្ងៃគាត់រស់នៅជាមួយកូនស្រីពីរនាក់ នៅម្តុំសំណង់ដប់ពីរ ក្នុងទីក្រុងភ្នំពេញ ។ ដោយសារអាយុច្រើន មិនអាចធ្វើការងារធ្ងន់បាន ដូច្នេះគាត់ត្រូវការការផ្គត់ផ្គង់ពីកូន និងចៅៗវិញ ។ យាយ សោភ័ណ្ឌ ជាពុទ្ធសាសនិកមួយរូប ហើយគាត់តែងតែទៅវត្តជារៀងរាល់ថ្ងៃសីលដើម្បីបួងសួង និងសុំឲ្យកូនចៅមានសុភមង្គល ។

គាត់មានភាពរីករាយ និងមានសុភមង្គលក្នុងជីវិតនៅទីក្រុងភ្នំពេញជាមួយកូន និងចៅៗរបស់គាត់ បើប្រៀបធៀបទៅនឹងសម័យកាលដ៏ជូចត់នៅក្នុងរបបខ្មែរក្រហមដែលគាត់ត្រូវរស់ក្នុងភាពភ័យខ្លាចជារៀងរាល់ថ្ងៃ ។ គាត់មិនមានការលំបាកទេក្នុងជីវិតពីព្រោះកូនចៅរបស់គាត់យកចិត្តទុកដាក់ និងមើលថែរក្សាគាត់ ។ កាលពីដើម គាត់ជាកូនកសិករម្នាក់នៅក្នុងភូមិធាយ ឃុំវត្តអង្គ ស្រុកបន្ទាយមាស ខេត្តកំពត ។ គាត់មានបងប្អូនបីនាក់ ដោយសារតែភាពក្រីក្រក្នុងគ្រួសារ គាត់បានឈប់រៀននៅថ្នាក់ទី៤ ។ គាត់នៅចាំថា គាត់រៀបការនៅអាយុ១៥ឆ្នាំ ។ យាយ សោភ័ណ្ឌ បានបន្តថា ខ្មែរក្រហមបានចូលភូមិរបស់គាត់ក្នុងអំឡុងពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ពីប្រមុខរដ្ឋ ។ ពេលនោះគាត់នៅបន្តធ្វើការងារស្រែចម្ការជាធម្មតា និងថែរក្សាកូនៗរបស់គាត់ ។ ខ្មែរក្រហមមិនបានធ្វើបាបគ្រួសាររបស់គាត់ និងអ្នកភូមិឡើយ ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគ្រួសារគាត់ និងប្រជាជនចេញពីភូមិ ឲ្យទៅរស់នៅខេត្តព្រះសីហនុ ។ នៅអំឡុងពេលជម្លៀស គាត់ត្រូវដើរពីផ្ទះទៅចំណត់រថយន្តដែលកំពុងរង់ចាំជាស្រេច ។ គាត់បានរៀបរាប់ថា ពេលនោះខ្មែរក្រហមបានប្រាប់គាត់ថា «កន្លែងថ្មីមានរបបហូបច្រើនណាស់» ។

ប្រជាជនមួយចំនួនមិនចង់ចាកចេញពីស្រុកកំណើតរបស់ខ្លួនឡើយ ប៉ុន្តែមិនមានជម្រើស ។ ខ្មែរក្រហមបានជម្លៀសគាត់ឲ្យទៅនៅភូមិអូរយ៉ាហេង តែមិនអនុញ្ញាតឲ្យគាត់រស់នៅជុំជាមួយគ្នាឡើយ ។ ពេលជម្លៀសទៅដល់កំពង់សោមដំបូង កម្មាភិបាលខ្មែរក្រហមបានឲ្យគាត់ និងប្រជាជនហូបគ្រប់គ្រាន់ ព្រមទាំងបានធ្វើល្អចំពោះគាត់ទៀតផង ។ ប៉ុន្តែមួយរយៈក្រោយមក ខ្មែរក្រហមបានចាត់ឲ្យប្រជាជនធ្វើការកាប់គាស់ ដកស្ទូង ចំណែកគាត់ ខ្មែរក្រហមបានចាត់តាំងឲ្យធ្វើការនៅកន្លែងបុកស្រូវអង្ករ ។ ការងារនៅកន្លែងនោះ មិនសូវជាពិបាកទេសម្រាប់គាត់ ហើយថែមទាំងមានអាហារហូប គ្រប់គ្រាន់ទៀតផង ។ ពេលនោះ គាត់ឃើញមនុស្សជាច្រើនមានរូបរាងស្គមស្គាំង និងមិនមានអ្វីហូប ប៉ុន្តែគាត់មិនអាចជួយអ្នកទាំងនោះបានទេ ។

គាត់ បានរៀបរាប់ថា កូនស្រីរបស់គាត់ម្នាក់ដែលបាននៅក្នុងកងនារី ត្រូវបានខ្មែរក្រហមប្រើឲ្យកាប់ដើមទន្ទ្រានខេត្រ និងឃើញមានរូបរាងស្គមស្គាំង ។ គាត់អាណិតកូនរហូតដល់ស្រក់ទឹកភ្នែក និងបានលួចយកបាយឲ្យកូនរបស់គាត់ហូបទៀត ។ ក្រោយមក គាត់ជួបរឿងដ៏រន្ធត់ដែលមិនអាចបំភ្លេចបាន គឺពេលដែលគាត់នឹកកូនស្រីរបស់គាត់ខ្លាំងពេក គាត់បានទៅលេងកូនស្រីនៅការដ្ឋាន ។ នៅពេលនោះ មានកងទ័ពខ្មែរក្រហមបានពួនស្ទាក់ស្ទានដើម្បីវាយប្រហារកងទ័ពវៀតណាម ។ យោធាខ្មែរក្រហម បានស្រែកប្រាប់គាត់ឲ្យរត់ឆ្លងកាត់ស្ពានឲ្យឆាប់ ។ បន្ទាប់ពីគាត់ឆ្លងផុត សំឡេងបំផ្ទុះលាន់ឮរំពង ហើយកងទ័ពវៀតណាមពីរនាក់បានស្លាប់ ។

សោភ័ណ្ឌ នៅចាំថា នៅក្នុងសម័យនោះឪពុករបស់គាត់ត្រូវបានខ្មែរក្រហមសម្លាប់ រួមជាមួយប្តីរបស់គាត់ដោយត្រូវបានចោទប្រកាន់ថា ជាគ្រូបង្រៀន ។ ក្រោយមក ខ្មែរក្រហមចាប់ផ្តើមស៊ើបសួរប្រវត្តិរូបរបស់គាត់បន្តទៀត ធ្វើឲ្យគាត់ភ័យខ្លាចយ៉ាងខ្លាំង ។ ដូច្នេះគាត់ក៏កុហកថា ប្តីរបស់គាត់គឺជាអ្នកបើកឡានតាក់ស៊ី ទើបគាត់នៅមានជីវិតរហូតមកដល់សព្វថ្ងៃ ។ **អ៊ិន ខណ្ឌារ៉ា**

# ជំនឿសាសនាត្រូវបានខ្មែរក្រហមលុបបំបាត់

ខ្ញុំបានដឹងរឿងរ៉ាវពីរបបខ្មែរក្រហម តាមរយៈចាស់ៗដែលរស់នៅក្នុងភូមិជាមួយគ្នា តាមរយៈឪពុកម្ដាយរបស់ខ្ញុំនិយាយប្រាប់ និងតាមរយៈការអានឯកសារផ្សេងៗដែលទាក់ទងទៅនឹងរឿងរ៉ាវដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហម ។ ទន្ទឹមនេះ ជនរងគ្រោះដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម ក៏តែងតែរៀបរាប់ពីផលវិបាករបស់គាត់ ដែលបានរស់នៅក្នុងរបបខ្មែរក្រហម ហើយអ្វីដែលគាត់សង្កត់ធ្ងន់នោះ គឺការបង្ខំឲ្យធ្វើការហួសកម្លាំង ការផ្ដល់របបអាហារ ការបំបិទសិទ្ធិសេរីភាព មិនឲ្យជជែកពិភាក្សា មិនឲ្យមានការគោរពបូជាដល់សាសនាជាដើម ។ ទាំងនេះគឺជាការគាបសង្កត់ខាងផ្លូវចិត្ត និងបានធ្វើឲ្យប្រជាជនមិនហ៊ាននិយាយស្ដីឬរៀបរាប់រឿងហេតុដែលបានកើតឡើងក្នុងរបបខ្មែរក្រហមប្រាប់ដល់ក្មេងជំនាន់ក្រោយឲ្យបានដឹងឡើយ ។ ភាពភ័យខ្លាចបានដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់ រហូតក្លាយទៅជាជំងឺបាក់ស្បាត ។

អ៊ំប្រុស ឌឹម បុត្រ មានអាយុ៦២ឆ្នាំ សព្វថ្ងៃរស់នៅភូមិទួលគ្រោះ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ បានមានប្រសាសន៍ថា គាត់មានស្រុកកំណើតនៅខេត្តក្រចេះ និងមានបងប្អូនប្រុសបីនាក់ (ប្អូនរបស់គាត់ទាំងពីរត្រូវបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម) ។ អ៊ំបានចូលបម្រើការជាទាហាន នៅពេលដែលគាត់មានអាយុ២០ឆ្នាំ ។ មុនពេលគាត់មកដល់ស្រុកអន្លង់វែង គាត់ត្រូវធ្វើដំណើរចល័តតាមព្រំដែនតាំងពីខេត្តក្រចេះ រហូតមកដល់មុំបីឬតំបន់១០០១ នៅក្នុងឆ្នាំ១៩៨១ ដែលកាលនោះ សុន សេន ជាមេរបស់គាត់ ។ នៅពេលគាត់មានអាយុប្រហែល៣០ឆ្នាំ គាត់បានផ្លាស់មករស់នៅស្រុកអន្លង់វែង និងបានរៀបការប្រពន្ធនៅឆ្នាំ១៩៨៩ ។ ក្រោយពេលដែលខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ គាត់បានមករស់នៅក្នុងភូមិឃុំដែលគាត់កំពុងតែរស់នៅបច្ចុប្បន្ន ហើយបានប្រកបរបរលក់ដូរមកដល់សព្វថ្ងៃ ។ គាត់បន្តថា ប្រជាជននៅតំបន់អន្លង់វែងទោះជាអតីតខ្មែរក្រហម ក៏ប្រជាជនទាំងនេះមានចិត្តស្រឡាញ់ និងគោរពសាសនាខ្លាំងណាស់ដែរ ពីព្រោះសាសនាជាអ្នកតម្រង់ទិសឲ្យមនុស្សដើរក្នុងផ្លូវល្អ ។ ប្រជាជនចង់បានការគោរពបូជាសាសនាមួយយ៉ាងពេញលេញ ដោយមិនចង់បានការគាបសង្កត់ផ្លូវចិត្តឡើយ ដែលផ្ទុយទៅការប្រណិប័តន៍សាសនាក្នុងរបបខ្មែរក្រហមត្រូវបានបំផ្លាញចោលទាំងស្រុង ។ ក្នុងសម័យនោះ ទីវត្តអារាមគ្មានព្រះសង្ឃគង់នៅ ខ្មែរក្រហមបានបង្ខំឲ្យព្រះសង្ឃលាចាកសិក្ខាបទ និងបញ្ជូនឲ្យទៅធ្វើស្រែចម្ការដូចប្រជាជនដទៃទៀតដែរ ។ ខ្មែរក្រហមបានធ្វើឲ្យទីវត្តអារាមក្លាយទៅជាគុកសម្រាប់ដាក់មនុស្ស ធ្វើជាឃ្លាំងសម្រាប់ដាក់ស្បៀងអាហារ និងសម្ភារផ្សេងៗ និងធ្វើជាទីកន្លែងសម្រាប់ចិញ្ចឹមជ្រូកទៅវិញ ។

ក្រោយរំដោះឆ្នាំ១៩៧៩ វត្តអារាមមួយចំនួនត្រូវបានរៀបចំឲ្យដំណើរការឡើងវិញ ដើម្បីឲ្យពុទ្ធសាសនិកជនបានធ្វើបុណ្យ ធ្វើទាន ហើយជាបណ្ដើរៗវត្តមួយចំនួនទៀតត្រូវបានបង្កើតថ្មី លើកលែងតែតំបន់ដែលនៅជាប់ព្រំដែនកម្ពុជា-ថៃប៉ុណ្ណោះ ព្រោះនៅតំបន់នោះជាតំបន់ដែលខ្មែរក្រហមកាន់កាប់នៅឡើយ ។ ខ្មែរក្រហមមានចេតនាលុបបំបាត់សាសនាចោលទាំងស្រុង ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យរៀបចំធ្វើពិធីបុណ្យផ្សេងៗដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យសពឡើយ ។ ជាធម្មតា បើនិយាយតាមបែបព្រះពុទ្ធសាសនា នៅពេលដែលប្រជាជនកម្ពុជាយើងរៀបចំធ្វើពិធីផ្សេងៗ ដូចជា ពីធីឡើងគេហដ្ឋាន បុណ្យបច្ច័យបួន បុណ្យផ្កា បុណ្យកឋិនទាន លើករាសី និងមង្គលការ ។ យើងតែងនិមន្តព្រះសង្ឃមកសូត្រធម៌ ចម្រើនព្រះបរិត្ត បង្សុកូល និងធម្មទេសនាទៀតផង ។ តែផ្ទុយគ្នាស្រឡះពិធីដូចបានរៀបរាប់ខាងលើ ខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនកម្ពុជាធ្វើឡើយ ។ ចំណែកការរៀបអាពាហ៍ពិពាហ៍វិញ ខ្មែរក្រហមបានបង្ខំឲ្យយុវជន-យុវនារីឲ្យរៀបការម្ដងៗចំនួនរាប់សិបគូ គ្មានការដឹងឮ ឬយល់ព្រមពីក្រុមគ្រួសារ ឪពុកម្ដាយ ជីដូនជីតា ពិសេសទៅទៀត សាមីខ្លួនតែម្ដង មិនបានដឹងថា ប្ដីឬប្រពន្ធរបស់ខ្លួនជានរណាផង ។ **ផាន ផល**

# អន្លង់វែង ៖ ការប្រតិបត្តិសាសនាដើម្បីផ្សះផ្សាផ្លូវចិត្ត

ខ្ញុំមិនសូវដឹងរឿងអ្វីច្រើនទេក្នុងរបប ប៉ុល ពត ។ ខ្ញុំបានដឹងព័ត៌មានតិចតួចតាមរយៈឪពុកម្តាយ និងចាស់ៗក្នុងភូមិនិយាយប្រាប់ប៉ុណ្ណោះ ។ បន្ទាប់ពីបានធ្វើដំណើរទស្សនកិច្ចនៅតំបន់អន្លង់វែងរយៈពេល៤ថ្ងៃ ទៅដល់តំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ខ្ញុំរឹតតែចង់ដឹង និងចង់ស្វែងយល់បន្ថែមទៀតពីរបបនេះ ។

នៅតំបន់អន្លង់វែង ទោះបីមានអតីតខ្មែរក្រហមរស់នៅច្រើនក៏ពិតមែន តែបច្ចុប្បន្នក៏មានបងប្អូនប្រជាពលរដ្ឋដែលជាជនរងគ្រោះទៅរស់នៅទីនោះដែរ ។ ទោះយ៉ាងណា ការឈឺចាប់របស់ជនរងគ្រោះទាំងនេះ បានរសាយបន្តិចម្តងៗ ដោយកត្តាទំនាក់ទំនងជីវភាព ពេលវេលា និងទ្រឹស្តីផ្សេងៗរបស់សាសនា ។

ស្ថិតនៅចម្ងាយ១២៥គីឡូម៉ែតពីទីរួមខេត្តសៀមរាប និងចម្ងាយប្រហែល១២គីឡូម៉ែតពីភ្នំដងរែក ស្រុកអន្លង់វែងជាតំបន់ដាច់ស្រយាលមួយនៃប្រទេសកម្ពុជា ។ ស្រុកអន្លង់វែង ជាស្រុកមួយស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ដែលនៅជិតព្រំប្រទល់រវាងប្រទេសកម្ពុជា និងប្រទេសថៃដែលមានច្រកទ្វារអន្តរជាតិនៅលើខ្នងភ្នំដងរែកឈ្មោះជាំសាង៉ាំ ។ ស្រុកអន្លង់វែងបែងចែកជា៤ឃុំ មាន ឃុំលំទងឃុំអន្លង់វែង ឃុំត្រពាំងតាវ និង ឃុំថ្លាវ ។ កាលពីមុន អន្លង់វែងជាតំបន់ដែលមានព្រៃឈើក្រាស់ សម្បូរដោយសត្វព្រៃ ហើយពុំសូវមានមនុស្សរស់នៅតែក៏ជាទីតាំងយុទ្ធសាស្ត្រយោធាដ៏មានសក្តានុពលរបស់ខ្មែរក្រហម ក្រោយពេលវៀតណាមដកទ័ពចេញ ។ បច្ចុប្បន្នអន្លង់វែងបានប្រែក្លាយជាទីប្រជុំជនមួយដ៏មានសក្តានុពលខាងវិស័យកសិកម្ម សេដ្ឋកិច្ច ទេសចរណ៍ លើសពីនេះអន្លង់វែងមានធនធានធម្មជាតិដ៏មានតម្លៃ ដូចជាព្រៃឈើ ធម្មជាតិដ៏ស្រស់ត្រកាល ដីមានជីជាតិសម្រាប់ដំណាំផ្សេងៗ ។ ឈើប្រណិតៗត្រូវបានប្រជាជនក្នុងតំបន់យកទៅកែច្នៃធ្វើជាគ្រឿងសង្ហារឹមគ្រប់ប្រភេទលក់នៅក្នុងស្រុក និងនាំចេញទៅក្រៅប្រទេស ។ រីឯផ្សារនៅក្នុងទីរួមស្រុកអន្លង់វែងមិនចាញ់ផ្សារនៅបណ្តាខេត្តផ្សេងៗប៉ុន្មានទេ ព្រោះមានលក់ផលិតផលជាច្រើនមុខ ។ ដោយសារតែនៅជិតព្រំដែនថៃ ទំនិញភាគច្រើនបាននាំចូលពីប្រទេសថៃ ។ ចំពោះជីវភាពរស់នៅរបស់ប្រជាជននៅទីនោះវិញ ខាន់ ធារ៉ា ដែលជាអ្នកស្រុកអន្លង់វែងផ្ទាល់បានលើកឡើងថា ជីវភាពរស់នៅរបស់ប្រជននៅអន្លង់វែងមានលក្ខណៈខុសគ្នាច្រើន ។ បើនិយាយពីអតីតមេកងពលឬមេបញ្ជាការធំៗគាត់មានដីស្រែចម្ការច្រើន ព្រោះគាត់មានតំណែងក្នុងកងកម្លាំងប្រដាប់អាវុធនៅតំបន់នេះ ។ ឯអ្នកចំណូលថ្មីភាគច្រើនរស់នៅតាមទីប្រជុំជន ប្រកបរបរលក់ដូរនៅផ្ទះ ឬនៅផ្សារ ។ ចំណែកឯប្រជាជនមួយចំនួនដែលធ្លាប់រស់នៅតំបន់នេះតាំងពីដើមមក ច្រើនតែរស់នៅឆ្ងាយពីទីប្រជុំជន ។ អ្នកទាំងនេះច្រើនប្រកបរបរស៊ីឈ្នួលធ្វើស្រែចម្ការ ក្រៅពីនេះគាត់រកជ័រធ្វើចន្លុះលក់នៅក្នុងតំបន់ និងនាំចេញទៅប្រទេសថៃ ។ មុខរបររកជ័រនេះមិនស្ថិតស្ថិរទេ ។



ចេតិយ៍របស់ តាម៉ុក នៅវត្តស្រះឈូក ស្រុកអន្លង់វែង

ថ្វីត្បិតនៅតំបន់នេះ មានដីទំនេរច្រើន តែប្រជាជនមួយចំនួន មិនមានដីសម្រាប់បង្កបង្កើនផលទេ ។ ប្រជាជនដែលមានជីវភាពក្រីក្រនៅតំបន់នេះច្រើនធ្វើជាអ្នកស៊ីឈ្នួលកាប់ឈើ ខ្លះទៀតអាចរកកម្រៃបាននៅតាមព្រំដែន ដោយធ្វើជាអ្នកអូសរទេះដឹកទំនិញឲ្យ

ឈ្នួញ ។ ចំពោះវិស័យអប់រំ ស្រុកអន្លង់វែង មានវិទ្យាល័យមួយសម្រាប់សិស្សានុសិស្សរៀនសូត្រ ។ ចំណែកវត្តអារាម ក៏មានការកសាងជាបន្តបន្ទាប់ជាប់រហូតមកដែរ ។ មកដល់សព្វថ្ងៃនេះ នៅក្នុងស្រុកអន្លង់វែង មានវត្តអន្លង់វែង, វត្តថ្នាត, វត្តតាដេវ, វត្តអូរអង្រ្រែ, វត្តដីថ្មី, វត្តទួលទ្រាស, វត្តអូរក្រញូង(នៅលើភ្នំដងរែក) , វត្តស្រះឈូក, វត្តពពេល និង វត្តពុទ្ធោភាវនា(ធម្មយុត្ត) ។

ខាន់ ធារ៉ា បានបន្តថា វត្តមួយចំនួនមានពុទ្ធបរិស័ទទៅធ្វើបុណ្យច្រើនជាហេតុធ្វើឲ្យសមិទ្ធិផលនៅក្នុងវត្តមានការរីកចម្រើន ឯព្រះសង្ឃក៏គង់នៅចាំព្រះវស្សាមានចំនួនច្រើនដែរ ដូចជាវត្តអន្លង់វែងជាដើម ។ ចំណែកឯវត្តដែលមិនសូវមានពុទ្ធបរិស័ទទៅធ្វើបុណ្យវិញគឺមានព្រះសង្ឃ២ទៅ៣អង្គប៉ុណ្ណោះដែលគង់នៅដូចជា វត្តស្ថិតក្នុងភូមិអូររុនជាដើម ។

ពេលរបប លន់ នល់ ដួលរលំនៅថ្ងៃ១៧មេសាឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងគ្រប់គ្រងអំណាចជំនួស ។ ទោះបីជាខ្មែរក្រហមបានប្រកាសរដ្ឋធម្មនុញ្ញឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ក៏ការប្រកាសនេះមិនបានធានាដល់ការប្រតិបត្តិសាសនាដែរ ។ ទាំងនៅអន្លង់វែង ក៏ដូចជានៅតំបន់ផ្សេងៗទៀត ប្រជាជនមិនអាចគោរពសាសនារបស់ខ្លួនបានឡើយ ព្រោះខ្មែរក្រហមបានចាត់ទុកសាសនាទាំងអស់ជាសាសនាប្រតិកិរិយា ។ ខ្មែរក្រហមស្អប់ខ្ពើមរបបមូលធននិយម និងរបបសក្តិភូមិ ។

គ្រូពេទ្យ នៃ ធ្វើការនៅមណ្ឌលសុខភាពអន្លង់វែង បានឲ្យដឹងថា “តាំងពីឆ្នាំ១៩៧៥ដល់១៩៧៩ នៅតំបន់នេះគ្មានវត្តអារាមទេ តែបើកាលពីគាត់នៅភូមិចាស់ពីដើមមកមានវត្តអារាមប្រជាជនធ្វើបុណ្យហូរហែ ។ ស្រុកនេះពីដើមឡើយគេហៅភូមិចោរៗ ហើយខណ្ឌចែកត្រង់ព្រៃស្អាក ។ ពីដើមគ្មាននរណាហ៊ានធ្វើដំណើរឆ្លងកាត់មកទីនេះទេ ព្រោះគេខ្លាចចោរ ហើយម្យ៉ាងទៀតខ្លាចសត្វសាហាវ ។ ក្រោយមក ខ្មែរក្រហមបានមកនៅតំបន់នេះ ដែលកាលនោះសម្បូរដោយព្រៃឈើក្រាស់ៗ ហើយមានផ្ទះប្រជាជនមួយៗប៉ុណ្ណោះ ។ ចំណែកការរៀបចំពិធីបុណ្យផ្សេងៗ គឺគ្មានព្រះសង្ឃ គ្មានតាអាចារ្យទេ រីឯបុណ្យសពវិញមានតែចាស់ៗបួនប្រាំនាក់ក្នុងភូមិធ្វើកិច្ចផ្សេងៗរួចសែនយកទៅបូជា ខ្លះយកទៅបញ្ចុះនៅក្នុងព្រៃ ។

ចំពោះពិធីរៀបការវិញ តាមប្រសាសន៍របស់លោក តាអ៊ុយ ប្រុង អាយុ៦៨ឆ្នាំ ជាអ្នកភូមិ អូរគរគីកណ្តាល បានលើកឡើងថា មកដល់ឆ្នាំ១៩៨២ ឬ១៩៨៣ ខ្មែរក្រហមនៅតែអនុវត្តការរៀបការច្រើនៗគូក្នុងពេលតែមួយដដែល ។ យោធាណាដែលដល់អាយុត្រូវរៀបការ ថ្នាក់លើក៏យកបញ្ជីមកបង្ហាញហើយនិយាយថា មិត្តឯងដល់អាយុយកប្រពន្ធហើយ ។ គ្មានយោធាណាហ៊ានប្រកែកថាមិនយកទេ ព្រោះថ្នាក់លើរៀបចំឲ្យហើយ ។ ប៉ុន្តែបុគ្គលណាមួយប្រកែក ក៏ថ្នាក់លើមិនបង្ខំដែរ ។ ការរៀបការមិនមានពិធីអ្វីច្រើនទេ គ្រាន់តែកូនក្រមុំ និងកូនកម្លោះ ឈរទន្ទឹមគ្នាឱនគោរពទង់បដិវត្តន៍ដែលមានរូបសញ្ញាកណ្តៀវ និងកួរស្រូវ និងប្តេជ្ញាថារួមរស់ជាមួយគ្នាមិនបែកបាក់គ្នា ។

ថ្វីត្បិតតែនៅអំឡុងឆ្នាំ១៩៨៣ មិនទាន់មានការគោរពលើជំនឿសាសនាពេញលេញ តែយោធាខ្មែរក្រហមគោរពតាមក្រមសីលធម៌របស់ខ្មែរក្រហមដែលមានចែងក្នុងច្បាប់ ។ លោកតា ប៊ុត ព អាយុ៦៣ឆ្នាំ ជាអតីតទាហានខ្មែរក្រហម បានមានប្រសាសន៍ថា ក្រមសីលធម៌ទាហានខ្មែរក្រហមមានចាប់ពីឆ្នាំ១៩៨៣ ឡើងទៅមានចែងដូចជា មិនឲ្យយើងបង្ខំចាប់កូនអ្នកស្រុក អ្នកស្រែ មិនឲ្យប៉ះពាល់ជាដាច់ខាត ហើយពេលដើរចំចម្ការ និងតាមផ្ទះ កុំឲ្យបេះដំណាំ រឺផ្លែឈើផ្តេសផ្តាស ។

ក្រោមការគ្រប់គ្រងរបស់ តាម៉ុក នៅអន្លង់វែងឃើញថាចាស់ៗភាគច្រើនដែលធ្លាប់រស់នៅតែងតែសរសើរដល់គាត់ (តាម៉ុក) ។ នៅក្នុងមណ្ឌលសុខភាពដែលសាងសង់ឡើងពីឈើដោយ តាម៉ុក លោកគ្រូពេទ្យ នៃ បានមានប្រសាសន៍ថា ក្រោមការគ្រប់គ្រងរបស់ តាម៉ុក ប្រជាជនគ្រប់រូបមានសេរីភាពលើជំនឿសាសនារបស់ខ្លួន ហើយនៅទីនេះប្រជាជនភាគច្រើនប្រណិប័តន៍តែព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ តាម៉ុក បានផ្តើមសាងសង់វត្តអារាមឲ្យប្រជាជនធ្វើបុណ្យធ្វើទានទៀតផង ។ ក្រៅពីវត្តអារ៉ាម តាម៉ុក បានកសាងស្ពានផ្លូវថ្នល់ និងមន្ទីរពេទ្យថែមទៀត ។

ការប្រត្តិបត្តិសាសនាតាមទ្រឹស្តីព្រះពុទ្ធសាសនារបស់អតីតខ្មែរក្រហមទាំងនេះ បានចូលរួមចំណែកដ៏សំខាន់នៅក្នុងដំណើរការនៃការផ្សះផ្សា និងជួយឲ្យជនរងគ្រោះអាចព្យាបាលរបួសផ្លូវចិត្តបានតាមរយៈសាសនាដែរ ។

**ស្ងួន សុភ័ក្ត្រ**

# ថុំ ទង់: ពីយោធាមកធ្វើគ្រូបង្រៀននៅអន្លង់វែង

កម្ពុជាប្រជាធិបតេយ្យ គឺជារបបមួយដែលប្រជាជនកម្ពុជាទូទៅស្គាល់ និងហៅថា របបខ្មែរក្រហម ។ របបនេះ បានធ្វើឲ្យប្រជាជនកម្ពុជាស្លាប់ជាងពីរលាននាក់ ដោយសារ ការអត់អាហារ ធ្វើពលកម្មហួសកម្លាំង ជំងឺ និងការសម្លាប់ ។ រឿងរ៉ាវនៃទុក្ខវេទនាទាំងឡាយ នៅតែដិតដាមក្នុងចិត្តអ្នកដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមជានិច្ច ។ អ្នកដែលរួចរស់ជីវិតនោះតែងតែយកព្រឹត្តិការណ៍ដែលធ្លាប់បានឆ្លងកាត់ មកធ្វើជាឧទាហរណ៍ដើម្បីអប់រំកូនចៅ ។ ជាក់ស្តែងលោកតា ថុំ វង់ គឺជាអតីតយុទ្ធជនមួយរូបដែលបានចូលរួមតស៊ូជាមួយបដិវត្តន៍ដែរ ។ សព្វថ្ងៃនេះ គាត់មានអាយុ ៧០ឆ្នាំហើយ ។ ពេញមួយជីវិតជាយុវវ័យរបស់គាត់ គឺមិនដែលសប្បាយនោះទេ ព្រោះគាត់បានចំណាយពេលធ្វើជាយុទ្ធជនខ្មែរក្រហម តស៊ូប្រឆាំងជាមួយរបប លន់ នល់ ដើម្បីដណ្តើមអំណាចថ្វាយសម្តេចឪវិញ ។

### ការផ្លាស់ជាទ័ពស្រុក

បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះទូទាំងប្រទេស វង់ មិនត្រូវបានអង្គការជម្លៀសទៅកន្លែងផ្សេងទេ គឺគាត់មានតួនាទីជាទ័ពស្រុកឈូកដដែល ។ វង់ បានឲ្យដឹងថា កងទ័ពគឺ មានវិន័យតឹងតែងណាស់ ។ អង្គការមិនអនុញ្ញាតឲ្យនិយាយលេង ឬអង្គុយជជែកគ្នាដោយគ្មានបទបញ្ជាឡើយ ។ គ្រប់គ្នាត្រូវធ្វើការតាមការចាត់តាំងរបស់អង្គការ ដោយមិនមានសិទ្ធិដើរហើរសេរីឡើយ ។ ចំពោះការហូបចុក វង់ និយាយថា មិនមានការលំបាកខ្លាំងនោះទេ គ្រាន់តែកងទ័ពទាំងអស់ត្រូវហូបរួម និងមិនអាចលួចហូបជាឯកជនបាន ។ បើមាននរណាម្នាក់ហ៊ានល្មើស នោះអង្គការនឹងចោទថា ក្បត់អង្គការ ឬក្បត់សមូហភាព ហើយនឹងត្រូវទទួលទោសជាមិនខាន ។

### ការរៀបការ

នៅឆ្នាំ១៩៧៦ អង្គការបានរៀបគ្រួសារឲ្យ វង់ ។ អនាគត



សាលារៀនដែលសាងសង់ក្នុងអំឡុង តាម៉ុក គ្រប់គ្រង បច្ចុប្បន្ន វិទ្យាល័យអន្លង់



មណ្ឌលសុខភាព ស្រុកអន្លង់វែង

ប្រពន្ធរបស់គាត់ ជាអ្នកដែលមានស្រុកកំណើតនៅខេត្តតាកែវ ។ ចំពោះរឿងនេះ ពិតជាធ្វើឲ្យ វង់ មានការភ្ញាក់ផ្អើលណាស់ ព្រោះគាត់ទាំងពីរមិនដែលធ្លាប់ស្គាល់ ឬជួបគ្នាម្តងណាឡើយ ។ ប៉ុន្តែ វង់ ក៏មិនហ៊ានតវ៉ានឹងការសម្រេចរបស់អង្គការដែរ ព្រោះមិនមែនមានតែគាត់ទេដែលត្រូវរៀបការក្នុងពេលនោះ ។ វង់ បានឲ្យដឹងថា អង្គការបានរៀបការឲ្យយុទ្ធជន យុទ្ធនារីជាច្រើនគូក្នុងពេលនោះ ។ បន្ទាប់ពីរៀបការរួច វង់ និងប្រពន្ធ ក៏មិនបានរស់នៅជួបជុំគ្នាដែរ ព្រោះម្នាក់ៗមានភារកិច្ចដែលត្រូវធ្វើរៀងៗខ្លួន ។ ពេញមួយរបបខ្មែរក្រហម វង់ មិនធ្លាប់បានផ្លាស់អង្គភាពទៅស្រុកផ្សេង ឬតំបន់ផ្សេងទេ ។ គាត់នៅឈរជើងនៅស្រុកឈូកនេះ រហូតដល់របបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ។

## ការដួលរលំរបបខ្មែរក្រហម និងការមកដល់អន្លង់វែង

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ យោធាខ្មែរក្រហមបានភៀសប្រជាជន ក៏ដូចជាកម្លាំងរបស់ខ្លួនដែលនៅសេសសល់ធ្វើដំណើរឆ្ពោះទៅព្រំដែនថៃ ។ វង់ និងគ្រួសារបានភៀសខ្លួនពីស្រុកឈូកឆ្ពោះទៅតំបន់អន្លង់វែង ដែលនៅជាប់ព្រំដែនថៃ ។ វង់ ជាមួយនឹងអ្នកឯទៀតបានធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលយ៉ាងយូរទម្រាំទៅដល់តំបន់អន្លង់វែង ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។

នៅអំឡុងឆ្នាំ១៩៨៦ នៅពេលមានការវាយប្រហារពីសំណាក់កងទ័ពរដ្ឋាភិបាល និងវៀតណាមជាញឹកញាប់មកលើតំបន់អន្លង់វែង ទើប វង់ និងគ្រួសារ ក៏ដូចជាប្រជាជនដទៃទៀត បាននាំគ្នាភៀសខ្លួនទៅរស់នៅជំរំក្នុងទឹកដីថៃ ។ ទៅដល់ជំរំ វង់ បានសម្រេចចិត្តលាឈប់ពីយោធា មកធ្វើជាប្រជាជនធម្មតាវិញ ហើយក៏មិនមានការជំទាស់អ្វីពីថ្នាក់លើដែរ ។ វង់ បានឲ្យដឹងថា ការរស់នៅរបស់ប្រជាជនត្រូវបានឧបត្ថម្ភទាំងស្រុងពីសំណាក់អង្គការសហប្រជាជាតិ ។ ប្រជាជនម្នាក់ៗ ទទួលអំណោយជាប្រចាំ មានដូចជា ទឹកអុស អង្ករ ត្រីខកំប៉ុង និង គ្រឿងឧបភោគ បរិភោគជាច្រើនទៀត ។

## អន្លង់វែងក្រោមការគ្រប់គ្រងរបស់ តាម៉ុក

នៅអំឡុងឆ្នាំ១៩៨៩ ពេលទ័ពរដ្ឋាភិបាលបានដកទ័ពចេញពីតំបន់អន្លង់វែង តាម៉ុក បាននាំប្រជាជនមករស់នៅតំបន់អន្លង់វែងវិញ ។ តាម៉ុក បានចាត់ឲ្យ វង់ ធ្វើជាសមាជិកមន្ទីរកងពលស្រុកអន្លង់វែង និងមួយរយៈក្រោយមក ក៏ផ្លាស់ វង់ ឲ្យមកធ្វើជាគ្រូបង្រៀនវិញ ។ វង់ បានឲ្យដឹងថា អន្លង់វែង ក្រោមការគ្រប់គ្រងរបស់ តាម៉ុក គឺប្រសើរជាងក្នុងរបបខ្មែរក្រហម ។ តាម៉ុក បានបំផុសឲ្យប្រជាជនទាំងអស់ ក៏ដូចជា វង់ ចូលរួមសាមគ្គីគ្នា កសាងមន្ទីរពេទ្យ សាលារៀន ទំនប់ ផ្លូវថ្នល់ជាដើម ។ ការធ្វើការងារទាំងនេះ ក៏មិនបង្ខិតបង្ខំឲ្យហួសកម្លាំងដែរ គឺប្រជាជនម្នាក់ៗអាចមកជួយ បន្ទាប់ពីអ្នកទាំងនោះ ទំនេរពីការងារស្រែចម្ការ ឬការងារផ្ទាល់ខ្លួន ។ ចំពោះជីវភាពរស់នៅរបស់ប្រជាជនក៏មិនមានការ ខ្វះខាតអ្វីទៀតដែរ ព្រោះ តាម៉ុក ជួយផ្គត់ផ្គង់ខ្លះ និងប្រជាជនអាចធ្វើស្រែចម្ការ ឬរកស៊ីបន្ថែមសម្រាប់ជីវភាពគ្រួសារដោយឯកជនបាន ។

## បច្ចុប្បន្នភាព

បន្ទាប់ពីប្រទេសមានសុខសន្តិភាពពេញលេញ នៅឆ្នាំ១៩៩៩ វង់ បានធ្វើជានាយកសាលាបឋមសិក្សាថ្លាត រហូតដល់ឆ្នាំ២០០២ ទើបគាត់ផ្លាស់មកធ្វើជានាយកសាលាបឋមសិក្សាអន្លង់វែង ។ នៅឆ្នាំ២០០៥ វង់ ក៏ផ្លាស់មកធ្វើការនៅការិយាល័យស្រុកអន្លង់វែង រហូតដល់គាត់ចូលនិវត្តន៍នៅឆ្នាំ២០១២ ។ សព្វថ្ងៃ គាត់រស់នៅជាមួយប្រពន្ធ និងកូនប្រុសស្រីពីរនាក់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយប្រកបរបរធ្វើស្រែចម្ការ ។

**ចាន់ ឡាត**

# ជាង៤០ឆ្នាំក្រោយមក ទើបដឹងថា ឪពុកស្លាប់នៅទួលស្លែង

កែវ ម៉ាលី ជាគ្រូបង្រៀនផ្នែកគីមី កម្រិតថ្នាក់អនុវិទ្យាល័យ នៅស្រុកអង្គស្នួល ខេត្តកណ្តាល ។ ថ្មីៗ នេះ អ្នកគ្រូបានប្រឡងជាប់



អ្នកគ្រូ កែវ ម៉ាលី នៅសាលពិព័រណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

គ្រូកម្រិតឧត្តម និងត្រូវឡើងមករៀនវគ្គពង្រឹងរយៈពេលបីខែបន្ថែមទៀត ដែលរៀបចំដោយក្រសួងអប់រំ យុវជន និង កីឡា នៅវិទ្យាស្ថានជាតិអប់រំ ។ អ្នកគ្រូបានជួបខ្ញុំដោយចៃដន្យនៅមុខការិយាល័យទស្សនាវដ្តីស្វែងរកការពិត ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ក្រោយពីចប់វគ្គសិក្សានៅពេលរសៀល ។ ក្នុងអំឡុងពេលជជែកគ្នា ខ្ញុំបានសាកសួរពីស្រុកកំណើត និងប្រវត្តិគ្រួសាររបស់គាត់ ។ ដោយសារតែអ្នកគ្រូមានពេលខ្លី ព្រោះត្រូវត្រឡប់ទៅផ្ទះវិញ ទើបអ្នកគ្រូរៀបរាប់រឿងរ៉ាវខ្លីៗទាក់ទងនឹងទឹកដីកំណើត សាច់ញាតិ និងការស្លាប់របស់បងប្អូន និងឪពុករបស់គាត់ម្នាក់ដែលត្រូវបានចោទថា "ខុសលីសធម៌" រួចអង្គការចាប់យកទៅសម្លាប់ទាំងគ្រួសារ រួមមានប្រពន្ធ និងកូនតូច ។

ឆ្លៀតឱកាសនោះ ខ្ញុំក៏បានសាកសួរគាត់ពីឈ្មោះឪពុកម្តាយ ។ អ្នកគ្រូម៉ាលី បានរៀបរាប់ថា បើតាមម្តាយរបស់គាត់ដែលនៅរស់និយាយប្រាប់ ឪពុករបស់គាត់ឈ្មោះ ហង់ កែវ ហៅ ស្មៀន ស្លាប់ប្រហែលខែកក្កដា ឆ្នាំ១៩៧៦ នៅពេលគាត់មានអាយុទើបតែ៦ឆ្នាំ ។ ឪពុកគាត់បានចូលរួមជាមួយចលនាខ្មែរក្រហមតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ហើយក្រោយមក បានកាន់តួនាទីខាងភ័ស្តុភារនៅក្នុងកងពល៨០១ ។ នៅពេលយោធាខ្មែរក្រហមទទួលជ័យជម្នះ នៅឆ្នាំ១៩៧៥ ឪពុករបស់គាត់ ត្រូវបានបញ្ជូនឲ្យទៅការពារព្រំដែន ក្នុងខេត្តរតនគិរី ។ នៅទីនោះ ឪពុករបស់គាត់ត្រូវបានអង្គការចោទប្រកាន់ថា ក្បត់ រួចចាប់បញ្ជូនមកឃុំឃាំង និងសម្លាប់នៅគុកទួលស្លែង ។

ភ្លាមៗ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ អ្នកគ្រូ និងក្រុមគ្រួសារបានព្យាយាមតាមសាកសួររកឈ្មោះឪពុកនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងទីស្នាក់ការទទួលជនភៀសខ្លួនមកពីជំរំ ប៉ុន្តែគាត់មិនបានទទួលព័ត៌មានអ្វីទាំងអស់ ។

ដោយសារខ្ញុំធ្លាប់មើលរូបថត និងអានឯកសារខ្លះដែលរៀបរាប់ពីឈ្មោះអ្នកទោសនៅគុកទួលស្លែង ក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទើបខ្ញុំចងចាំស្រពេចស្រពិលពីរូបថតអ្នកទោសម្នាក់ឈ្មោះ ហង់ កែវ ក្រោយពេលអ្នកគ្រូ ម៉ាលី បានរំឭកពីឈ្មោះឪពុករបស់គាត់ ។ ខ្ញុំបានព្យាយាមស្រាវជ្រាវរកឈ្មោះ ហង់ កែវ នៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រយៈពេលពីរថ្ងៃ ទើបឃើញរូបថតពណ៌ស-ខ្មៅ ជាមួយនឹងចំណារឈ្មោះពណ៌ស្វាយ ។

ទោះបីយ៉ាងណា ដោយសារអ្នកគ្រូ ម៉ាលី មិនបានឃើញមុខឪពុករយៈពេលជាង៤០មក ហើយម្យ៉ាងទៀតដោយសារចំណារលើរូបថតដែលសរសេរឈ្មោះហៅក្រៅឪពុករបស់គាត់ "ស្មៀន" ខុសនឹងឈ្មោះដែលគាត់ធ្លាប់ហៅឪពុក "ស្ងៀន" ពេលនៅរស់ ទើបធ្វើឲ្យគាត់នៅមានមន្ទិលសង្ស័យលើរូបថត ។ អ្នកគ្រូបានចំណាយពេលមួយយប់ ដើម្បីរំពឹកឡើងវិញនូវការចងចាំពីឪពុក និងកត់សម្គាល់ទៅលើរូបរាងឪពុក ហើយដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀត អ្នកគ្រូបានយករូបឪពុក ដែលទទួលបានទៅបង្ហាញម្តាយ ។ ទីបំផុត ទើបអ្នកគ្រូដឹងថា រូបថតនេះពិតជាឪពុករបស់គាត់តាមរយៈ ចំណារឈ្មោះ "ហង់ កែវ" ក្នុងពេលចូលរួមបដិវត្តន៍ជាមួយខ្មែរក្រហម និងការចំណាំរបស់ម្តាយគាត់ទៅលើ


ឪពុករបស់អ្នកគ្រូ កែវ ម៉ាលី ឈ្មោះ ហង់ កែវ ហៅ សៀន ជាប់ឃុំឃាំងនៅគុកទួលស្លែង

ភិនភាគឪពុករបស់គាត់ដែលមានសម្បុរស ប្រមុះស្រួច និងមានជំងឺសើរស្បែក (ស្នាមរបក) នៅលើមុខ និងដងខ្លួន ពេលរស់នៅជាមួយគ្នា ។

### អារម្មណ៍នៅពេលទទួលដំណឹងឪពុក

អ្នកគ្រូ ម៉ាលី បានរៀបរាប់ទាំងទឹកភ្នែកថា គាត់ និងម្តាយឈ្មោះ ខៀវ សារីម បច្ចុប្បន្នអាយុ៧៨ឆ្នាំ រស់នៅឃុំព្រៃព្ួច ស្រុកអង្គស្នួល ខេត្តកណ្តាល មានអារម្មណ៍រន្ធត់ និងឈឺចាប់នៅពេលឃើញរូបថតឪពុក ព្រោះគាត់មិនដែលដឹកស្មានថា ឪពុកគាត់ស្លាប់នៅទួលស្លែងទេ ។ អ្នកគ្រូបានបន្តថា គាត់ស្រណោះឪពុកយ៉ាងខ្លាំង ព្រោះឪពុករបស់គាត់ ប្រហែលជាត្រូវបានរងទារុណកម្ម មុននឹងស្លាប់នៅទួលស្លែង ។ គាត់ និងម្តាយរួមជាមួយនឹងក្រុមគ្រួសារបានទន្ទឹងរង់ចាំដំណឹងឪពុកយូរណាស់មកហើយ ។ អ្វីដែលអ្នកគ្រូចងចាំជាងគេនៅអំឡុងពេលនោះ គឺ ឪពុករបស់គាត់មានរាងខ្ពស់សប្បុរស ហើយនៅពេលនឹករឭកឪពុកម្តងៗ គាត់តែងតែនិយាយពីការបាត់បង់ឪពុកប្រាប់កូនៗទាំងពីរនាក់ដែលកូនប្រុសរបស់គាត់ម្នាក់រូបរាងដូចទៅនឹងជីតា ។

### ជួបមុខឪពុកបន្ទាប់ពីជ័យជម្នះ

នៅក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧៦ អ្នកគ្រូម៉ាលី រួមជាមួយម្តាយ និងប្អូនស្រីពីរនាក់ត្រូវបានខ្មែរក្រហមបញ្ជូនពីស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ តាមកប៉ាល់ឲ្យទៅរស់នៅជាមួយឪពុកនៅក្នុងខេត្តរតនគិរី ។ អ្នកគ្រូ ម៉ាលី ម្តាយ និងប្អូនរបស់គាត់បានទៅរស់នៅក្នុងបន្ទាយយោធា ដែលគាត់នៅចាំថា ស្ថិតនៅក្នុងស្រុកវើនសៃ ។

### ថ្ងៃចុងក្រោយ

រយៈពេលពីរខែក្រោយពេល អ្នកគ្រូ ម៉ាលី និងគ្រួសារទៅដល់ស្រុកវើនសៃ ឪពុករបស់គាត់ ត្រូវបានអង្គការចាប់ខ្លួន ។ ប៉ុន្តែមុនពេលចាប់ខ្លួនមួយថ្ងៃ អ្នកគ្រូ ម៉ាលី នៅចាំថា ឪពុករបស់គាត់បានយកគាត់ទៅដេកជាមួយ ហើយពេលនោះគាត់ក៏មិនបានដឹងរឿងរ៉ាវដែលកើតឡើងចំពោះឪពុករបស់គាត់ដែរ ដោយសារតែគាត់មានវ័យក្មេងពេក ។ បន្ទាប់ពីបាត់ឪពុក អ្នកគ្រូ ម៉ាលី ម្តាយ និងប្អូនស្រីពីរនាក់ ត្រូវបានខ្មែរក្រហមបញ្ជូនពីស្រុកវើនសៃ ខេត្តរតនគិរី មកឃុំឃាំង និងលត់ដំនៅកោះ តាពាង និងកោះខ្វៃ ក្នុងខេត្តក្រចេះ ។ ដោយសារនៅទីនោះ អ្នកគ្រូ, ម្តាយ និងប្អូនៗ អាចរកដំឡូង យកមកហូបបាន ទើបអាចរស់ជីវិតរហូតមកដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# ទើបទទួលបានសំបុត្រពីប្អូន

ទេព លីម មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលបានឃើញសំបុត្រដែលប្អូនប្រុសសរសេរក្នុងបំណងផ្ញើមកសួរសុខទុក្ខឪពុក និងបងប្អូននៅស្រុកកំណើតក្នុងស្រុករមាសហែក ខេត្តស្វាយរៀង កាលពីឆ្នាំ១៩៧៨ ។ លីម បានឲ្យដឹងថា រហូតដល់សព្វថ្ងៃគាត់នៅតែទន្ទឹងរង់ចាំដំណឹងពីប្អូន ហើយគាត់ ក៏មិននឹកស្មានថាប្អូនរបស់គាត់សរសេរសំបុត្រផ្ញើមកផ្ទះដែរ ។ គាត់រន្ធត់នៅពេលឃើញសំបុត្ររបស់ប្អូន ហើយគាត់នឹងរក្សាទុកសំបុត្រនេះឲ្យបងប្អូននិងកូនចៅអាន ។

កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាពីររូបបានរៀបចំការផ្សាយបន្តពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលប្រកាសសាលដីកាស្ថាពរទាក់ទងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅវត្តស្វាយទន្ទឹម ឃុំត្រពាំងស្ដៅ ស្រុករមាសហែក ខេត្តស្វាយរៀង។ នៅខណៈពេលដែលចែកជូនឯកសារមួយចំនួនដល់អ្នកចូលរួម យើងបានប្រទះឃើញសំបុត្រសរសេរដៃមួយច្បាប់នៅក្នុងឯកសារប្រល័យពូជសាសន៍ ៖ អ្នកណាជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដែលត្រូវនាំមកជំនុំជម្រះ? ភាពចាំបាច់នៃសំណុំរឿង ០០២ បោះពុម្ពផ្សាយ នៅឆ្នាំ២០១០ ។ នៅលើស្រោមសំបុត្របានសរសេរថា ៖ សូមផ្ញើជូនចំពោះលោកឪពុកឈ្មោះ ទេព ម៉ឹង នៅភូមិទួលសុក្រំ ឃុំត្រពាំងស្ដៅ ស្រុករមាសហែក តំបន់ស្វាយរៀង ពីកូន ទេព សុភាព នៅអង្គភាពកងពលលេខ៣ ភូមិភាគ ២០៣ ។ បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីកាសម្រេចឲ្យ នួន ជា និង ខៀវ សំផន ជាប់គុកអស់មួយជីវិត រួចមក យើងបានធ្វើដំណើរតាមម៉ូតូ ទៅភូមិទួលសុក្រំ តាមការផ្តល់ដំណឹងពីប្រជាជន និង អាជ្ញាធរឃុំ ។ យើងបានធ្វើដំណើរលើផ្លូវលំដែលមានសភាពក្រហូង និង ភក់ល្បាប់ប្រមាណជាង៨គីឡូម៉ែត្រ



រូបខាងស្ដាំ ៖ ទេព លីម ត្រូវជាបងស្រីរបស់ ទេព សុភាព ហៅ យ៉ាត នៅភូមិទួលសុក្រំ ភូមិត្រពាំងស្ដៅ ស្រុករមាសហែក ខេត្តស្វាយរៀង



ក៏ បានជួបអ៊ី ទេព លឹម បច្ចុប្បន្ន អាយុ៧៧ឆ្នាំ នៅផ្ទះរបស់គាត់ស្ថិតក្នុងភូមិទួលសុក្រំ ឃុំត្រពាំងស្ដៅ ស្រុករមាសហែក ខេត្តស្វាយរៀង ដែលត្រូវជាបងស្រី បង្កើតរបស់ ទេព សុភាព ។ ទេព លឹម បានរៀបរាប់ឲ្យដឹងថា គាត់មិនដែលទទួលបានដំណឹងពីប្អូនប្រុសរបស់គាត់ទេ ចាប់ តាំងប្អូនចាកចេញពីស្រុកកំណើតទៅចូលរួមតស៊ូជាមួយចលនាបដិវត្តន៍ខ្មែរក្រហម ។ រាល់ថ្ងៃ គាត់នៅតែអាឡោះអាល័យ និងនឹកស្រណោះប្អូន ដោយសារតែប្អូនជាមនុស្សស្លូតបូត ។ ចំណែកឪពុករបស់គាត់ កាលពេលដែលនៅរស់ក៏បានទៅរកគ្រូទាយ ដើម្បីទាយរកកូនប្រុស ទេព សុភាព ហៅ យ៉ាត ដែលបានបាត់ខ្លួនដែរ តែដំណឹងដែលគ្រូទាយ ទាយថា សុភាព នៅរស់រីតតែធ្វើឲ្យឪពុកគាត់ នឹករឭកកូនកាន់តែខ្លាំង រហូតដល់ថ្ងៃឪពុកគាត់ស្លាប់ ។

លឹម បានឲ្យដឹងទៀតថា គាត់មានប្អូនបង្កើតចំនួន៨នាក់ ហើយ ទេព សុភាព ជាកូនទី៧ ។ ក្នុងចំណោមប្អូនរបស់គាត់ទាំងអស់ មានតែ ទេព សុភាព មួយប៉ុណ្ណោះដែលបានរៀនខ្ពស់ជាងគេ ។ សុភាព បានរៀនចប់ថ្នាក់ឌីប្លូម នៅវិទ្យាល័យកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ សុភាព បានចូលរួមចលនាបដិវត្តន៍ខ្មែរក្រហម ដែលពេលនោះ មានការគាំទ្រពីកងទ័ពវៀតកុង (វៀតណាមខាងជើង) ។ មិនយូរប៉ុន្មាន សុភាព បានឡើងនាទីជា យោធាស្រុក ។

ក្រោយពីយោធាខ្មែរក្រហមទទួលជ័យជម្នះ នៅខែមេសា ឆ្នាំ១៩៧៥ សុភាព ត្រូវបានផ្លាស់ មកយោធាតំបន់២៣ ស្ថិតនៅទីរួមខេត្តស្វាយរៀង ។

នៅឆ្នាំ១៩៧៥ ដដែល សុភាព បានបរទេះសេះទៅលេងឪពុកម្ដាយនៅស្រុកកំណើតនៅភូមិទួលសុក្រំ ។ សុភាព បានស្នាក់នៅផ្ទះមួយយប់ប៉ុណ្ណោះ ក៏ចាកចេញទៅរករុក្ខជាតិដើម្បីផ្សំធ្វើថ្នាំខ្មែរ ទោះបីពេលនោះឪពុករបស់គាត់បានអង្វរកូន (សុភាព) ឲ្យស្នាក់នៅផ្ទះមួយរយៈទៀតក៏ដោយ ។ សុភាព បានប្រាប់ឪពុកវិញថា «នេះជាភារកិច្ចរបស់បដិវត្តន៍ដែលមិនអាចឲ្យគាត់ស្នាក់បានយូរ» ។ ឪពុករបស់គាត់បានស្រក់ទឹកភ្នែកនៅពេល សុភាព ចាកចេញពីផ្ទះដោយសារនឹកអាល័យកូន ។

ទេព លឹម មានប្រសាសន៍ថា គាត់មានការពេញចិត្តនឹងសាលក្រមដែលសម្រេចឲ្យ នួន ជា និង ខៀវ សំផន ឲ្យជាប់គុកអស់មួយជីវិត ពីព្រោះរបបខ្មែរក្រហមដែលមាន នួន ជា និង ខៀវ សំផន ជាមេដឹកនាំជាន់ខ្ពស់នេះហើយដែលបានបង្ខំឲ្យគាត់ចាកចេញពីផ្ទះសម្បែង ស្រុកកំណើតទៅធ្វើ ការងារធ្ងន់ធ្ងរពីមួយកន្លែងទៅកន្លែង រហូតទៅខេត្តពោធិ៍សាត់ និងបានបែកបាក់ក្រុមគ្រួសាររហូតមកដល់បច្ចុប្បន្ននេះ ។

**សោម ប៊ុនថន**

# សាលដីកាស្ថាពរនៃសំណុំរឿង០០២ វគ្គ១

“ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ (មាត្រា១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ) ។


នួន ជា និង ខៀវ សំផន នៅក្នុងបន្ទប់សវនាការ

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលប្រជាជនហៅថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នឹងចេញសេចក្តីសម្រេចចុងក្រោយ(សាលដីកា) លើសំណុំរឿង០០២ វគ្គ១ ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ ជនជាប់ចោទទាំងពីររូបត្រូវបានអង្គជំនុំជម្រះសាលាដំបូងកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ នេះគឺជាសេចក្តីសម្រេចចុងក្រោយ និងលើកដំបូងបំផុតប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ដែលបានចេញគោលនយោបាយធ្វើឲ្យស្លាប់ប្រជាជនខ្មែរប្រមាណជិតពីរលាននាក់ ។

សំណុំរឿង០០២ វគ្គ១ ចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបើកក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ។ សំណុំរឿងនេះចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជនដំណាក់កាលទី២ ដែលត្រូវបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៧ ព្រមទាំងការសម្លាប់រង្គាលលើអតីតទាហ៊ាន និងមន្ត្រីរដ្ឋការរបបលន់ នល់ នៅទួលពោធិ៍ជ្រៃ ។

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងរកឃើញថាជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងសម្រេចកាត់ទោសជនជាប់ចោទទាំងពីររូបឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ជនជាប់ចោទទាំងពីរប្តឹងសាទុក្ខទៅតុលាការកំពូលសុំឲ្យមោឃភាពសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងសម្រេចឲ្យរួចខ្លួនពីបទចោទទាំងអស់ ។ សហព្រះរាជអាជ្ញាប្តឹងសាទុក្ខសុំឲ្យតុលាការកំពូលប្រកាសថា ទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋរួមដែលហៅថា “សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣” គឺអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការកំពូលនឹងប្រកាសសាលដីកាស្ថាពរសម្រាប់សំណុំរឿង០០២ វគ្គ១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដើម្បី បិទបញ្ចប់សំណុំរឿងនេះ ។

ការជំនុំជម្រះលើសំណុំរឿង០០២ វគ្គ២ ចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបើកនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ។ អង្គហេតុចោទប្រកាន់នៅក្នុងសំណុំរឿងនេះរួមមាន ៖

◆អំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម និងវៀតណាម (ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើដែនដីវៀតណាមនោះឡើយ) ។

◆ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (នៅទូទាំងប្រទេស) ។

◆ការបោសសម្អាតផ្ទៃក្នុង ។

◆មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និង មន្ទីរសន្តិសុខភ្នំក្រោល ។

◆ការដ្ឋានសាងសង់ទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានលើកទំនប់ត្រពាំងថ្ម ។

◆សហករណ៍ត្រាំកក់ ។

◆ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និង

◆ការកំណត់គោលដៅមកលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តនេះត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានសាងសង់ទំនប់១មករា មន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់) ។

ការបង្ហាញភ័ស្តុតាងនៅក្នុងសំណុំរឿង០០២ វគ្គ២ ត្រូវគេរំពឹងថានឹងបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០១៦ ហើយការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់គឺនៅចុងត្រីមាសទី១ ឆ្នាំ២០១៧ ។ សាលក្រមសម្រេចសេចក្តីត្រូវបានគ្រោងរៀបចំចេញនៅខែធ្នូឆ្នាំ២០១៧ ។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងរង់ចាំយុត្តិធម៌អស់រយៈពេលជាង៣៧ឆ្នាំមកហើយ ។ សម្រាប់អ្នករស់រានមានជីវិតដែលរស់នៅក្នុងតំបន់ដាច់ស្រយាល គឺមានឧបសគ្គយ៉ាងខ្លាំងក្នុងការទទួលបានព័ត៌មានអំពីការសម្រេចសេចក្តីរបស់តុលាការកំពូល ។ ដើម្បីធានាថាសាធារណជនកម្ពុជានៅតំបន់ជនបទមានលទ្ធភាពទទួលបានព័ត៌មាន និងដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការកំពូលដែលប្រកាសនៅក្នុងសាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅរាជធានីភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងរៀបចំវេទិកាសាធារណៈតាមភូមិ និងផ្សាយបន្តផ្ទាល់ការប្រកាសនេះ ចំនួន៧កន្លែងនៅក្នុងប្រទេសកម្ពុជា ។ ទីតាំងទាំងនោះរួមមានៈ

១) វត្តគគីធំ ក្នុងស្រុកអង្គរបូរី ខេត្តតាកែវ

២) វត្តស្វាយទន្ទឹម ក្នុងស្រុករមាសហែក ខេត្តស្វាយរៀង

៣) ពោធិ៍បាន ក្នុងស្រុកកោះធំ ខេត្តកណ្តាល

៤) វត្តពេជដីរិស ក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

៥) វត្តចំការមួរ ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

៦) ទីរួមស្រុកកោះញែក ខេត្តមណ្ឌលគិរី

៧) វត្តថាឡា ក្នុងស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

ការរៀបចំវេទិកាសាធារណៈ និងការផ្សាយបន្តផ្ទាល់នេះ គឺដើម្បីផ្តល់ឱកាសឲ្យជនជាតិភាគតិច ប្រជាជនរងគ្រោះ អតីតយោធា និងកម្មាភិបាលខ្មែរក្រហម និងប្រជាជនរស់នៅតំបន់ដាច់ស្រយាលទទួលបានព័ត៌មានពេញលេញអំពីសេចក្តីសម្រេចរបស់តុលាការកំពូលលើសំណុំរឿង០០២ វគ្គ១ ។ បើពុំនោះសោតប្រជាជនទាំងអស់នោះនឹងមិនទទួលបានព័ត៌មានឡើយ ។ យើងរំពឹងថា វេទិកាសាធាណៈនីមួយៗនឹងមានប្រជាជនរាប់រយនាក់ ចូលរួម ។ អ្នកចូលរួមនឹងទទួលបានការធ្វើបទបង្ហាញសង្ខេបអំពីសំណុំរឿង០០២ វគ្គ១ មុនការប្រកាសរបស់តុលាការកំពូលដែលនឹងចាប់ផ្តើមនៅម៉ោង៩ព្រឹក ។ បន្ទាប់ពីតុលាការប្រកាសសេចក្តីសម្រេចរបស់ខ្លួនចប់ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន២នាក់នៅតាមទីតាំងនីមួយៗ នឹងរៀបចំឲ្យមានវេទិកាសាធារណៈមួយសម្រាប់អ្នកចូលរួម ដើម្បីឲ្យគាត់មានឱកាសបញ្ចេញយោបល់ប្រតិកម្ម និងទស្សនៈអំពីយុត្តិធម៌ ការជាសះស្បើយ និងការផ្សះផ្សា ។

កម្មវិធីផ្សាយបន្តផ្ទាល់នេះទទួលបានការគាំទ្រពីក្រសួងមហាផ្ទៃ, ការិយាល័យនៃកម្មវិធីពិភពលោក ការិយាល័យប្រជាធិបតេយ្យសិទ្ធិមនុស្ស និងការងារ, ក្រសួងការបរទេសសហរដ្ឋអាមេរិក, សហភាពអឺរ៉ុប, មូលនិធិរ៉ូបឺតបោះស៍ និងមជ្ឈមណ្ឌលសិទ្ធិមនុស្សអន្តរជាតិ, កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ), ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការប្រទេសស្វីស, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ក្រសួងអប់រំ យុវជន និង កីឡា និងក្រសួងទេសចរណ៍ ។ ថវិកាសម្រាប់អនុវត្តកម្មវិធីនេះឧបត្ថមដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ដើមបណ្តឹងរដ្ឋប្បវេណី : ខ្មែរក្រហមលុបបំបាត់ចោលទាំងស្រុងនូវអារម្មណ៍នៃទំនាក់ទំនងគ្រួសារ

ថ្ងៃនេះ ដើមបណ្តឹងរដ្ឋប្បវេណី ព្រែក សុខឹម បានចូលផ្តល់សក្ខីកម្មរបស់គាត់ ។ សុខឹម បានផ្តល់ព័ត៌មានអំពីរចនាសម្ព័ន្ធដឹកនាំក្នុងកងរបស់គាត់ ។ គាត់បានផ្តល់ព័ត៌មានលម្អិតបន្ថែម អំពីការរៀបការតាមបែបរៀបចំ និងការរំលោភបំពានពីសំណាក់ស្វាមីរបស់គាត់ ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណី ពីរក្រុមទៀតបានបន្តការធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួនអំពីអំពើអយុត្តិធម៌ និងការរងទុក្ខសោក ។ ដើមបណ្តឹងរដ្ឋប្បវេណី លោក គុល នឹម បានប្រាប់តុលាការថា លោកត្រូវបានចាប់បង្ខំឲ្យរៀបការ បើទោះបីជាលោកមានគូដណ្តឹងហើយក៏ដោយ ។ ប្រពន្ធរបស់លោកបានរលូតកូនចំនួនពីរដង ម្តងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយម្តងទៀតក្នុងឆ្នាំ១៩៧៩ ដែលលោកបានសន្មត់ថាបណ្តាលមកពីការធ្វើការហួសកម្លាំងរបស់ប្រពន្ធលោកក្នុងរបបនោះ ។ ជាចុងបញ្ចប់ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី ង៉ែត ឆាត បានផ្តល់ព័ត៌មានអំពីការចាប់ខ្លួន និងការគំរាមធ្វើឃាតស្វាមី និងគ្រួសាររបស់អ្នកស្រី ។ គាត់បានប្រាប់តុលាការថា គាត់ត្រូវបានចាប់ឲ្យរៀបការជាមួយបុរសផ្សេងទៀត បន្ទាប់ពីស្វាមីគាត់បានបាត់ខ្លួនអស់រយៈពេល ៣ ឬ ៤ ថ្ងៃ ។

**ព្រែក សុខឹម**




គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែសហមេធាវីការពារក្តីលោក ខៀវ សំផន អ្នកស្រី ហ្គីហ្សេ ។ សវនាការត្រូវបានប្រគល់ទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីធ្វើការវិនិច្ឆ័យលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី ព្រែក សុខឹម ។ ជំនួយការព្រះរាជអាជ្ញាជាន់ខ្ពស់ លោក វ៉ាំងសង់ ដឺ វ៉ាល់ បានសាកសួរអំពីអាយុរបស់ សុខឹម ។ លោក ដឺ វ៉ាល់ បាននិយាយថា ឆ្នាំនោះគឺប្រហែលជាឆ្នាំទី៥ រាប់ពីឆ្នាំ វក នៅពេលដែលលោកប៉ាន់ស្មានពីអាយុរបស់ សុខឹម ។ លោក ដឺ វ៉ាល់ បានសួរថា វាអាចទៅរួចដែរឬទេ ដែលថា សុខឹមមានអាយុ ៦០ឆ្នាំ មិនមែនអាយុ៦២ឆ្នាំ ។ សុខឹម បានតបថា គាត់មានអាយុ៦២ឆ្នាំ បើរាប់ពីឆ្នាំវក ។ គាត់មិនអាចចាំបានច្បាស់ទេថា គាត់មានអាយុប៉ុន្មានក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ ។ គាត់បានបន្តថាគាត់មានភាពចាស់ទុំបន្តិចក្នុងឆ្នាំ១៩៧៥ ។ សុខឹម ត្រូវបានចាប់អោយរៀបការ ប៉ុន្មានឆ្នាំបន្ទាប់នៅពេលដែលគាត់មានអាយុ១៨ឆ្នាំ ។ លោក ដឺ វ៉ាល់ បានសាកសួរថាតើ សុខឹម មានអាយុ១៨ឆ្នាំ នៅពេលដែលលោកស្រីរៀបការ ហើយកូនរបស់លោកស្រីបានកើតនៅពេលលោកស្រីមានអាយុ២០ឆ្នាំ ដូចអ្វីដែលលោកស្រីបានរៀបរាប់ក្នុងរបាយការណ៍សរសេរក្នុងបទសម្ភាសន៍មែនដែរឬទេ ។

## សមាសភាពនៃក្រុម

សុខឹម បាននិយាយថា ក្នុងកងរបស់គាត់មានជនជាតិចិនម្នាក់ តែគ្មានកូនក្មេង និងជនជាតិចាមទេ ។ ក្នុងកងមានជនជាតិចាមខ្លះ ប៉ុន្តែពួកគេមិនត្រូវបានចាត់ទុកជាជនជាតិចាមនោះទេ ។ ពួកគេមិនអនុញ្ញាតឲ្យគោរពប្រតិបត្តិសាសនារបស់ខ្លួនឡើយ ។ ពួកគេត្រូវតែបរិភោគអាហារដូចអ្នកផ្សេងដែរ ។ រ៉េត ត្រូវបានរៀបការជាមួយបុរសម្នាក់ឈ្មោះ សាន ប៉ុន្តែ រ៉េត មិនចាំថ្ងៃខែរៀបការរបស់ខ្លួនទេ ។ រ៉េត ថែមទាំងមិនដឹងថា សាន ជាឈ្មោះពិតរបស់ប្តី

គាត់ ឬក៏គ្រាន់តែឈ្មោះហៅក្រៅ ។ រ៉េត បានប្រាប់ សុខឹម ថា គាត់មិនដឹងអំពីការរៀបការទេ ដោយសារតែគាត់ត្រូវបានកោះហៅដោយមិនបានដឹងមុនពីការរៀបចំទុក ។

ដើមបណ្តឹងរដ្ឋប្បវេណី មិនបានទទួលការអប់រំផ្នែកបន្តពូជមុនពេលរៀបអាពាហ៍ពិពាហ៍ឡើយ ក្រៅពីឲ្យអ្វីដែលពួកគេប្រាប់ថា "គាត់គួរតែគេងជាមួយប្តីគាត់ ។ ពួកគេបានប្រាប់ សុខឹម ថា សុខឹម គួរតែស្លៀកសំពត់គេងពេលយប់ ប៉ុន្តែដោយសារតែគាត់គ្មានសំពត់ដូច្នេះគាត់ស្លៀកខោ ។

"ក្រោយពីខ្ញុំបានរៀបការ អារម្មណ៍របស់ខ្ញុំគឺមិនស្រណុកសោះ ។ សុខឹម ភ័យខ្លាចថា ប្តីគាត់ចាប់យកគាត់ទៅឆ្ងាយ និងសម្លាប់គាត់ចោល ម្យ៉ាងគាត់ខ្លាចប្តីគាត់រំលោភគាត់ ។

លោកដឺ វ៉ាល់ បានដកស្រង់សម្តីចេញពី សេចក្តីថ្លែងការណ៍របស់លោកស្រី សុខឹម នៅត្រង់ចំនុចដែល សុខឹម បាននិយាយថា គាត់គឺជា "កម្មសិទ្ធរបស់អង្គការ" ។ សុខឹម បានបកស្រាយថា ពួកគេបានហាមឃាត់មិនឲ្យគាត់ទៅណាដោយសេរី ហើយត្រូវតែបំពេញការងារ ។ លោកបានសួរលោកស្រី ពីសេចក្តីថ្លែងការណ៍ត្រង់ចំណុច ។ ទាហានបាត់បង់កាយសម្បទាក្នុងសង្គ្រាមអាចរៀបការជាមួយស្រីស្អាត ។ សុខឹម បាននិយាយថា គាត់មិនដែលចាប់អារម្មណ៍ឡើយរហូតដល់ក្រោយពេលរៀបការទើបគាត់ដឹងថាប្តីគាត់ពិការដៃ "បើមិនអ៊ីចឹងខ្ញុំប្រហែលជាអាចគេងលក់" ។ បន្ទាប់មក លោក ដឺ វ៉ាល់ សាកសួរអំពី ព្រឿង ។ អ្នកស្រី ព្រែក សុខឹម បានរាយរ៉ាប់ថា ព្រឿង បានបដិសេធរៀបការជាមួយបុរសដែលគាត់ត្រូវរៀបការជាមួយ ។ ប្រជាជនបាននិយាយថា ព្រឿង ត្រូវបានចាប់ដាក់រទេះ ។ បន្ទាប់ពីបានឮដូច្នោះ ពួកយើងមិនហ៊ានមាត់កឡើយ ។ សុខឹម មិនបានធ្វើជាសាក្សីនៃការចាប់ខ្លួនរបស់ ព្រឿង ដោយផ្ទាល់ទេ ។ មានរឿងខ្លះ ដែលប្រជាជនបានស្នើទៅអង្គការ ប៉ុន្តែអង្គការបានប្រានចោលសំណើទាំងនោះ ។

អឿន មានរូបរាងធំមាំតែ "រូបសម្បត្តិ" មិនសូវស្អាត ។ ក្រោយពេលរៀបការ គាត់ និងប្រពន្ធគាត់មិនបានរួមមេត្រីទេ ហើយបានគេងដាច់ដោយឡែកពីគ្នាម្នាក់គេងក្នុងអង្រឹង ម្នាក់គេងលើគ្រែ ។ ដំណឹងនេះបានលេចឮដល់អង្គការ ហើយអឿន និងប្រពន្ធគាត់ត្រូវបានយកទៅអប់រំ ។

លោកដឺ វ៉ាល់ បានសួរពីសេចក្តីថ្លែងការណ៍ដែលថា ប្តីប្រពន្ធមួយគូរនេះត្រូវបានគេតាមដាន ។ សុខឹម បានតបថា គាត់បានជួបមាន តែមិនបានជួប អឿន ទេ ។

សុខឹម បាននិយាយថា កាលពីពេលនោះ មានមនុស្សជាច្រើនត្រូវបានសម្លាប់ ។ គាត់ដឹងតែអំពីសមមិត្ត ព្រឿង និង សមមិត្ត យឿន ត្រូវបានយកទៅសម្លាប់ ។ ស្ត្រីម្នាក់មានប្តីធ្លាប់បួសជាសង្ឃក៏ត្រូវបានយកទៅសម្លាប់ចោលដែរ ។ ទោះបីជាយ៉ាងនេះក្តីប្តីរបស់ស្ត្រីម្នាក់នោះត្រូវបានដោះលែងមកវិញ ។ "ដំបូងគេសម្លាប់ប្រពន្ធទុកប្តី ប៉ុន្តែក្រោយមកគ្រប់គូ ទាំងប្តី និងប្រពន្ធត្រូវបានគេសម្លាប់" ។ ស្ត្រីដែលធ្លាប់មានប្តីជាអតីតសង្ឃមានឈ្មោះថា ចៀន ប៉ុន្តែគាត់មិនច្បាស់ពីរឿងនេះទេ ។ ប្តីប្រពន្ធមួយគូនេះរស់នៅមិនចុះសម្រុងនឹងគ្នាឡើយ ។ ក្រោយពីពេលដែលប្រពន្ធត្រូវបានចាប់ទៅបាត់ ប្តីបានច្រៀងចម្រៀង "ចាបកំព្រាហើរតែឯង" ។ ពេលគេសួរ ចៀន ថាហេតុអ្វីបានជាគាត់ច្រៀងចម្រៀងនោះគាត់ឆ្លើយថាប្រាប់គេថា ដោយសារតែគេចាប់ប្រពន្ធគាត់ទៅ ហើយគាត់មានអារម្មណ៍កណ្តោចកណ្តែង ។ ក្រោយមក ចៀន ក៏ត្រូវបានចាប់ទៅដែរ ។ លោកដឺ វ៉ាល់ បាននិយាយថា អ្នកស្រីបាននិយាយពីឈ្មោះ វិន ក្នុងសេចក្តីថ្លែងការណ៍របស់គាត់ ។

ក្រោយពីគូរស្រករបានរៀបការ ភាគច្រើនពួកគេរស់នៅចុះសម្រុងនឹងគ្នា ពីព្រោះពួកគេគិតថាពួកគេត្រូវបានរៀបចំដោយអង្គការ ដូច្នេះពួកគេត្រូវតែរស់នៅជាមួយគ្នា ដោយភាពសុខសប្បាយ ។ មានមួយចំនួនតូចដែលរស់នៅមិនចុះសម្រុងនឹងគ្នា ។ "ក្នុងករណីបែបនេះ ប្រជាជនបានបដិសេធនឹងការរៀបការ" ម្តាយរបស់ សុខឹម បាននិយាយជាមួយគាត់នៅក្រោយរោងថា សុខឹម ត្រូវតែរៀបការ ។ សុខឹម បានប្រាប់ម្តាយរបស់គាត់ថា គាត់ភ័យខ្លាចប្តីទី២របស់គាត់ និងបំផ្លាញជីវិតគាត់ម្តងទៀត ហើយគាត់ខ្លាចថាបុរសម្នាក់នោះជាអ្នកញៀនល្បែង ។ ម្តាយគាត់បន្តថា គាត់ចង់ចូលរួមមង្គលការរបស់កូនស្រីគាត់នាពេលនោះ ដោយសារតែគាត់ខកខានមិនបានចូលរួម "មង្គលការលើកទីមួយ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានអាចារ្យនោះទេ ដូច្នេះគឺមានភាពខុសប្លែកពីប្រពៃណី ។ ពិធីរៀបការលើកទីពីរគឺត្រូវបាន

រៀបចំតាមបែបបទប្រពៃណី ដូច្នេះវាធ្វើឲ្យ សុខឹម មានអារម្មណ៍ធូរស្រាល ។ មង្គលការរបស់ សុខឹម ត្រូវបានចូលរួមដោយភ្ញៀវជាច្រើនរយនាក់ ហេតុនេះគាត់មានទំនុកចិត្តលើមង្គលការនេះ ។

## ទាហានលន់ នល់

អ្នកស្រី សុខឹម បានរ៉ាយរ៉ាប់ថា ក្នុងឆ្នាំ១៩៧៣ ខេត្តកំពង់ធំត្រូវបានកាន់កាប់ ។ ទាហានត្រូវបានបញ្ជូនទៅកាន់តំបន់នោះ "មានអណ្តូងមួយដែលត្រូវបានប្រើប្រាស់ក្នុងពិធីសាសនា ។ មានសាកសពជាច្រើនត្រូវបានរកឃើញនៅក្នុងនោះ ។ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានស្វែងរកទាហានជាប់ពាក់ព័ន្ធនឹងលន់ នល់ ។ បងប្រុសរបស់ សុខឹម ដែលជាទាហាននៅក្រោមរបបលន់នល់ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។ ប្រពន្ធរបស់បងប្រុសគាត់ក៏ត្រូវបានគេចាប់ និងសម្លាប់ចោលដូចគ្នាដែរ ។ បងប្រុសរបស់ សុខឹម គឺជាអតីតទាហាន លន់ នល់ នៅខេត្តកំពង់ចាម ។ នៅពេលដែលគាត់ត្រូវបានជម្លៀសទៅកាន់ស្រុកកំណើតរបស់គាត់ គាត់ត្រូវបានគេតាមរក និងសម្លាប់ចោល ។ ក្នុងឆ្នាំ១៩៧៧ គាត់ត្រូវបានគេចាប់យកទៅសម្លាប់បាត់ទៅហើយ ។ សុខឹម បានព្រួថា ឪពុកគាត់ក៏ត្រូវបានយកទៅសម្លាប់ដែរ ។ ដោយសារតែអ្នកស្រីមានជំងឺ អ្នកស្រីមិនត្រូវបានគេចាប់អារម្មណ៍ទេ ។ ឪពុក និងបងប្អូនរបស់ សុខឹម ត្រូវបានយកទៅសម្លាប់ ។ "ប្រសិនបើខ្ញុំមិនឈឺ ហើយមិនត្រូវគេអើពើ ខ្ញុំប្រហែលជាត្រូវគេចាប់យកទៅសម្លាប់ដែរហើយ" ។

## របនាសម្ព័ន្ធគ្រប់គ្រង

វេទិកាបន្ទាប់ត្រូវបានផ្តល់ឲ្យក្រុមមេធាវីការពារលោក នួន ជា ។ សហមេធាវីការពារក្តីជាតិ លោក លីវ សុវណ្ណា បានសាកសួរអំពី ព្រឿង ។ សុខឹម បានតបថា គាត់ស្គាល់ តែមនុស្សម្នាក់ឈ្មោះ ព្រឿង ដែលជិតស្និទ្ធនឹងគាត់ប៉ុណ្ណោះ ។ ក្នុងកងធំមួយមានកងតូចៗចំនួន៣រួមបញ្ចូលគ្នា ។ មានប្រជាជនរស់នៅជាមួយគ្នាចំនួន៩៦នាក់ ។ ក្រោយពេល ព្រឿង បានផ្ទេរមក គៅ បានតែងតាំង ព្រឿង ជាប្រធានកង ។

បន្ទាប់មក លោក សុវណ្ណា បានសួរពីមនុស្សម្នាក់ឈ្មោះ លី ។ សុខឹម បានតបថា មានមនុស្សពីរនាក់ស្រីមួយ ប្រុសមួយមានឈ្មោះ លី នៅកងផ្សេង ។ ប៉ុន្តែក្នុងកងរបស់គាត់គ្មានឈ្មោះ លី នោះទេ ។ គាត់ស្គាល់ រីន ជាអ្នកទទួលបន្ទុកធំក្នុងកង ។ រីន ត្រូវបានចាប់យកទៅសម្លាប់ ។ លោកស្រី សុខឹម ទទួលខុសត្រូវលើមនុស្សចំនួន១២នាក់ក្នុងកងរបស់គាត់ ។

លោក សុវណ្ណា បានសួរថា ហេតុអ្វីបានជាក្នុងសំណុំឯកសាររបស់អ្នកស្រី ព្រឿង គឺជាប្រធានកង ចំណែក លី គឺជាអនុប្រធានទៅវិញ ។ អ្នកស្រី សុខឹម បានតបថា លី ទទួលបន្ទុកបញ្ហាទូទៅក្នុងកងធំ ដោយឡែក ព្រឿង គឺជាប្រធានកងដែលគ្រប់គ្រងលើអ្នកស្រីដោយផ្ទាល់ ។ ទី គឺជាអនុប្រធានដែលគ្រប់គ្រងលើអ្នកស្រីផងដែរ ។ លោក សុវណ្ណា បានសួរសំណួរដដែល ចំណែកឯ សុខឹម ក៏បានផ្តល់ចម្លើយដដែលដែរ ។ លោក សុវណ្ណា បានសួរអំពីតួនាទីរបស់ រិន ក្នុងកង ។ អ្នកស្រីបានឆ្លើយថា រិន គឺជាប្រធានកង ប៉ុន្តែមិនមែនជាប្រធានកងរបស់គាត់ទេ ។

លោក សុវណ្ណា បានសួរថាតើ គូស្រករខ្លះដែលជាគូដណ្តឹងនឹងគ្នា បានស្នើសុំអង្គការរៀបការដែរឬទេ? សុខឹម បានឆ្លើយថា មានតែមួយគូប៉ុណ្ណោះដែលបានស្នើគឺ ព្រំ និង ចិន សំណាង ។ ព្រំ មានតួនាទីខ្ពស់ដូច្នេះគាត់អាចស្នើសុំដើម្បីរៀបការបាន ។

លោក សុវណ្ណា បានសួរថាតើមានគូខ្លះបដិសេធចូលរួមពិធីមង្គលការដែរឬទេ ។ លោកស្រីបានបន្តថា ពួកគេបានធ្វើតាមអង្គការគ្រប់ជំហ៊ាន ទាំងដែលមិនបានដឹងអំពីព័ត៌មានទាំងស្រុង ។ សុខឹម ត្រូវបានគេផ្តល់សម្លៀកបំពាក់ឲ្យនៅពេលដែលគាត់បានដឹងថា គាត់នឹងត្រូវគេបញ្ជូនឲ្យទៅរៀបការ ។ "ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវបានគេប្រមូលទៅជាមួយប្រជាជនដទៃទៀតដើម្បីបញ្ជូនចេញទៅសម្លាប់ ។ ខ្ញុំមិនដែលគិតសូម្បីតែបន្តិចថា ខ្ញុំត្រូវបានគេចាប់បង្ខំឲ្យរៀបការ" ។ នេះបញ្ជាក់ថា សុខឹម មិនបានធ្វើការបដិសេធអ្វីទាំងអស់ ។

នៅក្នុងពិធីនោះ ពួកគេអង្គុយនៅតុវែង និងមានសុន្ទរកថាមួយ ។ "ពិតណាស់ សុន្ទរកថា ពិតជាពិរោះស្តាប់" ។ ពួកគេហៅសមមិត្ត កែវ និង ចៅ ដើម្បីមកផ្គូរផ្គងពួកគេទាំងពីរ ។

សុខឹម ចង់ដឹងពីអនាគតស្វាមីរបស់ខ្លួន ។ សុខឹម ត្រូវបានប្រាប់ថា ប្តីរបស់គាត់ដើរមិនត្រង់ផ្លូវឡើយ នៅពេលនោះហើយដែលគាត់ដឹងថា ប្តីរបស់គាត់ពិការជើងម្ខាង ។ ប្តីរបស់គាត់មិនអាចលាម្រាមដៃចំនួន៣បានទេ ។ ស្ត្រីផ្សេងទៀតបាននិយាយថា ប្តី

របស់ សុទឹម មានជំងឺខ្វាក់មាន់ ។ មកដល់ចំណុចនោះ ទើប សុទឹម ដឹងថា ប្តីរបស់គាត់ពិការ ។

**ប្តីពិការ**

លោក សុវណ្ណា បានជជីកសួរ ថាតើមិត្តភក្តិរបស់អ្នកស្រី ដែលចំអន់នឹងប្តីរបស់អ្នកស្រីដែរឬទេ ដោយសារតែប្តីអ្នកស្រីជាមនុស្សពិការ ។ សុទឹម បានតបថា ពួកគេមានចិត្តអាណិតគាត់ ដែលដឹងថាគាត់មានស្វាមីជាជនពិការ ។ សុទឹម បានកត់សម្គាល់ថា ស្រ្តីដែលបានរៀបការថ្ងៃតែមួយជាមួយគាត់សុទ្ធតែយំតាមគាត់ ហើយ“ខ្ញុំមិនដឹងថាមានហេតុផលអ្វីបានជាគេយំនោះទេ” ។ គាត់មិនបានដឹងថា ព្រំ យុន បានរៀបការថ្ងៃតែមួយជាមួយគាត់ឬយ៉ាងណាទេ ដោយសារតែគាត់ស្ថិតនៅមន្ទីរខុសគ្នាពីគាត់ ។ លោក សុវណ្ណា បានសួរថា សុទឹម គិតថា តើពួកគេយំដោយសារតែពួកគេគិតថា មានភាពតក់ស្លុត និងភាពភ័យខ្លាចថាពួកគេនឹងត្រូវយកចេញទៅឆ្ងាយ ឬក៏ពួកគេនឹងត្រូវរៀបការ ។ ស្រ្តី២-៣នាក់បានបង្ហូរទឹកភ្នែកជិត សុទឹម ដោយមិនដឹងថាពួកគេនឹងត្រូវចាកចេញទៅទីកន្លែងណា ។ នៅពេលពួកគេកំពុងយំ រិន បានចូលមកប្រាប់ពួកគេថា ពួកគេត្រូវបានរៀបចំឲ្យរៀបការ ។

នៅពេលដែលពួកគេបញ្ជាឲ្យរៀបការ សុទឹម មិនហ៊ានជំទាស់នឹងការសម្រេចចិត្តនោះទេ ពីព្រោះគាត់ខ្លាចត្រូវគេសម្លាប់ ប្រសិនបើគាត់ធ្វើដូច្នោះ ។ “ខ្ញុំគ្មានជម្រើសអ្វីផ្សេងក្រៅពីយំនោះទេ” ។ សុទឹម បានប្រាប់ប្តីគាត់កុំឲ្យប៉ះពាល់គាត់ “ខ្ញុំធ្វើតាមបណ្តាំឪពុករបស់ខ្ញុំ” ។ ឪពុកខ្ញុំប្រាប់ខ្ញុំថា “កុំឲ្យប្រុសណាប៉ះកូន លើកលែងតែបុរសនោះត្រូវបានរៀបចំឲ្យរៀបការជាមួយកូនដោយពួកគាត់” ។

មានករណីប្រជាជនជាច្រើនដែលត្រូវបានសម្លាប់ មុន រិន ទៅទៀត ។ នេះគឺជាហេតុផលដែល សុទឹម មានអារម្មណ៍ភ័យខ្លាច ។ គាត់មិនបានឃើញការសម្លាប់ប្រជាជនទាំងនោះទេ ប៉ុន្តែពួកគេបានបាត់ខ្លួន ។ សមមិត្ត ព្រឿង បានរៀបការមុនសុទឹម ។ គាត់មិនចាំទេថា រិន បានរៀបការប៉ុន្មានខែមុនគាត់ ។ រិន នៅទីនោះពេលដែលអ្នកស្រី សុទឹម រៀបការ ប៉ុន្តែក្រោយមក រិន ត្រូវបានគេចាប់យកទៅ ។ អ្នកស្រីមិនបានប្រាប់ខ្មែរក្រហមថា គាត់មិនបានរស់នៅចុះសម្រុងជាមួយប្តីនោះឡើយ ។

**ការរំលោភ**

សមមិត្ត តាវ បានធ្វើជាប្រធានក្នុងអង្គប្រជុំមួយ ។ តាវ បាននិយាយថា អ្នកណាក៏ដោយដែលត្រូវបានរៀបចំឲ្យរៀបការ គឺត្រូវតែធ្វើតាមបទបញ្ជារបស់អង្គការ ។ អ្នកស្រីមិនបានដឹងថា រិន ត្រូវបានចាប់ខ្លួននោះទេ ។ តាវ បានលើកឡើងពីអវត្តមានរបស់ រិន ក្នុងកិច្ចប្រជុំ ។ ប្រជាជនខ្លះបានសន្និដ្ឋានថា រិន បាត់ខ្លួនដោយសារគាត់រស់នៅមិនចុះសម្រុងជាមួយប្តីគាត់ ។

សុទឹម យំនៅពេលដែលគាត់បានឮដំណឹងថា គាត់ត្រូវបានរៀបចំឲ្យរៀបការ ។ ប្រសិនបើគាត់ដឹងថា គាត់នឹងត្រូវរៀបចំឲ្យរៀបការជាមុន គាត់ប្រហែលជាអាចគេចផុត ។

លោក សុវណ្ណា បានបន្តនិង សាកសួរអំពីសមមិត្ត ព្រឿង ។ សុទឹម បានតបថា មានស្រ្តីម្នាក់បានរត់គេច ហើយពួកគេចាប់គាត់បានមកវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ ម្នាក់នោះមិនមែនជាសមមិត្ត ព្រឿង ទេ ។ លោក សុវណ្ណា បានបន្តថា វាមានភាពផ្ទុយពីសេចក្តីថ្លែងការណ៍ ដោយសារតែ សុទឹម បានរម្លឹកពីស្រ្តីម្នាក់មានឈ្មោះ ព្រឿង ដែលមិនបានរស់នៅចុះសម្រុងជាមួយប្តីគាត់ ហើយក្រោយមកបានរត់គេចទៅបាត់ ។

លោក សុវណ្ណា បានសួរពីគូស្វាមីភរិយាមួយចំនួនដែលបានចូលរួមពិធីមង្គលការរបស់ សុទឹម ដោយសារតែម្តង សុទឹម បាននិយាយថា មានគូស្វាមីភរិយាចំនួន១៥គូ បានចូលរួមពិធីមង្គលការគាត់ ហើយក្រោយមកគាត់ថា មាន១២គូ ។ សុទឹម បានតបថា គាត់ប្រហែលជាមិនបានចាប់អារម្មណ៍ ហើយគាត់ក៏បានសូមធ្វើការអភ័យទោសពីសំណាក់ភ្ញៀវចូលរួមផងដែរ ។ សុទឹម ប្រហែលជាមិនមានការប្តេជ្ញាចិត្តក្នុងពិធីមង្គលការឡើយ ។ លោក សុវណ្ណា បាននិយាយថា សុទឹម មិនបានធ្វើការប្តេជ្ញាចិត្តក៏ពិតមែន តែគាត់បាននិយាយក្នុងសេចក្តីថ្លែងការណ៍របស់គាត់ថា គាត់បានធ្វើការប្តេជ្ញាចិត្ត ។ សុទឹម បានប្រកែកថា គាត់មិនបានធ្វើការប្តេជ្ញា ប៉ុន្តែមានមនុស្សម្នាក់តំណាងឲ្យក្រុម បានធ្វើការប្តេជ្ញាចិត្ត ។ សុទឹម រៀបអាពាហ៍ពិពាហ៍ចំពេលដំណាំកប្បាសអាចប្រមូលផល ដូច្នេះគាត់ប៉ាន់ស្មានថាប្រហែលជាក្នុងអំឡុងខែវិច្ឆិកា ឬខែធ្នូ ចំថ្ងៃពេញបូរណ៌មី ។ វាប្រហែលជានៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ ។ លោក សុវណ្ណា បាននិយាយថា សុទឹម ប្រហែលជាមិនបានរម្លឹកទេ

ថា គាត់ត្រូវបានគេតាមដាន ហើយគាត់ប្រហែលជាត្រូវរស់នៅចុះសម្រុងជាមួយប្តីគាត់តាំងពីមុនពេលគាត់គេងជាមួយប្តីគាត់មកម្ល៉េះ ។ លោក សុវណ្ណ បានសួរថា ហេតុអ្វី សុខឹម មិនបានរម្លឹកថាគាត់ត្រូវបានគេតាមដានក្នុងឯកសារ តែរម្លឹកក្នុងតុលាការ ។ សុខឹម បាននិយាយថា គាត់ត្រូវបានគេសួរដើម្បីឲ្យបកស្រាយព័ត៌មានលម្អិតនៅចំពោះមុខតុលាការ នេះជាហេតុផលដែលគាត់លើករឿងនេះឡើងឥឡូវនេះ ។ សុខឹម បាននិយាយថា "ខ្ញុំបាននិយាយកុហកសេនាជនច្រើនណាស់" ដូច្នេះទើបអាចចេញពីផ្ទះបាន ។ "នៅពេលគាត់មកលេងខ្ញុំ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំអស់កម្លាំងណាស់ បន្ទាប់មកគាត់ដាក់ដៃគាត់លើខ្លួនខ្ញុំ" ។

## ភាពមិនស៊ីសង្វាក់គ្នា

លោក សុវណ្ណ បាននិយាយថា សុខឹម បាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា ប្តីរបស់គាត់ដេញតាមគាត់ដល់ក្នុងផ្ទះ តែមុននេះបន្តិចគាត់បាននិយាយថា ពេលគាត់កំពុងគេងលក់ប្តីរបស់គាត់បានចាប់ផ្តើមប៉ះពាល់គាត់ ។ សុខឹម បានតបថា ប្តីគាត់ចាប់ផ្តើមរំលោភគាត់នៅពេលដែលគាត់កំពុងដេកលក់ ។ ប្តីរបស់គាត់បានព្យាយាម ដោះលេវអាវគាត់ ហើយនៅពេលដែលប្តីគាត់ព្យាយាមដោះអាវទ្រនាប់គាត់ចេញ នៅពេលគន្លឹះរបូតប្តីគាត់ទាញអាវគាត់ចេញ ។ កាលពីយប់ដំបូង ប្តីគាត់មិនបានធ្វើអ្វីគាត់ឡើយ ។

លោក សុវណ្ណ បាននិយាយថា សុខឹម មិនបានរម្លឹកពីការរំលោភក្នុងឯកសារមួយក្នុងចំណោមឯកសារផ្សេងទៀត ។ លោក សុវណ្ណ បានអានឯកសារផ្សេងទៀតដែល សុខឹម មិនបានលើកឡើងពីការរំលោភ ។ សុខឹម បាននិយាយថា គាត់មិនបានលើកឡើងពីការរំលោភដោយសារតែ "នៅតែមានភាពអៀនខ្មាសអំពីបញ្ហានេះ" ។ សុខឹម បានពន្យល់ថា "ខ្ញុំមិនចង់និយាយពីបញ្ហាផ្ទៃក្នុងរបស់ខ្ញុំនោះទេ" ។

សុខឹម មិនចាំថា អ្នកណាជាអ្នកបំពេញបែបបទរបស់គាត់នៅ អង្គការ អាដ ហុក (Ad Hoc) នោះទេ ហើយក្រោយមកគាត់បាននិយាយទៅកាន់ លោក ឆាំង យុ ។ ក្រោយមកគាត់ត្រូវបានប្រាប់ថាឲ្យយករឿងនិយាយចេញក្រៅ និងមិនត្រូវមានភាពអៀនខ្មាសអំពីអំពើរំលោភសេពសន្ថវៈឡើយ ។ "ខ្ញុំត្រូវបានប្រាប់ថាប្រសិនបើខ្ញុំអៀនខ្មាស ប្រាកដជាគ្មានអ្វីធ្វើជាភ័ស្តុតាងនោះទេ" ។

សុខឹម បាននិយាយថា ប្តីរបស់គាត់មិនមែនជាមនុស្សឃោរឃៅទេ ។ "ប្រសិនបើគាត់ជាមនុស្សឃោរឃៅ ប្រហែលជាគាត់រំលោភខ្ញុំតាំងពីយប់ដំបូងមកម្ល៉េះ" ។ សុខឹម និយាយបែបនេះគឺចង់បញ្ជាក់ថា ប្តីរបស់គាត់ជាមនុស្សស្អាតស្អំ ។

លោក កូប៉េ បាននិយាយថា សុខឹម មិនបាននិយាយអ្វីទាំងអស់អំពីការរំលោភ និងអំពីពេលដែលពួកគេបានប្រាប់ សុខឹម ឲ្យរួមមេត្រី ឬអំពីការដែលមានគេតាមដានគាត់ ។ លោក កូប៉េ បានសួរថា ហេតុអ្វីបានជាមានករណីនេះ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ម៉ារី ហ្គីរ៉ូដ បានក្រើនរម្លឹកតុលាការថា ឯកសារគ្មានសភាពដូចគ្នាឡើយ ។ មានការពិភាក្សាខ្លីមួយជាមួយចៅក្រម ខ្លូឌៀ ហ្វេនស៍ ដែលជាអ្នករម្លឹកតុលាការថា សំណួរត្រូវបានឆ្លើយរួចហើយ ដូច្នេះ លោក កូប៉េ គួរតែសួរសំណួរផ្សេងវិញ ដូចដែលអ្វីដែលគាត់បានសួរក្នុងសំណួរនាំមុខ ឬដូចដែលអ្វីដែលគាត់បានបង្ហាត់ដោយអ្នកគ្រប់គ្នាដឹង ។

លោក កូប៉េ បាននិយាយថា កត្តានេះឈានទៅរកសំណួរដែលថា សុខឹម ប្រហែលជាអាចបង្វឹកដោយ អង្គការ អាដ ហុក ឧទាហរណ៍ លោក កូប៉េ បានសួរ សុខឹម ថាហេតុអ្វីបានជា សុខឹម និយាយថាប្តីរបស់គាត់ជាមនុស្សល្អ ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក្រោយមកមានរឿងផ្សេងទៀតក្នុងថ្ងៃនេះ ។ សុខឹម បានតបថា គាត់បាននិយាយថា ប្តីរបស់គាត់ជាមនុស្សល្អ ។ "ប្រសិនបើគាត់ជាមនុស្សឃោរឃៅ ប្រហែលជាគាត់រំលោភខ្ញុំតាំងពីយប់ដំបូងមកម្ល៉េះ" ។

សុខឹម ត្រូវបានសួរនាំពីសំណាក់ប្តីគាត់ក្រោយពេលរៀបការ ថាហេតុអ្វីបានជាគាត់ព្យាយាមរក្សាព្រហ្មចារី ចាប់តាំងពីពួកគេបានរៀបការជាមួយគ្នាមក ។ លោក កូប៉េ បានសួរថាតើមានអ្នកណាអាចបញ្ជាក់រឿងនេះ ដែល សុខឹម បានបដិសេធមិនបញ្ជាក់បានដែរឬទេ ។ សុខឹម បានបកស្រាយថា សំណួរដែលត្រូវបានសួរក្នុងតុលាការ ដូច្នេះចម្លើយក៏ត្រូវបានផ្តល់នៅតុលាការដូចគ្នាផងដែរ ។ "គ្មាននរណាម្នាក់បង្ខំគាត់ឲ្យផ្តល់ចម្លើយនោះទេ" ។

## រចនាសម្ព័ន្ធគ្រប់គ្រង

សុខឹម បាននិយាយថា ព្រឿង គឺជាប្រធានកងធំ ហើយ លី គឺជាប្រធានកង ចំណែកគាត់គឺជាអ្នកដឹកនាំក្រុម ។ សុខឹម គឺជា

សមាជិកកងធំ ។ គាត់មិនចាំទេថា ឆ្នាំណាដែលគាត់ត្រូវបានគេចាត់តាំងជាសមាជិកកងធំទេ ។ សុខឹម គឺជាសមាជិកដឹកនាំកងធំជាមួយនឹង ព្រឿង និង លី ។

កងទាំងនោះគឺគ្មានចំនួនសមាជិកចាត់តាំងឡើយ ។ កងទាំងនោះសំដៅទៅលើកងរបស់ ព្រឿង និងកងរបស់ លី ឧទាហរណ៍ សមមិត្ត លី ធំជាង សមមិត្ត ព្រឿង ។ លី ទទួលខុសត្រូវលើនារីៗទាំងអស់ក្នុងស្រុកកំពង់ព្រលឹង ។ សមមិត្ត លី និងសមមិត្ត ស ចាត់ចែងការងារឲ្យពួកគេ ។ ពួកគេសំដៅទៅលើអង្គការ ប៉ុន្តែ សុខឹម មិនដឹងថាអង្គការមានប្រភពពីណាទេ ។ អ្នកស្រី សុខឹម បាននិយាយថា គាត់មិនដែលបន្ទោសសមាជិកកងរបស់គាត់ទេ ប្រសិនពួកគេមិនអាចបំពេញការងារបាន ។ សុខឹម បាននិយាយថា ក្នុងកងគាត់គ្មាននរណាម្នាក់មានកំហុសនោះទេ ។ “ថ្វីបើពួកគេខ្ជិលច្រអូស ឬឈឺស្កាត់បន្តិចមែន ប៉ុន្តែគាត់មិនដែលរាយការណ៍ទៅថ្នាក់លើនោះទេ” ។ សុខឹម ព្យាយាមលើកទឹកចិត្តពួកគេឲ្យពួកគេឆាប់សះស្បើយពីជំងឺ ។ គាត់មិនដែលបង្អត់អាហារអ្នកណាម្នាក់ឡើយ ហើយរបបអាហារគឺត្រូវរៀបរាប់ដូចពីខាងដើម ។ កន្លែងដែលពួកគេធ្វើការមានចម្ងាយ៥០០ម៉ែត្រ ហើយកន្លែងខ្លះទៀតមានចម្ងាយ២គីឡូម៉ែត្រឯណោះ ។ នៅក្នុងរយៈពេលដំបូង ពួកគេបេះកប្បាសនៅកន្លែងដែលជិតភូមិ ប៉ុន្តែក្រោយមកទៀត ពួកគេត្រូវបានចាត់ឲ្យទៅធ្វើការនៅកន្លែងឆ្ងាយៗ ។

### ពេលវេលា

សុខឹម ចាំមិនបាននោះទេថា ថ្ងៃមង្គលការរបស់គាត់ត្រូវនឹងថ្ងៃអ្វី នៅក្នុងប្រតិទិនអន្តរជាតិ ប៉ុន្តែគាត់អាចប៉ាន់ស្មានបានថា វាប្រហែលជានៅក្នុងខែតុលា ខែវិច្ឆិកា ឬខែធ្នូ ផងក៏មិនដឹង ។ តាមការចងចាំរបស់ សុខឹម វាប្រហែលជានៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ ។ កូនរបស់គាត់បានចាប់កំណើតនៅក្នុងរបបនេះ ប៉ុន្តែគាត់មិនចាំថា នៅពេលណានោះទេ ។ សុខឹម និយាយថា វាប្រហែលជានៅខែធ្នូ ឬខែមករា ។ គាត់បានបង្កើតកូននេះនៅក្នុងរដូវប្រមូលផលស្រូវរដូវប្រាំង កូនរបស់គាត់មានអាយុប្រហែល ១ខួប នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ ។ សុខឹម នឹកមិនឃើញនោះទេថា វានៅខែណាឆ្នាំណាឲ្យប្រាកដ ប៉ុន្តែគាត់នៅចាំថា ពួកគាត់ត្រូវបានអនុញ្ញាតឲ្យជួបគ្នា៤ដង ។ មួយខែក្រោយមក គាត់ត្រូវបានហៅឲ្យទៅជួបប្តីរបស់គាត់ដោយយកលេសថា ប្តីរបស់គាត់ឈឺ ។ គាត់បានប្រាប់ទៅពួកគេថា គាត់មិនចង់ទៅតែឯងនោះទេ ដូច្នេះពួកគេបានឲ្យ សុជាតិ ទៅជាមួយគាត់គ្រាន់បានជាគ្នា ។ សុខឹម ទៅទីនោះបន្ទាប់ពីពេលដែលគេប្រមូលផលស្រូវរួច ។

លោក សោម អូន បានសួរថា តើអ្នកណាជាអ្នកបញ្ជាឲ្យគាត់រួមរស់ជាមួយប្តីគាត់? សុខឹម បានព្យាយាមការពារខ្លួនគាត់ពីការរួមដំណេកជាមួយប្តីគាត់ ។ “គិតអំពីការចាប់រំលោភដែលបានកើតឡើង ប្តីរបស់គាត់បានព្យាយាមពន្យល់ប្រាប់គាត់ថា ប្រសិនបើពួកគាត់ទាំងពីរមិនផ្សំដំណេកនោះទេ ពួកគាត់នឹងមានបញ្ហាមិនខាន” ។ សុខឹម បានបញ្ជាក់បន្ថែមថា គ្មាននរណាម្នាក់បញ្ជាឲ្យពួកគាត់ផ្សំដំណេកនោះទេ ក៏ប៉ុន្តែ ដោយសារតែគាត់បានបាត់បង់ព្រហ្មចារីរួចទៅហើយ ម្យ៉ាងទៀត ពួកគាត់បានរៀបការជាមួយគ្នាទៅហើយ ដូច្នេះពួកគាត់គួរតែរួមរស់ជាមួយគ្នា ។ “ពួកយើងទាំងពីរនាក់គួរតែរស់នៅជាមួយគ្នាឲ្យដូចប្តីប្រពន្ធ គ្មាននរណាម្នាក់បង្ខំយើងនោះទេ” ។ ប្តីរបស់គាត់បានព្យាយាមលួងលោមគាត់ដោយនិយាយថា អង្គការតម្រូវឲ្យពួកគាត់រស់នៅជាមួយគ្នា ដូច្នេះពួកគាត់ត្រូវតែនៅជាមួយគ្នា ។

លោក សោម អូន បានសួរអំពីមនុស្សម្នាក់ដែលមានឈ្មោះថា តាវ ។ គាត់បានរៀបរាប់ថា នៅពេលដែលអង្គភាពទើបតែបង្កើតឡើងដំបូង មិនមានវត្តមាន តាវ នោះទេ ។ តាវ បានលេចវត្តមានឡើងនៅពេលដែលមនុស្សម្នាត្រូវបានចាប់ខ្លួន ។ “នៅពេលដែល តាវ មកដល់មនុស្សគឺឃោរឃៅណាស់” ។ តាវ មានវត្តមាននៅគ្រប់អង្គប្រជុំទាំងអស់ ។ នៅពេលដែលមានវត្តមានរបស់ តាវ លក្ខខណ្ឌការងារតឹងតែងត្រូវបានអនុវត្ត ។ ពួកគេត្រូវធ្វើការដោយមិនផ្អែកទៅតាមធាតុអាកាស ។ “ស្ថានភាពធ្វើការគឺពិតជាតឹងតែងណាស់” ។ តាវ ត្រួតពិនិត្យការងាររបស់ពួកគេ ។ បើសិនជាពួកគេមិនអាចបំពេញការងារឲ្យទាន់ពេលកំណត់ទេនោះ ពួកគេនឹងត្រូវបានយកទៅកសាង ។ តាវ ជាអ្នកកំណត់បរិមាណការងារដែលត្រូវធ្វើជារៀងរាល់ថ្ងៃ ។ តាមការយល់ដឹងរបស់គាត់ តាវ ជាអ្នកត្រួតត្រាលើកិច្ចការទូទៅ ។ “គាត់ជាមនុស្សតែម្នាក់គត់ដែលអាចយកនរណាម្នាក់ទៅកសាងបាន ហើយគាត់ក៏មានសិទ្ធិកម្ចាត់មនុស្សចេញដូចគ្នា” ។ គាត់មិនដឹងនោះទេថា តាវ មានតួនាទី

ខ្ពស់ ឬទាបជាង ស ពីព្រោះវាគ្មានការប្រកាសបញ្ជាក់ផ្លូវការណាមួយនោះទេ ។ ក្រោយមកទៀត មានការបន្ធូរបន្ថយច្រើន ។ ជាមួយគ្នានេះដែរ លោក សោម អូន បានបញ្ចប់ការសួរសំណួរ ហើយផ្តល់ឱកាសទៅអ្នកស្រី សុខឹម ដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើសក្ខីកម្ម ។

## កំណត់ហេតុនៃអំពើអាក្រក់ និងការឈឺចាប់ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្ម

ខ្ញុំសូមរៀបរាប់ពីការឈឺចាប់ ដែលខ្ញុំខំអត់ទ្រាំក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃក្នុងរបបនេះ ។ ខ្ញុំនៅក្មេង ។ ខ្ញុំត្រូវបានបំបែកចេញពីបងប្អូន និងឪពុកម្តាយរបស់ខ្ញុំ ហើយខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យទាក់ទងជាមួយសាច់ញាតិនោះទេ ។ ពួកយើងត្រូវបានកាត់ផ្តាច់ទំនាក់ទំនងជាមួយគ្នាទាំងស្រុងហើយ យើងមិនបានដឹងថា មានរឿងអ្វីកើតឡើងចំពោះក្រុមគ្រួសាររបស់យើងនោះទេ ។ ពួកគេលុបបំបាត់ចោលទាំងស្រុងនូវអារម្មណ៍នៃទំនាក់ទំនងគ្រួសារ ហើយទាំងនេះហើយដែលធ្វើឲ្យយើងឈឺចាប់ ពីព្រោះខ្ញុំអន្ទះអន្ទែងចង់ដឹងពីសុខទុក្ខរបស់សមាជិកគ្រួសារក៏ដូចជាសាច់ញាតិរបស់ខ្ញុំផងដែរ ។ អ្វីដែលធ្វើឲ្យខ្ញុំកាន់តែឈឺចាប់នោះគឺខ្ញុំមិនបានដឹងដំណឹងអ្វីពីសមាជិកគ្រួសាររបស់ខ្ញុំ ហើយខ្ញុំក៏មិនបានរស់នៅជាមួយពួកគាត់ដែរ ។

ក្រោយមក គាត់បានរៀបរាប់អំពីស្ថានភាពក្នុងការរស់នៅ និងធ្វើការដ៏លំបាកលំបិនរបស់គាត់ ។

«ខ្ញុំបានគេងយ៉ាងច្រើនបំផុត៣ម៉ោងក្នុង១ថ្ងៃ ហើយពួកយើងត្រូវបានបង្ខាំងសេរីភាព ពួកយើងរស់នៅប្រៀបដូចជាសត្វធាតុ ។ ស្ថានភាពរស់នៅរបស់យើងវេទនាខ្លាំងណាស់ក្នុងរបបនោះ» ។

បន្ទាប់មកទៀត គាត់បានចង្អុលបង្ហាញពីការរៀបការរបស់គាត់ និងការបាត់ខ្លួនរបស់ប្តីគាត់វិញម្តង ។

ចំណុចមួយទៀតដែលខ្ញុំចង់លើកឡើងអំពីមង្គលការរបស់ខ្ញុំគឺ ខ្ញុំត្រូវបានរៀបចំឲ្យការ និងបង្ខំឲ្យរួមដំណេកជាមួយមនុស្សដែលខ្ញុំមិនចូលចិត្ត និងមិនចង់រួមរស់ជាមួយ ។ ទាំងអស់នេះបានធ្វើឲ្យខ្ញុំឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត ។ បន្ថែមលើសនេះទៅទៀត នៅពេលដែលខ្ញុំមានផ្ទៃពោះ ពួកគេមិនអនុញ្ញាតឲ្យប្តីរបស់ខ្ញុំមើលថែខ្ញុំនោះទេ ។ ប្តីរបស់ខ្ញុំត្រូវបានយកចេញទៅឆ្ងាយ ហើយសម្លាប់ចោល ។ ប្រធានកងបានគំរាមយកកូនរបស់ខ្ញុំចេញពីខ្ញុំ និងសម្លាប់វាចោល ។ ពួកគេចោទថាកូនខ្ញុំជាកូនជនក្បត់ ។ ខ្ញុំបានអង្វរពួកគេឲ្យទុកជីវិតឲ្យកូនរបស់ខ្ញុំ ហើយខ្ញុំបានប្រាប់ពួកគេថា ប្រសិនបើពួកគេសម្លាប់កូនខ្ញុំ ពួកគេត្រូវសម្លាប់ខ្ញុំជាមុនសិន ។ កូនខ្ញុំមិនដឹងអំពីគោលនយោបាយអ្វីនោះទេ ។

គាត់បានពន្យល់អំពីមូលហេតុដែលគាត់មានការភ័យខ្លាច នៅពេលដែលបានឃើញក្រុមកម្មាភិបាលបង្ហាញខ្លួនជាមួយនឹងខ្សែពួរដោយសារតែគាត់គិតថា គាត់នឹងត្រូវគេយកទៅសម្លាប់ ។ គាត់នៅមានជីវិតរស់នៅឡើយ ប៉ុន្តែរឿងនេះនៅតែជះឥទ្ធិពលដល់ជីវិតរបស់គាត់ ។

ការឈឺចាប់នៅតែនៅជាមួយខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ។ អ្វីដែលអាក្រក់ជាងនេះទៅទៀតនោះ សមាជិកគ្រួសាររបស់ខ្ញុំទាំងអស់គឺបានស្លាប់ គ្មាននរណាម្នាក់នៅរស់ឡើយ ។ សូម្បីតែក្មួយរបស់ខ្ញុំ ពួកគេទាំងអស់ បានបាត់ខ្លួន និងស្លាប់ ហើយខ្ញុំនឹងចងចាំទុក្ខវេទនាទាំងអស់នេះ រហូតដល់ថ្ងៃដែលខ្ញុំស្លាប់ ។ ខ្ញុំមិនអាចបំភ្លេចវាបាននោះទេ ។ ខ្ញុំចង់ផ្តល់យោបល់ទៅដល់ជនរួមជាតិទាំងអស់ថា យើងមិនគួរមានអ្នកដឹកនាំរបៀបនេះក្នុងរបបគ្រប់គ្រងនោះទេ ។ មនុស្សធ្លាប់បានឆ្លងកាត់ការធ្វើពលកម្មធ្ងន់ ។ មនុស្សត្រូវបានពង្រាត់ចេញពីបងប្អូន និងឪពុកម្តាយ ហើយពួកយើងមិនចង់ឃើញរបបបែបនេះត្រឡប់មកវិញនោះទេ ។

សុខឹម បានសួរថា «ហេតុអ្វីបានជាអ្នកដឹកនាំចូលរួមក្នុងការសម្លាប់មនុស្ស បង្អត់អាហារ ធ្វើបាបមនុស្ស ហើយមនុស្សទាំងនោះរស់ដូចជាសត្វធាតុ? ពួកគេត្រូវបានឃាត់ឃាំងសេរីភាព ហើយមិនមានអាហារគ្រប់គ្រាន់ ហេតុអ្វីបានជាពួកគេបង្កើត និងស្រលាញ់របបបែបនេះ?» ។

លោកប្រធានបានរម្លឹកដល់ដើមបណ្តឹងរដ្ឋប្បវេណីថា ជនជាប់ចោទមានសិទ្ធក្នុងការរក្សាភាពស្ងៀម ។ គាត់អរគុណចំពោះអ្នកស្រី ព្រាប សុខឹម ។

## សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី កុល នឹម

ដើមបណ្តឹងរដ្ឋប្បវេណី កុល នឹម បានរៀបរាប់ថា គាត់កើតនៅក្នុងឆ្នាំខាល ហើយគាត់មានអាយុជាង៦០ឆ្នាំហើយ ។ គាត់កើតនៅខេត្តតាកែវ ។ បច្ចុប្បន្ន គាត់រស់នៅក្នុងខេត្តមណ្ឌលគិរី ។

ឪពុករបស់គាត់ឈ្មោះ លី ម្ដាយរបស់គាត់ឈ្មោះ នេប ។ ក្នុងអំឡុងរបបខ្មែរក្រហម ប្រពន្ធរបស់គាត់បានរលូតកូនចំនួន២ ហើយគាត់គ្មានសល់កូនណាម្នាក់នោះទេ ។ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្ដល់ពេល១៣០ នាទីក្នុងការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ។ ម៉ារី ហ្គីរ៉ូដ មេធាវីអន្តរជាតិដើមបណ្ដឹងរដ្ឋប្បវេណីបានយកពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាគោល ហើយគាត់បាននិយាយថា គាត់យល់ពីដំបូង នឹម បានចូលធ្វើជាទាហាន ហើយបន្ទាប់មកទៀតគាត់បានទៅភ្នំពេញ ហើយបានទៅខេត្តក្រចេះ ហើយ នឹម ក្រោយមកទៀតបានចាកចេញពីក្រចេះទៅមណ្ឌលគិរី នៅក្នុងឆ្នាំ ១៩៧៦ ។ លោក នឹម បានឆ្លើយថា គាត់បានទៅខេត្តមណ្ឌលគិរីក្នុងឆ្នាំ១៩៧៥ គាត់ត្រឡប់មកភ្នំពេញក្នុងរយៈពេល២ ៣ខែ ហើយត្រូវបានបញ្ជូនត្រឡប់ទៅក្រចេះវិញជាមួយនឹងកងពលធំលេខ២ ។ ចាន់ សយ ត្រូវបានចាប់ខ្លួនហើយគាត់ត្រូវបានបញ្ជូនទៅតំបន់នៅតាមបណ្ដាខេត្ត ។ គាត់បាននៅ ក-១១ ក្នុងរយៈពេលខ្លីដែរ ។ "ទោះបីជាយ៉ាងណាក៏ដោយ គាត់មិនសប្បាយចិត្តនោះទេ ពីព្រោះគាត់ត្រូវបានចាប់បង្ខំឲ្យរៀបការ" ។ គាត់ត្រូវបានហៅ ប៉ុន្តែនេះជាការយល់ច្រឡំតែប៉ុណ្ណោះ ពីព្រោះមានអ្នកផ្សេងដែលស្រដៀងគាត់ ។ គាត់ត្រូវបានបញ្ជូនទៅតំបន់ដែលមានមនុស្សស្រីរស់នៅ ហើយគាត់ត្រូវបានឲ្យទៅដួតទឹកនៅទីនោះទៀតផង ។ យ៉ាងណាក៏ដោយ គាត់ត្រូវបានគេបញ្ជូនត្រឡប់មកវិញ ហើយសួរនាំថា តើគាត់ចូលចិត្តទីនោះដែរឬទេ? ប៉ុន្តែគាត់មិនយល់ថាពួកគេចង់បានន័យយ៉ាងម៉េចនោះទេ ។ ពួកគេសួរគាត់ថា តើគាត់មានបានចាប់អារម្មណ៍ទៅលើនារីណាម្នាក់នៅក្នុងតំបន់ដែលគាត់ ត្រូវបានបញ្ជូនទៅនោះដែរឬទេ? ថ្ងៃបន្ទាប់គាត់ធ្វើការនៅក្នុងវាលស្រែមួយនៅ ក-១១ ពួកគេបានលលេងនឹងគាត់ ហើយទុកពេល៣ថ្ងៃឲ្យគាត់ពិចារណា ។ "ក្នុងអំឡុងពេល៣ថ្ងៃនេះ ខ្ញុំពិបាកចិត្តយ៉ាងខ្លាំងពីព្រោះខ្ញុំមិនដឹងថាគួរធ្វើអ្វីនោះទេ ដោយសារតែខ្ញុំមានគូដណ្ដឹងនៅស្រុករួចទៅហើយ ។ បន្ទាប់ពី៣ថ្ងៃនេះកន្លងផុតទៅ គាត់យល់ព្រមរៀបការទាំងអារម្មណ៍មួរម៉ៅ ។ "ខ្ញុំធ្វើបែបនេះដើម្បីបាននៅរស់ ដូច្នេះខ្ញុំអាចមើលឃើញថ្ងៃមេឃម្ដងទៀត" ។ គាត់បានដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីបង្ហាញពីការឈឺចាប់របស់គាត់ ។ គាត់បាននិយាយថា "ខ្ញុំបានសុំទោសទៅកាន់គូដណ្ដឹងរបស់ខ្ញុំ ហើយប្រាប់គាត់ថា ខ្ញុំបានរៀបការជាមួយនារីផ្សេងម្នាក់ទៀតហើយ ដែលនេះចាត់ទុកជាភាពមិនស្មោះត្រង់ចំពោះគូដណ្ដឹងរបស់គាត់ ។ អារម្មណ៍មួម៉ៅនេះនៅតែស្ថិតនៅជាមួយគាត់រហូតដល់ពេលបច្ចុប្បន្ន ។

នៅអំឡុងថ្ងៃរៀបការ នឹម គោរពតាមអង្គការ ទោះបីជាគាត់មានអារម្មណ៍ឈឺចាប់ក៏ដោយ ។ បុរសត្រូវបានអង្គុយនៅជ្រុងម្ខាងហើយនារីត្រូវអង្គុយនៅជ្រុងម្ខាងទៀត ។ ប្រធានកងធ្វើការប្រកាសថា ពួកគេគួរយកគ្នាជាប្ដីប្រពន្ធ ។ ពួកគេត្រូវបានប្រាប់ថា បើសិនបើពួកគេលែងលះគ្នា នោះពួកគេនឹងត្រូវស្លាប់ ។ ប្រាកដណាស់មនុស្សដូច ខៀវ សំផន បានដឹងនូវអ្វីដែលបានកើតឡើង ។ គាត់និយាយថា វាជាសិទ្ធរបស់ ខៀវ សំផន ក្នុងការធ្វើមិនដឹងមិនឮ ក៏ប៉ុន្តែគាត់ចង់សួរថាតើ គោលការណ៍នេះចេញមកពីណា?

នឹម មិនបានស្គាល់ប្រពន្ធរបស់គាត់មុនពេលរៀបការនោះទេ ។ "ប្រាកដណាស់ ខ្ញុំត្រូវធ្វើតាមវិន័យ និងការណែនាំ" គាត់បានធ្វើការប្រៀបធៀបស្ថានភាពរបស់គាត់ទៅនឹងការហាមមិនឲ្យ "ដាក់ជើងវាទឹក នៅពេលដែលទូកកំពុងអុំទៅមុខ" ។ ហេតុដូច្នេះហើយ គាត់មិនអាចបដិសេដបាននោះទេ ។ គាត់ត្រូវតែបង្ហាញឲ្យឃើញពីការគោរពរបស់គាត់ចំពោះអង្គការ ។ "ខ្ញុំធ្វើបែបនេះគឺ ដើម្បីបានរស់" បើមិនដូច្នេះទេ ខ្ញុំមិនបានឃើញមុខមេធាវីរបស់ខ្ញុំក្នុងតុលាការនេះទេ ។ បន្ទាប់មកទៀត មេធាវី ហ្គីរ៉ូដ បានសួរថា តើនៅក្នុងកាលៈទេសៈអ្វីដែលប្រពន្ធរបស់គាត់បាត់បង់កូន? គាត់បានឆ្លើយតបថា គាត់មានកូន ប៉ុន្តែកូនរបស់គាត់មិនទាន់គ្រប់ខែកើតទេ ហើយក៏រលូតបាត់ទៅ ។ "នៅពេលនោះខ្ញុំខឹងខ្លាំងណាស់ ប៉ុន្តែខ្ញុំបានទប់កំហឹងនៅក្នុងខ្លួនរបស់ខ្ញុំ ពួកយើងគ្មានសិទ្ធិក្នុងការបង្ហាញពីភាពខឹងសម្បាររបស់យើងនោះទេ" ។ គាត់បានយកសាកសពកូនរបស់គាត់ទៅកប់នៅពេលដែលប្រពន្ធរបស់គាត់សម្រាកនៅមន្ទីរពេទ្យនៅឡើយ ។ ប្រពន្ធរបស់គាត់ត្រូវបានឲ្យធ្វើការធ្ងន់ ហើយគាត់បានអស់កម្លាំង ។ "នេះជាហេតុផលដែលធ្វើឲ្យគាត់រលូតកូន" ។ ហេតុនេះក៏ជាហេតុផលដែលគាត់ "មកទីនេះដើម្បីសុំជំនួយ" ផងដែរ ។ គាត់និយាយថា គាត់សង្ឃឹមថា មនុស្សជំនាន់ក្រោយនឹងមិនជួបប្រទះនូវការឈឺចាប់ដូចជាពួកគាត់នោះទេ ។

ក្រោយមកទៀត បន្ទាប់ពីវៀតណាមបានរំដោះប្រទេសយើង ប្រពន្ធរបស់គាត់បានរលូតកូនមួយទៀត "ខ្ញុំមានអារម្មណ៍

ឈឺចាប់ ហើយនេះជាមូលហេតុដែលខ្ញុំដាក់ពាក្យបណ្តឹងតាមយោបល់របស់មេធាវីដើម្បីបង្ហាញអំពីទុក្ខវេទនា និងការឈឺចាប់របស់ខ្ញុំ និងប្រពន្ធខ្ញុំ ។ ការដែលគ្មានកូននេះមិនមែនកើតឡើងតែចំពោះខ្ញុំនោះទេ ប៉ុន្តែក៏កើតឡើងចំពោះអ្នកដទៃទៀតដូចគ្នា» ។ គាត់បន្តទៀតថា ពួកគេប្រហែលជាអស់កម្លាំងដូចគ្នា ។ «ពួកគេបង្ខំយើងឲ្យធ្វើការទាំងថ្ងៃទាំងយប់» ។

លោកប្រធានតុលាការបានណែនាំដល់ដើមបណ្តឹងរដ្ឋប្បវេណី កុំឲ្យផ្តល់ព័ត៌មានច្រំដែល ។ មេធាវី ហ្គីរ៉ូដ បានឲ្យដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ពី «ក-១១» ។ គាត់បានឆ្លើយថា គាត់ត្រូវបានបញ្ជូនពីកងពលធំ ។ «ខ្ញុំត្រូវបានចាត់ឲ្យស្ទូងស្រូវនៅទីនោះ» ជួនកាល គាត់ត្រូវជួយក្នុងការងារសាងសង់អគារ ។ បញ្ជូនទៅកាន់ ក-១១ គឺត្រូវបានចាត់ទុកជាការដាក់ទារុណកម្ម ។ «ខ្ញុំដឹងថា វាគឺជាការដាក់ទោស ដូច្នេះហើយទើបខ្ញុំមិនហ៊ានប្រឆាំងនឹងការងារដែលបានដាក់ឲ្យធ្វើ» ។

ប្រពន្ធរបស់គាត់គឺជាជនជាតិភាគតិច ហើយពួកគាត់ត្រូវបានរៀបចំឲ្យរៀបការជាមួយគ្នា ។ គាត់មិនបានដឹងទេថា ប្រពន្ធរបស់គាត់មានអាយុប៉ុន្មាននៅពេលដែលពួកគាត់រៀបការ ។ «ប្រពន្ធរបស់គាត់ប្រើភាសាខុសពីគាត់ក្នុងការហៅថ្ងៃខែ» ឧទាហរណ៍ គាត់ហៅរដូវដាំពោតជាដើម ។ មេធាវី ហ្គីរ៉ូដ បានសួរថា តើគាត់ធ្លាប់គិតចង់រស់នៅបែកគ្នា ក្រោយរបបនេះត្រូវបានផ្តួលរំលំដែរឬទេ? គាត់បានឆ្លើយថា គាត់ចង់បែកគ្នា ប៉ុន្តែគាត់មិនអាចធ្វើបាន ដោយសារគាត់បានរៀបការជាមួយគ្នារួចទៅហើយ ។ គាត់ជ្រើសរើសយកការសុំទោសគូដណ្តឹងរបស់គាត់ ហើយប៉ះប៉ូវសងនាងវិញ ។ គូដណ្តឹងរបស់គាត់បានរៀបការក្រោយគាត់ ។ មេធាវី ហ្គីរ៉ូដ បានសួរថា តើវាជាបញ្ហាចោទដែរឬទេ ដែលប្រពន្ធរបស់គាត់គឺជាជនជាតិព្នង ។ នឹម ឆ្លើយថា គាត់រស់នៅជាមួយនាង ហើយនាងមិនដែលនិយាយអ្វីសោះពីខ្លួនឯង ។ «យើងរស់នៅជាមួយគ្នាដោយសន្តិវិធី ។ គាត់មិនដែលស្តីបន្ទោសខ្ញុំ ហើយខ្ញុំក៏មិនដែលស្តីបន្ទោសគាត់ដែរ ដូច្នេះពួកយើងយល់ពីគ្នា ហើយហេតុផលនេះហើយដែលពួកយើងអាចរស់នៅជាមួយគ្នាបាន» ។

ត្រង់ចំណុចនេះ លោកប្រធានតុលាការបានផ្អាកសវនាការដើម្បីឈប់សម្រាករយៈពេលខ្លី ។

## ការគោរពតាមបញ្ជា

បន្ទាប់ពីសម្រាក សវនាការត្រូវបានផ្តល់ជូនសហព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញាចង់ដឹងថា តើគាត់មានត្រូវរបួសក្នុងពេលប្រយុទ្ធជាមួយវៀតណាមដែរឬទេ ។ គាត់បានឆ្លើយថា គាត់ត្រូវរបួសនៅខាងជើងរាជធានីភ្នំពេញក្នុងពេលកំពុងប្រយុទ្ធជាមួយវៀតណាម ។

គាត់រៀបការ នៅចុងឆ្នាំ១៩៧៧ ។ គាត់ភ័យខ្លាចថា គាត់នឹងត្រូវបានបន្ទោស ប្រសិនបើគាត់បដិសេធមិនព្រមរៀបការ ។ អ្នកដែលបង្គាប់បញ្ជាឲ្យពួកគាត់រៀបការមានឈ្មោះថា សុភា ។ សុភា គឺជាជនជាតិចារាយ ហើយក៏ជាមេទ័ពផងដែរ ។ តាសុភាមិនមានជីវិតរស់នៅនោះទេ ពីព្រោះគាត់ត្រូវបានចាប់ខ្លួនដោយអះអាងថា ជាជនក្បត់ ។ នៅក្នុងរបបខ្មែរក្រហម ពួកគេត្រូវបានឃ្លាំមើលពីការផ្សំដំណេករបស់ពួកគេ ។ ពួកគេត្រូវបានរៀបចំឲ្យរៀបការ ប៉ុន្តែពួកគេគោរពតាមការបញ្ជា ពីព្រោះតែពួកគេមានការភ័យខ្លាច ។ តាមការប៉ាន់ស្មានរបស់គាត់ ប្រពន្ធគាត់មានអាយុលើស ២០ឆ្នាំតិចតួច ។ លោក នឹម ធ្លាប់បានសួរប្រពន្ធគាត់ថា តើនាងចូលចិត្តគាត់ឬទេ? ប្រពន្ធគាត់បានប្រាប់គាត់វិញថា គាត់យល់ព្រមពីព្រោះតែគាត់មានការភ័យខ្លាចតែប៉ុណ្ណោះ ។ «ពួកយើងទាំងអស់គ្នាត្រូវបានបង្ខំឲ្យរៀបការ» ពួកគេត្រូវបានបង្ខំឲ្យរៀបការជាមួយជនជាតិភាគតិច ដើម្បីកុំឲ្យមានការសម្លាប់គ្នា ។ នៅក្នុងមង្គលការនាពេលនោះគឺមានដល់ទៅ ៣០គូឯណោះ ។

ពួកគេនិយាយថា បើសិនជាយើងមិនបង្កើតកូនឲ្យអង្គការទេនោះ «ពួកយើងប្រឆាំងនឹងច្បាប់អង្គការហើយ» ប៉ុន្តែពួកគេមិនអាចដាក់ទោសពួកយើងបាននោះទេ ពីព្រោះពួកយើងរលូតកូន ។ ២ ឬ៣ គូ បានឡើងតំណាងឲ្យគូដទៃទៀតក្នុងការប្តេជ្ញារៀបការ ។ នឹម បានរៀបរាប់ថា ភ្នំក្រោល គឺត្រូវបានត្រួតត្រាដោយ ឡេង ។ ទីនេះគឺនៅជិតនឹងទឹកន្លែងដទៃទៀត ។ នឹម មិនបានដឹងទេថា មាននរណាខ្លះដែលត្រូវបានឃុំឃាំងនៅទីនោះ ក្រៅពីប្រជាជនស៊ីវិល ។ មានសមាជិកគ្រួសារមួយចំនួនត្រូវបានសម្លាប់ ប៉ុន្តែគាត់មិនដឹងថាមានអ្វីកើតឡើងឲ្យប្រាកដនោះទេ ។ ជាមួយគ្នានេះ លោក វីនសិន ដឺវ៉ាល់ បានបញ្ចប់ការសាកសួររបស់គាត់ ។

ក្រុមមេធាវីការពារក្តី នួន ជា លោក លីវ សុវណ្ណា បានសួរ

អំពីមនុស្សដែលនាំ នីម ទៅទីកន្លែងនោះ ។ នីម បានឆ្លើយថា អ្នកដែលនាំគាត់ទៅគឺជាជនជាតិខ្មែរម្នាក់ដែលមានឈ្មោះ សឿន ។ ពួកគេបានសួរទៅ នីម ថា តើ នីម មានពេញចិត្តនារីណាម្នាក់នៅទីនោះឬទេ ។ បើសិនបើពួកគេប្រាប់ នីម ឲ្យជ្រើសរើសនារីណាម្នាក់ក្នុងចំណោមនារីទាំងនោះ វាគឺជារឿងមួយផ្សេងទៀត ។ មនុស្សទាំងអស់បានលលេងនឹង នីម ថា គាត់គឺសមជាមួយមនុស្សស្រីម្នាក់ ។ នីម នៅតែមិនអាចសម្រេចបានថា នីម ពេញចិត្តនរណាម្នាក់នោះទេ ។ ស្របពេលនោះ ចាន់ សយ ត្រូវបានចាប់ខ្លួនផងដែរ "នៅពេលដែល នីម ទៅដល់កន្លែងថ្មី គាត់ត្រូវបានរងសម្ពាធម្តងទៀត" ។ ប្រសិនបើខ្ញុំមិនមានភាពភ័យខ្លាចនោះទេ ខ្ញុំនឹងមិនរៀបការទេ ។ លោក សុវណ្ណ បានសួរទៅកាន់ នីម ថា តើការភ័យខ្លាចនេះចេញពី "ក្នុងខ្លួនរបស់គាត់" មែនទេ? ហើយ នីម បានយល់ស្របនឹងសំណួរនេះ ដោយនិយាយថា "មនុស្សត្រូវបានជម្លៀសចេញ និងត្រូវបានចាប់ខ្លួន" ។

លោកមេធាវី សុវណ្ណ បានសួរបន្តទៅកាន់ នីម ថា តើហេតុអ្វីបានជា នីម មិននិយាយតាំងពីដំបូងអំពីការចាប់បង្ខំឲ្យរៀបការនៅក្នុងពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ហើយនរណាជាអ្នកផ្តើមគំនិតក្នុងការបំពេញពាក្យស្នើសុំជាលើកទី២នេះ ។ នីម បានឆ្លើយតបទៅវិញថា វាគឺជាគំនិតរបស់គាត់ផ្ទាល់ ។ មេធាវី ហ៊ីរ៉ូដ បានបដិសេធហើយបន្តថា សំណួរនេះគ្មានការពាក់ព័ន្ធនោះទេ ។

អ្នកផ្សេងទៀតដែលត្រូវបានបង្ខំឲ្យរៀបការ បានប្រាប់ នីម ថា ប្រសិនបើពួកគេហ៊ានប្រឆាំង ពួកគេនឹងត្រូវទទួលទារុណកម្ម តែ "បើយើងយល់ព្រម យើងនឹងរស់" ។

វាមិនមែនជាគំនិតរបស់ នីម ទេ ដែលថា អ្នកដទៃក៏មានការភ័យខ្លាចដែរ ។ នីម បានបន្ថែមថា "មនុស្សគ្រប់គ្នាដែលបានរៀបការក្នុងរបបខ្មែរក្រហមសុទ្ធតែនិយាយថា ពួកគេត្រូវបានចាប់បង្ខំឲ្យរៀបការ" ។ គូដណ្តឹងរបស់ នីម ក៏មានការភ័យខ្លាចក្នុងរឿងនេះដែរ ។ នាងរស់នៅខេត្តតាកែវ ស្របពេលដែល នីម នៅមណ្ឌលគិរី ។ នីម បានបន្ថែមទៀតថា គាត់ក៏បានដាក់ពាក្យប្តឹងអំពីការបាត់បង់កូនទី២របស់គាត់ដែរ ពីព្រោះពេលនោះប្រពន្ធរបស់គាត់ត្រូវបានឲ្យធ្វើការហួសកម្លាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយវាមានផលប៉ះពាល់ដល់ប្រពន្ធគាត់រហូតដល់ថ្ងៃដែលវៀតណាមចូលរំដោះប្រទេសយើង ។

ការសួរដេញដោលត្រូវបានប្រគល់ទៅឲ្យក្រុមមេធាវីការពារ ខៀវ សំផន ។ លោកមេធាវី សោម អូន បានចោទជាសំណួរថា តើ នីម មានបានដឹងអំពីក្រមសីលធម៌នៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? នីម បានឆ្លើយថា មនុស្សប្រុសស្រី ធ្វើការដាច់ដោយឡែកពីគ្នាក្នុងរបបនេះ ។ ប្រសិនបើពួកគេជួបគ្នា មេកងនឹងសួរនាំពួកគេជាមិនខាន ។ "ពួកគេបាននាំខ្ញុំទៅ ហើយខ្ញុំមិនបានដឹងពីគោលបំណងដែលពួកគេនាំខ្ញុំទៅនោះទេ រហូតដល់ពេលដែលខ្ញុំបានដឹងថាពួកគេនាំខ្ញុំទៅឲ្យមើលមនុស្សស្រី" ។ ណៃ ជាអ្នកហៅ នីម ទៅ ប៉ុន្តែ ណៃ មិនបានដឹងពីមូលហេតុនោះទេ ។ លោកមេធាវី សោម អូន បានសួរថា តើការប្រើពាក្យ "នាំទៅមើលមនុស្សស្រី" នេះជាពាក្យផ្ទាល់ខ្លួនរបស់ នីម ប្រើដែលមិនមែនជាពាក្យមេកងប្រើទេ តើមែនទេ? នីម បានយល់ស្របនឹងសម្តីនេះ ។

ជាមួយគ្នានេះដែរ លោកមេធាវី សោម អូន បានបញ្ចប់ការសាកសួររបស់គាត់ត្រឹមនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានសុំឲ្យ នួន ជា និង ខៀវ សំផន "និយាយការពិត" ហើយបានសំណូមពរទៅដល់តុលាការថា កុំឲ្យក្មេងជំនាន់ក្រោយមានវាសនាដូចគាត់ឲ្យសោះ ។ លោកប្រធានតុលាការបានអរគុណ នីម ហើយឲ្យគាត់ចេញទៅវិញ ។

### ដើមបណ្តឹងរដ្ឋប្បវេណីថ្មី ង៉ែត ឆាត

ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ឆាត កើតក្នុងឆ្នាំរកា នៅភូមិរុងតាកក់ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលជាទីកន្លែងគាត់រស់នៅសព្វថ្ងៃនេះ ។ គាត់មានកូន២នាក់ជាមួយប្តីដើមរបស់គាត់ និង៤នាក់ទៀតជាមួយប្តីទី២ ។

មេធាវី ហ៊ីរ៉ូដ បានផ្តល់តួនាទីទៅមិត្តរួមការងាររបស់គាត់ មេធាវី ឡោ ឈុនធី ក្នុងការធ្វើការសាកសួរអំពីកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ រស់នៅកាលពីឆ្នាំ១៩៧៥ ។ ឆាត បានឆ្លើយថា គាត់រស់នៅខេត្តពោធិ៍សាត់ ហើយគាត់បាននាំកូន និងប្តីរបស់គាត់ទៅការដ្ឋានរំលេច ។ ពួកគាត់បានសង់ជម្រកសម្រាប់គេង និងសម្រាប់បរិភោគរួមគ្នានៅទីនោះ ។ លោកមេធាវី ឈុនធី បានសួរពីហេតុការណ៍នៅពេលដែលប្តីរបស់គាត់ទៅធ្វើការ ហើយគាត់ត្រូវបានរង់ចាំប្តីរបស់គាត់ ។ គាត់បានរៀបរាប់ថា គ្មានហេតុ

ការណ៍គួឲ្យកត់សម្គាល់កើតឡើងក្នុងឆ្នាំ១៩៧៥ នោះទេ ។ គាត់បន្តទៀតថា ហេតុការណ៍ដែលលោកមេធាវីចង់ដឹងនោះ គឺកើតឡើងក្នុងឆ្នាំ១៩៧៨ទៅវិញទេ ។ គាត់ត្រូវបានផ្លាស់ទៅថ្នល់ទទឹង ។ ប៉ុន្មានខែក្រោយមក គាត់ត្រូវបានចាត់ឲ្យប្រមូលផលពោត ។ “ ខ្ញុំបានចេញពីសមរភូមិជាមួយកូន និងប្តីរបស់ខ្ញុំ” ។ ពេលនោះ គឺនៅពេលថ្ងៃត្រង់ ខ្ញុំបានឃើញមនុស្សត្រូវបាននាំយកទៅសម្លាប់ ។ ខ្ញុំបានសួរពួកគេថា តើពួកគេត្រូវនាំយកទៅទីណា? ហើយពួកគេឆ្លើយថា ពួកគេត្រូវបាននាំយកទៅប្រមូលផលពោត ។ ពួកគេក៏បានសួរត្រឡប់មកខ្ញុំវិញថា ហេតុអ្វីបានជាខ្ញុំមិនទៅជាមួយអ្នកទាំងនោះ? ខ្ញុំប្រាប់ពួកគេថា ខ្ញុំចាំប្តី និងកូនរបស់ខ្ញុំ ។ ពួកគេសួរខ្ញុំថា ខ្ញុំមកទីនេះជាមួយគ្រួសាររបស់ខ្ញុំមែនទេ? ហើយខ្ញុំបានឆ្លើយ “ចាស” ពួកគេបានសួរទាំខ្ញុំថា តើប្តីរបស់ខ្ញុំនៅទីណា? ហើយខ្ញុំបានប្រាប់ពួកគេថា ប្តីរបស់ខ្ញុំបានទៅនាំកូនខ្ញុំមក ។ សមមិត្ត សួន បានប្រាប់មិនឲ្យខ្ញុំទៅជាមួយពួកគេនោះទេ ហើយខ្ញុំគួរតែឲ្យប្តីខ្ញុំទៅបានហើយ ។

ប្តីរបស់ខ្ញុំបានសួរនាំពីមូលហេតុដែលខ្ញុំមិនព្រមទៅជាមួយអ្នកទាំងនោះ ។ ខ្ញុំបានប្រាប់គាត់ថា សមមិត្ត សួន ប្រាប់មិនឲ្យខ្ញុំទៅ ហើយឲ្យតែគាត់ម្នាក់ទៅបានហើយ ។ ប្តីរបស់ខ្ញុំបានអង្វរឲ្យខ្ញុំទៅជាមួយគាត់ ។ “ទីបំផុតខ្ញុំព្រមទៅជាមួយគាត់ ។ ពួកយើងបានយំ ។ ខ្ញុំមិនចង់ទៅនោះទេ ប៉ុន្តែប្តីរបស់ខ្ញុំបានព្យាយាមបញ្ចុះបញ្ចូលឲ្យខ្ញុំទៅជាមួយគាត់ ។ ប្តីរបស់ខ្ញុំបានដើរនៅជួរទី១” ។

ឆាត ត្រូវបានគេនាំយកទៅកន្លែងផ្សេងមួយទៀត ។ នៅម៉ោង៧ល្ងាច នៅពេលដែលខ្ញុំកំពុងសម្រាន្តនៅក្នុងរោងវែងដែលគេទុកសម្រាប់មនុស្សស្រីវ័យចំណាស់ ។ ខ្ញុំបានឃើញសេនាជនរួមមាន សួន ដើរចូលមក ហើយដៃរបស់ពួកគេមានកាន់ដាវ ដែលប្រឡាក់ដោយឈាម ។ ពួកគេបានសួរខ្ញុំថា តើខ្ញុំមានចំណាំអ្វីខ្លះបានទេ ហើយខ្ញុំបានប្រាប់ពួកគេថា ខ្ញុំចំណាំខោអាវរបស់សមមិត្តភឿន ។ “ពេលនោះ ខ្ញុំពិតជាភ័យខ្លាចណាស់” ។ ឆាត បានសន្និដ្ឋានថា ប្តីរបស់គាត់ត្រូវបានគេសម្លាប់ហើយ ។

លោកមេធាវី ឈុនធី បានសួរបន្ថែមទៀតថា តើមានរឿងហេតុអ្វីកើតឡើងចំពោះគាត់ក្នុងហេតុការណ៍នោះដែរឬទេ? គាត់បានបដិសេធ ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់បានបន្តទៀតថា គាត់ត្រូវបានបង្ខំឲ្យរៀបការក្នុងពេល១អាទិត្យក្រោយមក ។ នៅពេលដែលពួកយើងទៅដល់សាលប្រជុំ ខ្ញុំឃើញមានមនុស្សជាច្រើននៅទីនោះ ។ នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំត្រូវបានគម្រូវឲ្យរៀបការ ហើយខ្ញុំមិនដឹងថា តើបុរសណាម្នាក់ដែលត្រូវគេផ្សំផ្គុំជាមួយនឹងខ្ញុំនោះទេ ។ ខ្ញុំដើរតាមគេចូលទៅក្នុងអគ្គប្រជុំនោះ ។ ពិធីមង្គលការធ្វើឡើងក្នុងរយៈពេលពីរបីថ្ងៃ បន្ទាប់ពីប្តីរបស់គាត់ស្លាប់ ។ “ខ្ញុំនៅស្រក់ទឹកភ្នែកចំពោះការបាត់បង់ប្តីរបស់ខ្ញុំនៅឡើយនាពេលនោះ” ។

គ្រួសាររបស់គាត់ដែលជាកម្ពុជាក្រោមត្រូវបាននាំយកទៅសម្លាប់ចោលទាំងអស់ ។ “ដោយពួកគេចាត់ទុកអ្នកទាំងនោះក៏ជាខ្មែរដែរ” ។

លោកមេធាវី ឈុនធី បានចោទសួរគាត់ថា តើគាត់ត្រូវបានប្រាប់អំពីគោលបំណងនៃការរៀបការនេះទេ ។

ពួកគេបានឲ្យយើងឡើងប្តេជ្ញា ។ ខ្ញុំបានមើលមុខប្តីរបស់ខ្ញុំ ហើយខ្ញុំឃើញថា គាត់មានវ័យចំណាស់ណាស់ ។ ខ្ញុំមានអាយុទើបតែ២០ឆ្នាំប៉ុណ្ណោះ ហើយគាត់ចាស់ជាងខ្ញុំឆ្ងាយណាស់ ។ ខ្ញុំមិនហ៊ានប្រឆាំងនោះទេ ដោយសារពួកគេប្រាប់ថា បើសិនជាខ្ញុំប្រឆាំងខ្ញុំនឹងត្រូវបញ្ជូនទៅថ្នាក់លើ ។

គេសួរអំពីអារម្មណ៍របស់ ឆាត នាពេលនោះ ។ គាត់តបវិញថា “អារម្មណ៍នាពេលនោះ គឺមិនអាចបរិយាយបាននោះទេ ជាអារម្មណ៍ដែលតក់ស្លុត និងភ័យខ្លាច” ។

គេបានឲ្យផ្ទះមួយទៅ ឆាត និងប្តីរបស់គាត់សម្រាប់ផ្សំដំណេក ។ ឆាត និងប្តីរបស់គាត់បានពិភាក្សាគ្នាទៅវិញទៅមក ហើយសម្រេចថា ពួកគាត់មិនប្រឆាំងនោះទេ ហើយរក្សាភាពស្ងៀមស្ងាត់ ពីព្រោះមានសេនាជនដើរនៅក្បែរផ្ទះនោះ ។ “ពួកយើងឃើញហេតុការណ៍ដែលមនុស្សត្រូវបានយកទៅសម្លាប់” ។ លោកមេធាវី ឈុនធី បានសួរថា តើគាត់ធ្លាប់ត្រូវបាននាំយកទៅសម្លាប់ដែរឬទេ? ហើយគាត់ឆ្លើយថា ប្តីរបស់គាត់ធ្លាប់ ។

លោកប្រធានតុលាការ បានបិទសវនាត្រឹមនេះ ហើយសវនាការនេះនឹងបន្តនៅថ្ងៃស្អែកម៉ោង៩ព្រឹក ជាមួយនឹងការថ្លែងការណ៍របស់លោកស្រី ឆាត និង ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1068 និងសាក្សី 2-TCW-289 ។ **អាលីស រមីហ្គើរ**

# អ្នកជំនាញបានផ្តល់សក្ខីកម្ម៖ គូស្វាមីភរិយាមិនត្រូវបានបង្ខំឱ្យរៀបការនោះទេ

លើសពីពីរសប្តាហ៍ហើយដែលគ្មានសវនាការដោយសារតែមានបុណ្យជាតិ និង មានទឹកជំនន់លិចនៅតុលាការ នាថ្ងៃនេះអង្គជំនុំជម្រះបានបន្តការស្តាប់សក្ខីកម្ម ។ សាក្សីអ្នកជំនាញ ផេច ឡឺវ៉ាញ បានចាប់ផ្តើមផ្តល់សក្ខីកម្មក្នុងទំនាក់ទំនងនៃការរៀបការដោយបង្ខំ ។ ស្ថិតក្រោមការសាកសួរពីសំណាក់លោកស្រី អានតាហ៊្គីសេវ្យ មេធាវីការពារក្តីឲ្យ ខៀវ សំផន អ្នកស្រី ឡឺវ៉ាញ បាននិយាយថា មនុស្សដែលគាត់បានធ្វើការសម្ភាសន៍មិនបានចាប់បង្ខំឲ្យរៀបការឡើយ បើទោះបីជាពួកគេមិនមានចំណង់ស្នេហានៅពេលដែលអង្គការបានរៀបចំការរៀបការឲ្យក៏ដោយ ហើយនេះក៏មិនមែនជាសំណុំរឿងទាក់ទងការរៀបការតាមបែបរៀបចំ មុនឆ្នាំ១៩៧៥ដែរ ។ អ្នកស្រីក៏បានបន្ថែមថា ក្រៅពីការណែនាំឲ្យរួមដំណេកក្រោយការរៀបការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យមានប្តីប្រពន្ធតែប៉ុន្មានគូប៉ុណ្ណោះដែលធ្វើតាមការណែនាំនោះ ។ លើសពីនេះទៀត អ្នកស្រីបានចង្អុលបង្ហាញថា សូម្បីតែនៅអន្តរជាតិ ការរួមដំណេកក្រោយការរៀបការ គឺវាជារឿងដែលជៀសមិនរួច ។

**បញ្ហាដំបូង**

ដោយសារតែកម្ពស់ទឹកឡើងខ្ពស់នៅបរិវេណខាងមុខតុលាការ និង នៅលើកំណាត់ផ្លូវជាតិលេខ៤ សវនាការដែលបានពន្យារពេលមួយរយៈ បានចាប់ផ្តើម ។ នាពេលចាប់ផ្តើមនៃដំណើរការសវនាការ ការស្នើផ្ទាល់មាត់ និងការឆ្លើយតបទាក់ទងនឹងឯកសារដែលបានដាក់ស្នើ ត្រូវបានអនុញ្ញាតដើម្បីបានស្តាប់សក្ខីកម្មអ្នកជំនាញនាថ្ងៃនេះ ។ លើសពីនេះទៀត ប្រធានអង្គជំនុំជម្រះ លោក និល ណុន បានត្រឡប់មកសាលសវនាការវិញ បន្ទាប់ពីអវត្តមានប៉ុន្មានសប្តាហ៍ដោយសារបញ្ហាសុខភាព ។ ក្រោយពីការស្នើសុំនិងការឆ្លើយតបដើម្បីបញ្ជាក់លើឯកសារដែលពាក់ព័ន្ធ មេធាវីការពារក្តីឲ្យ នួន ជា បានប្រកាសថា សំណើសាក្សី ២-TCW-៩៦០ មិនត្រូវបានចាត់ទុកថាពាក់ព័ន្ធឡើយ ដូច្នេះលោកស្រីមេធាវីបានស្នើអោយដកសាក្សីចេញ ។ ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមលោក ហ្សង់ម៉ាក ឡាវែញ លោក វីកទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា បានបកស្រាយថា គាត់មិនបានចាត់ទុកសាក្សីសំខាន់ភ្ជាប់ទៅនឹងទ្រឹស្តីនៃសំណុំរឿងទៀតនោះទេ ។ ចៅក្រម ឡាវែញ បានថ្លែងថា អង្គជំនុំជម្រះមិនផ្អែកទៅលើប្រព័ន្ធច្បាប់ខំមិនឡូឡើយ សាក្សីបានក្លាយជាបុគ្គលក្នុងតុលាការ ហើយមាត្រាទី៨៧(៤) ក៏ចាំបាច់ត្រូវតែបំពេញ ។ ដូច្នេះ សម្អាងហេតុចាំបាច់ត្រូវតែមាន ដើម្បីបញ្ជាក់ថាសាក្សីមិនមានការពាក់ព័ន្ធនៅក្នុងសំណុំរឿង ។ លោក នីកូឡាស គូមជីន សហព្រះរាជអាជ្ញា បានមានប្រសាសន៍ថា ទោះបីជាមានសារសំខាន់នៅក្នុងរឿងក្តីក៏ដោយ



សហព្រះរាជអាជ្ញា នីកូឡាស គូមជីន

ក៏សាក្សីបានត្រឹមតែផ្តល់ចម្លើយដូចក្នុងឯកសារ ។ ដូច្នេះ លោកមិនបានចាត់ទុកថា ការកោះហៅសាក្សីគឺជារឿងសំខាន់ឡើយ ។ លោកស្រី ម៉ារី ហ្គីរ៉ូដ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយថា ភាគីខាងលោកស្រីនឹងធ្វើការដោយប្រុងប្រយ័ត្នទៅលើករណីនេះក្នុងតុលាការ ។ បន្ទាប់មក លោកប្រធានបានប្រកាសថា ការសម្រេចចិត្តលើបញ្ហានេះនឹងត្រូវធ្វើឡើងនៅពេលផ្អាកសាវនាការ ។

## អ្នកជំនាញ ផេច ឡឺវ៉ាញ



អ្នកជំនាញ ផេច ឡឺវ៉ាញ

បន្ទាប់ពីសម្រាក លោកប្រធានបានប្រកាសថា ការស្នើសុំដើម្បីបង្ហាញឯកសារត្រូវបានអនុញ្ញាត ។ បន្ទាប់មក សក្ខីកម្មរបស់អ្នកជំនាញបានចាប់ផ្តើមបកស្រាយ ។ អ្នកស្រី ផេច ឡឺវ៉ាញ ដែលមានសញ្ជាតិអាមេរិក-អូស្ត្រាលី បានកើតនៅថ្ងៃទី២១ ខែមករា ឆ្នាំ១៩៥២ ។ សព្វថ្ងៃអ្នកស្រីមានទីលំនៅ នៅរដ្ឋវិចថូរៀ ប្រទេសអូស្ត្រាលី ។ អ្នកស្រីជាចិត្តវិទូ នៃគ្លីនិកដែលមានការចុះបញ្ជីមួយកន្លែង និងជាបុរាណវិទូដែលផ្តោតលើការសិក្សានរវិទ្យាផ្នែកវេជ្ជសាស្ត្រ ជាសាស្ត្រាចារ្យ និង ជាអ្នកសម្របសម្រួលការស្រាវជ្រាវ នៃមូលនិធិ សូ អា ផ្តោតលើអំពើប្រល័យពូជសាសន៍នាសម័យទំនើប ក្នុងទីក្រុងឡូសអែនជឺឡេស ។

## ការសិក្សា និង ការស្រាវជ្រាវដំបូង

អ្នកស្រី ផេច ឡឺវ៉ាញ បានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសង្គម នៅក្នុងឆ្នាំ១៩៩៤ និងទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកចិត្តវិទ្យា ក្នុងឆ្នាំ១៩៩៦ ហើយអ្នកស្រីទទួលបានសញ្ញាបត្របណ្ឌិតផ្នែកចិត្តវិទ្យាដោយផ្តោតលើការសិក្សាពីជំងឺផ្លូវចិត្ត ក្នុងឆ្នាំ១៩៨៤ និងទទួលបានសញ្ញាបត្របណ្ឌិតមួយទៀតក្នុងឆ្នាំ២០០៧ ។

អ្នកស្រី បានមកកាន់កម្ពុជាជាលើកដំបូងនៅឆ្នាំ១៩៨៥ និងឆ្នាំ១៩៨៦ ជាអំឡុងពេលដែលគាត់មកពិភាក្សាអំពីលទ្ធភាពដែលអាចបង្កើតវគ្គសិក្សាផ្នែកអន្តរវប្បធម៌សង្គម នៅសកលវិទ្យាល័យជាមួយសិស្សកម្ពុជាម្នាក់ក្នុងចំណោមសិស្សផ្សេងទៀតរបស់អ្នកស្រី ដែលមានឈ្មោះថា ហែម ម៉ាយ៉ាង ។ ដំណើរទស្សនកិច្ចរបស់អ្នកស្រីមានរយៈពេលប្រហែលជា២សប្តាហ៍ ។

ការសាក់សួរផ្ទាល់ខ្លួនជាលើកដំបូងរបស់អ្នកស្រីក្នុងប្រទេសកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើងនៅឆ្នាំ១៩៨០ នៅពេលដែលអ្នកស្រីកំពុងបំពេញការងារនៅមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តមួយកន្លែង ។ អ្នកជំងឺរបស់អ្នកស្រីមួយចំនួន គឺជាជនភៀសខ្លួនដែលបានរត់ទៅសហរដ្ឋអាមេរិក បន្ទាប់ពីនោះមក អ្នកស្រីក៏បានចាប់ផ្តើមសិក្សាពីកម្ពុជា ។ ពេលនោះគឺជាលើកទីមួយ ដែលអ្នកស្រីបានឮពីការរៀបការបែបនោះ ។ អ្នកស្រីបានចាប់ផ្តើមដំណើរការស្រាវជ្រាវជាផ្លូវការរបស់អ្នកស្រី នៅឆ្នាំ១៩៩៧ ។ ចំណាប់អារម្មណ៍របស់អ្នកស្រី បានកើតមានកាន់តែខ្លាំងនៅពេលដែលអ្នកស្រីបានជួបជាមួយសហការីរបស់អ្នកស្រីដែលបានរៀបការជាមួយគ្នា ហើយប្តីប្រពន្ធមួយគូនោះហាក់ដូចជាមានភាពល្អូកល្អើននឹងគ្នាណាស់ ។ ពួកគេទាំងពីរបានជួបគ្នា នៅក្នុងរបបខ្មែរក្រហម និងមិនត្រូវបានបង្ខំឲ្យរៀបការឡើយ ។ អ្វីដែលអ្នកស្រី ផេច ឡឺវ៉ាញ បានឮនេះ គឺមានភាពផ្ទុយគ្នាពីការគិតរបស់អ្នកស្រីដែលថា ប្រជាជននៅក្នុងរបបខ្មែរក្រហមបានរៀបការជាមួយគ្នាដោយបង្ខំ ។ អ្នកស្រីបានបន្តជួបជាមួយប្រជាជននៅក្រុងតាខ្មៅ និង ចង់យល់បន្ថែមពីអំពីកត្តាផ្សេងៗ ដែលអាចឲ្យអ្នកស្រីជឿថា ពិតជាមានការរៀបការបែបបង្ខំពិតមែន ។ បន្ទាប់មក អ្នកស្រីបានធ្វើការអង្កេតដ៏ហ្មត់ចត់មួយដែលរួមមាន ការអាន

ឯកសារនយោបាយ ។ អ្នកស្រីបានថ្លែងថា ការស្រាវជ្រាវផ្សេងៗរបស់អ្នកស្រីទាក់ទងនឹងប្រធានបទនេះច្រើនតែមានសភាពផ្ទុយពីគ្នា ។ ឧទាហរណ៍ អ្នកស្រីបានធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលវប្បធម៌បារាំង ហើយបានអានរបាយការណ៍ផ្នែកដែនទី និង របាយការណ៍ស្រដៀងៗនោះ ។ អ្នកស្រីក៏មានបំណងចង់គូសបង្ហាញពីការរៀបការមុនឆ្នាំ១៩៧០ដែរ ។ អ្នកស្រីបានបន្តថា ការសិក្សាថ្នាក់បណ្ឌិតរបស់គាត់ដើម្បីមានពេល និង ធនធានគ្រប់គ្រាន់ក្នុងការធ្វើការស្រាវជ្រាវដោយឯករាជ្យ ។ លោក ដេវីដ ឆេនដល័រ បានយល់ព្រមក្នុងការផ្តល់ប្រឹក្សាដល់ការងាររបស់អ្នកស្រី បន្ទាប់ពីអ្នកផ្តល់ប្រឹក្សាមុនៗបានលាឈប់ពីសកលវិទ្យាល័យ មានន័យថា អ្នកស្រីត្រូវតែបញ្ចប់ការងារដែលនៅសេសសល់ប្រកបដោយក្រមសីលធម៌បន្ថែមលើការងាររបស់ខ្លួនម្តងទៀត ។

និក្ខេបបទរបស់អ្នកស្រីត្រូវបានដាក់ចំណងជើងថា ការសិក្សាពីបរិបទមួយអំពីការរៀបការ និងការផ្តល់កំណើតក្រោមរបបខ្មែរក្រហម ក្បួនទម្លាប់បដិវត្តន៍ ។ ការចំណាយរបស់អ្នកស្រីត្រូវពឹងលើប្រាក់អាហារូបករណ៍ដែលអ្នកស្រីទទួលបាន និងពេលខ្លះត្រូវពឹងលើមូលនិធិឯកជន ។ បន្ថែមពីនេះទៀត អ្នកស្រីបានទទួលឋានៈជាសាស្ត្រាចារ្យពេញសិទ្ធ នៅជប៉ុន ដោយបង្រៀនក្នុងរយៈពេលមួយឆ្នាំទៅពីរឆ្នាំ ហើយទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរមកកាន់កម្ពុជា ។ ការស្ទាបស្ទង់មតិរបស់អ្នកស្រីមានការឆ្លើយតបជាផ្លូវការពីអ្នកផ្តល់ព័ត៌មានចំនួន១៩២រូប ដើម្បីធ្វើការសិក្សា ប៉ុន្តែជារឿយៗអ្នកស្រីបានសំណេះសំណាលជាមួយពលរដ្ឋដែលមានវ័យចំណាស់ដើម្បីឲ្យពួកគាត់បកស្រាយពីពិធីបុណ្យសាសនានានា ដែលត្រូវបានអនុវត្តពីមុនសម័យខ្មែរក្រហម ។ អ្នកស្រីបានថត សកម្មភាពចូលរួមទុក នាំយកវីដេអូ និង ឧបករណ៍ថតសំឡេងមកជាមួយគាត់ ។

គ្រង់ចំនុចនេះ លោកប្រធានបានផ្អាកការស្តាប់ដើម្បីសម្រាក ។

## វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្រោយពីសម្រាកហូបអាហារថ្ងៃត្រង់ លោកប្រធានបានប្រកាសថា នឹងរក្សាការសម្រេចចិត្តដើម្បីកោះហៅសាក្សី ២-TCW-៩៦០ ។ សវនាការត្រូវបានផ្តល់ទៅឲ្យមេធាវីការពារក្តី


ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន

ខៀវ សំផន ដើម្បីធ្វើការចោទសួរទៅអ្នកជំនាញ ។ លោកស្រីមេធាវី អាន់តា ហ្គីសេ្ស បានសាកសួរអ្នកស្រី ដេច ឡឺវ៉ាញ អំពីភាពខុសប្លែកគ្នារវាងនិក្ខេបបទ និងសៀវភៅរបស់អ្នកស្រី ។ អ្នកស្រីបានបកស្រាយថា ក្នុងនិក្ខេបបទរបស់អ្នកស្រី មានឯកសារយោងចំនួន ១៧៨ ចំណែកឯក្នុងសៀវភៅរបស់អ្នកស្រីមានឯកសារយោង១៨៤ ។ អ្នកស្រីបានបន្តថា មានការបោះពុម្ពផ្សាយថ្មីខ្លះត្រូវបានបោះពុម្ព ដូច្នេះគាត់សំដៅថា ការបោះពុម្ពផ្សាយថ្មីទាំងនោះគឺមាននៅក្នុងសៀវភៅគាត់ ។ និក្ខេបបទរបស់អ្នកស្រីមានការរួមបញ្ចូល គំរូ និង ទិន្នន័យ ។ ព័ត៌មានលម្អិតដែលទាក់ទងនឹងការធ្វើការពិនិត្យអក្សរសិល្ប៍ និង ជំហាននៃការធ្វើសេចក្តីសន្និដ្ឋានគឺមានតិច ។

លោកស្រីមេធាវី បានសួរថា អ្នកស្រី ដេច ឡឺវ៉ាញ បានអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវ តាមវិធីសាស្ត្រប្រើក្នុងទស្សនវិទ្យា វេជ្ជសាស្ត្រ នរវិទ្យា និង សង្គមវិទ្យា ឬ អ្នកស្រីផ្តោតទៅលើវិធីសាស្ត្រស្រាវជ្រាវស្តង់ដារជាក់លាក់ណាមួយ ។ អ្នកស្រីបានបកស្រាយថា ការស្រាវជ្រាវរបស់អ្នកស្រីគឺបានរួមបញ្ចូលវិធីសាស្ត្រជាច្រើន ។ ប៉ុន្តែទោះយ៉ាងនេះក្តី អ្នកស្រីបានអនុវត្តតាមវិធីសាស្ត្រស្តង់ដារក្នុងការស្រាវជ្រាវ ជាពិសេសក្នុងដំណាក់កាលដំបូងនៃការស្រាវជ្រាវ ។

អ្នកស្រីបានបកស្រាយថា បុគ្គលម្នាក់អាចទទួលបានបរិញ្ញាប័ត្រថ្នាក់បណ្ឌិតដោយធ្វើការបញ្ជាក់ក្នុងផ្នែកណាមួយឲ្យបានជាក់លាក់ ។ វាសមមូលទៅនឹងសញ្ញាបត្របណ្ឌិតរបស់អាមេរិកដូចដែរ ។ អ្នកស្រីបាននិយាយថា នៅពេលដែលសហការីរបស់អ្នកស្រីបានបកស្រាយប្រាប់អ្នកស្រី អំពីបទពិសោធន៍ជីវិតរបស់ពួក

គេ ដែលមានភាពផ្ទុយស្រឡះពីការគិតរបស់អ្នកស្រី ដូច្នេះ អ្នកស្រីចង់ធ្វើការស្រាវជ្រាវបន្ថែមទៀត ។ ប្តីប្រពន្ធមានចិត្តចង់រៀបការនៅពេលដែលពួកគេជួបគ្នាក្នុងជំរំ ។ ពួកគេបានពិពណ៌នាថា ពួកគេត្រូវតែរៀបអាពាហ៍ពិពាហ៍តាមសាសនាគ្រិស្តដើម្បីទទួលបានកម្មវិធីសម្រាប់ជនភៀសខ្លួន ។ បទពិសោធន៍ផ្ទាល់ខ្លួនបែបនេះ បានធ្វើឲ្យអ្នកស្រីចង់ធ្វើការស្រាវជ្រាវពីពាក្យ "ការរៀបការដោយបង្ខំ" ។

អ្នកស្រី ដេច ឡឺវ៉ាញ បានឆ្លងកាត់៣ដំណាក់កាលក្នុងគុណភាពស្រាវជ្រាវ ៖

◆ ការជ្រើសរើសគំរូដែលមានគណៈវិនិច្ឆ័យពី ប្តីប្រពន្ធដែលនៅជាមួយគ្នាត្រូវធ្វើការសម្ភាសដាច់ដោយឡែកពីគ្នា ហើយសង្កេតមើលត្រង់ចំណុចណាដែលពួកគេយល់ស្រប ទីពីរគឺប្តីប្រពន្ធដែលបានរៀបការនៅកម្ពុជា ហើយគ្មានប្រវត្តិជាជនភៀសខ្លួន ។

◆ ការជ្រើសរើសគំរូ (ដែលផ្ទុយពីគំរូការវិនិច្ឆ័យ) ប្តីប្រពន្ធដែលបានរៀបការក្រោមរបបខ្មែរក្រហមត្រូវបានសួរដោយសំណួរមិននាំមុខ ដើម្បីយល់ឲ្យកាន់តែច្បាស់ពីបទពិសោធន៍អាពាហ៍ពិពាហ៍របស់គាត់ ។

◆ អ្នកស្រីបានជ្រើសរើសគំរូរបស់អ្នកស្រីតាមរយៈប្តីប្រពន្ធដែលបានរៀបការក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងប្តីប្រពន្ធដែលបានរៀបការក្នុងភូមិដែលមានអ្នកដឹកនាំផ្សេងគ្នា អ្នកស្រីផ្តោតលើ ប្រជាជននៅភូមិភាគកណ្តាល និងភូមិភាគនិរតី ។

ប្តីប្រពន្ធមួយគូដំបូងបានសាកល្បងយល់ន័យនៃពាក្យបង្ខំ ។ អ្នកស្រីបានជួបប្តីប្រពន្ធដំបូងនេះប្រហែលជា៣ឆ្នាំមកហើយ ។ អ្នកស្រីបានថតរូបពួកគេដើម្បីប្រមូលទុកឯកសាររូបភាព និងសំឡេង ។ អ្នកស្រីចង់បានគំរូច្រើនដើម្បីជាទិន្នន័យ ។ មុនការប្រមូលទិន្នន័យនេះ អ្នកស្រីបានជួបប្រទះតែការប្រមូលទិន្នន័យដោយផ្អែកលើខ្លឹមសារតែប៉ុណ្ណោះក្នុងការស្រាវជ្រាវ ។

អ្នកស្រីមានប្រសាសន៍ថា អ្នកស្រីយល់ថា "ទីតាំងប្រវត្តិសាស្ត្រអាចដាស់ការចងចាំ ។ អ្នកស្រីបានយល់ថា ខ្លឹមសារនៃសាច់រឿងអាចនឹងមានការផ្លាស់ប្តូរ ប្រសិនបើអ្នកស្រីធ្វើដំណើរជាមួយពួកគេទៅកាន់កន្លែងដែលធ្លាប់មានអនុស្សាវរីយ៍" ។ តើវាបានផ្លាស់ប្តូរសាច់រឿងរបស់ពួកគេដែរឬទេ? ចា៎ គឺពិតណាស់ ។ អ្នកស្រីបានធ្វើការជាមួយអ្នកចិត្តវិទូដើម្បីអោយប្រាកដថា ក្រុមប្រជាជនទទួលបានការគាំទ្រផ្នែកស្មារតីក្នុងបទសម្ភាសន៍បន្តបន្ទាប់របស់អ្នកស្រី ។

អ្នកស្រីបានបកស្រាយថា ពេលខ្លះការទទួលយកប្រាក់មូលនិធិគឺអាចប៉ះពាល់ដល់ការស្រាវជ្រាវបែបអព្យាក្រឹត្យ ។ ដូច្នេះ អ្នកស្រីនឹងមិនធ្វើការរួមគ្នាជាមួយអង្គការមិនមែនរាជរដ្ឋាភិបាលក្នុងប្រទេសកម្ពុជាឡើយ ។ អ្នកស្រីបាននិយាយថា ការពិភាក្សាត្រូវបានកើនកម្តៅដោយសារ តែចំណុចរសើប ៖ "តាំងពីដើមមកម្ល៉េះ ខ្ញុំមានអារម្មណ៍ថាកំដៅ និងអាចកើតមាន" ។

អ្នកស្រីមាន បំណងរក្សាអព្យាក្រឹត្យភាពតាមដែលអាចធ្វើទៅបាន ។ "ខ្ញុំមានអារម្មណ៍ថា មានភាពតានតឹងណាស់ចំពោះប្រធានបទនោះ" ។ ប្រធានបទនៅលើរបៀបវារៈកាន់តែច្រើន ប្រជាពលរដ្ឋដែលអ្នកស្រីធ្វើការសម្ភាសន៍ក៏មានភាពអៀនខ្មាសកាន់តែច្រើនផងដែរ ។

ក្រឡេកទៅពេលដែលអ្នកស្រីប្រមូលគំរូនៃប្រជាជនចំនួន


សហមេធាវីការក្តីជនជាប់ចោទ អ្នកស្រី អាន់តា ហ្គីស្សេ

២៧រូបក្នុងតំបន់មួយ លោកស្រីមេធាវី ហ្គីស្សេ បានសួរអ្នកស្រី ដេច ឡឺវ៉ាញ ថា តើអ្នកស្រីបានធ្វើការស្រាវជ្រាវដូចគ្នាជាមួយប្តីប្រពន្ធគ្រប់គូ ដូចអ្វីដែលអ្នកស្រីបានធ្វើជាមួយប្តីប្រពន្ធមួយគូដំបូងដែរឬទេ ។ អ្នកស្រីបានបញ្ចប់ការប្រមូលគំរូជាមួយតត្តិភាព ហើយវាក៏ជាវិធីដែលអ្នកស្រីបញ្ចប់ការប្រមូលគំរូទី២របស់គាត់ផងដែរ អ្នកស្រីបញ្ចប់នៅពេលដែលអ្នកស្រីចាប់ផ្តើមទទួលខ្លឹមសារប្រាំដែល ។ ជាឧទាហរណ៍ វាមានភាពខុសប្លែកក្នុងពិធីមង្គលការបើ

យោងតាមមេកង ។ អ្នកស្រីវិវត្តសំណួរតាមរយៈប្តីប្រពន្ធមួយគូដំបូង ។ សំណួរទាំងនោះ គួយ៉ាងមានដូចជា សួរពួកគេឲ្យពិពណ៌នាអំពីពិធីអាពាហ៍ពិពាហ៍ «តើអ្វីបានការពារអ្នក?» ដើម្បីបកស្រាយពីដំណើរមានគ៌ភ និងប៉ុន្មានថ្ងៃក្រោយពីការសម្រាល ។ នៅពេលធ្វើការសម្ភាសន៍លើកដំបូង អ្នកស្រីបានធ្លាក់ខ្លួនឈឺ ហើយមានស្ត្រីប៉ុន្មានអ្នកបានមើលថែអ្នកស្រី ។ នាពេលនោះ អ្នកស្រីបានសួរពួកគាត់ថា តើពួកគាត់ទទួលបានការថែទាំរបៀបនេះឬទេពេលដែលពួកគាត់មានគ៌ភនៅក្នុងរបបខ្មែរក្រហម ស្ត្រីទាំងអស់នោះបានប្រកែក ។ មានស្ត្រីម្នាក់បាននាំអ្នកស្រីទៅកាន់កន្លែងដែលបានប្រើប្រាស់ដើម្បីសម្រាលកូន ជាកន្លែងដែលអ្នកស្រីបានឈានដល់មធ្យោបាយនៃការនាំអ្នកសម្ភាសន៍ទៅកាន់កន្លែងដើម ។

## ខ្លឹមសារនៃការស្រាវជ្រាវ

អ្នកស្រីបានធ្វើការសម្ភាសច្រើនជាង១.០០០នាក់ក្នុងភូមិទាំងនោះ ។ ពួកគេភាគច្រើនមិនបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែលោកតាលោកយាយបាននិយាយជាមួយអ្នកស្រីអំពីពិធីអាពាហ៍ពិពាហ៍មុនរបបខ្មែរក្រហម ។

លោកស្រីមេធាវី អានតា ហ្គីសេរ្ស បានធ្វើការដកស្រង់ផ្នែកខ្លះនៃនិក្ខេបបទរបស់អ្នកស្រី ដេច ឡឺវ៉ាញ ត្រង់ចំនុចដែលអ្នកស្រីនិយាយថា ប្រហែលជាមានការយល់ខុសក្នុងការបែងចែកការរៀបការក្នុងរបបខ្មែរក្រហមថា ជាការបង្ខំក្នុងបរិបទនៃប្រទេសដែលប្រជាពលរដ្ឋត្រូវបានរៀបចំឲ្យរៀបការមុនរបបនោះ ។ មានប្រតិកម្មទៅនឹងសេចក្តីថ្លែងការណ៍របស់អ្នកស្រី ណាកាហ្គាវ៉ា ដែលថា ការរៀបការគឺជាបញ្ហាគ្រួសារ អ្នកស្រី ដេច ឡឺវ៉ាញ បាននិយាយថា វាគឺជាបញ្ហាសហគមន៍ច្រើនជាង ។ ការសិក្សាពីជាតិពន្ធុខ្លះបានកត់សម្គាល់ភាពខុសប្លែកគ្នាក្នុងន័យពេលវេលាដែលពិធីអាពាហ៍ពិពាហ៍ត្រូវបានកើតឡើងដោយការរៀបចំ ។ សហគមន៍ខ្លះប្រារព្ធពិធីមង្គលការមួយថ្ងៃ ខ្លះទៀតធ្វើឡើងលើសពី៧ថ្ងៃ ។ វាមានការខុសប្លែកយ៉ាងខ្លាំង រវាងពិធីអាពាហ៍ពិពាហ៍នីមួយៗ ។

យោងតាមបទពិសោធន៍បកស្រាយប្រាប់អ្នកស្រី ដេច ឡឺវ៉ាញ អ្នកស្រីបានថ្លែងថា គាត់បានធ្វើសេចក្តីសន្និដ្ឋានថា ពួកគេមិនត្រូវបានបង្ខំឡើយដោយសារតែមានការស្នើសុំ និងពេលខ្លះបានស្នើដល់សាច់ញាតិដែលបានទៅជួបមេកង ។ «ជាធម្មតាពួកគេស្ថិតក្នុងការព្រមព្រៀងគ្នា» ។

បើតាមអ្នកបកប្រែផ្ទាល់មាត់របស់គាត់ អ្នកស្រីបាននិយាយថា អ្នកស្រី ឡឺវ៉ាញ មានអ្នកបកប្រែឯករាជ្យមួយ ។ អ្នកបកប្រែឲ្យអ្នកស្រីដំបូងគេ គឺជាអ្នកដែលនៅរស់រានមានជីវិត នេះគឺជាហេតុផលដែលអ្នកស្រីមានអ្នកបកប្រែមួយទៀតដែលមិនមានទីលំនៅនៅក្នុងទីជនបទ ។ អ្នកបកប្រែទី២បានបកប្រែដោយមិនបានអានប្រតិចារឹកដំបូងរបស់អ្នកបកប្រែមុនឡើយ ។ អ្នកស្រីបានរកសិស្សពីសកលវិទ្យាល័យភូមិន្ទភ្នំពេញមកជួយអ្នកស្រី ។ ពួកគេមិនមែនជាសិស្សរបស់អ្នកស្រីឡើយតែជាអ្នកស្ម័គ្រចិត្ត ។ អ្នកស្រីបានបង្ហាត់បង្រៀនពួកគេពីការសាកសួរឲ្យបានល្អិតល្អន់លើបញ្ហាជាក់ស្តែងជាច្រើនទៀត តែមិនបានបង្ហាត់ពីការធ្វើបទសម្ភាសន៍ និងបន្ថែមសំណួរនោះទេ ។ អ្នកស្រីបានប្រមូលគំរូព្រាងនៃគំរូទាំង១០២ ដែលសិស្សរបស់គាត់បានប្រមូលដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយការងាររបស់គាត់ ។ មានសិស្សប្រមាណជាមួយភាគបីប៉ុណ្ណោះដែលបានរក្សាការសម្ភាសន៍ទាំងនោះ ។

ត្រង់ចំណុចនេះ លោកប្រធានបានប្រកាសផ្អាកការស្តាប់ដើម្បីសម្រាក ។

## ការរួមដំណេកក្រោយរៀបការ

អ្នកស្រី ដេច ឡឺវ៉ាញ បានចាប់ផ្តើមសម្ភាសប្តីប្រពន្ធចំនួន១១គូ ។ ក្រោយមក អ្នកស្រីបានសម្ភាសប្តីប្រពន្ធចំនួន៩០គូ ។ ទាំង៩០គូបូករួមទាំង១១គូហើយសិស្សរបស់គាត់បានសម្ភាសបន្ថែម ១០២គូ ដូច្នេះសរុបទៅគឺមាន១៩២គូ ។ គំរូប្តីប្រពន្ធដែលគាត់យកបានភាគច្រើនគឺរៀបការនៅខេត្តកណ្តាល ។ ក្រោយពីរយៈពេលដំបូងដែលខ្មែរក្រហមបានកាន់អំណាច ពិធីរៀបការគឺត្រូវបានធ្វើឡើងដោយភាពខុសប្លែក ។ អ្នកស្រីបាននិយាយថា មានពិធីការខុសគ្នាចំនួន២ដែលយើងអាចធ្វើការស្រាវជ្រាវក្នុងនរវិទ្យា អេមិក ដែលក្រឡេកមើលសង្គមឬវប្បធម៌ពីផ្នែកខាងក្នុង និង អេទិក ដែលយើងវិនិច្ឆ័យពីផ្នែកខាងក្រៅ ។ អ្នកស្រីបានបកស្រាយថា អ្នកស្រីប្រហែលជាត្រូវប្រកាន់ជំហប្រកបដោយក្តីស្រឡាញ់ឬអ្វីក៏ដោយដែលអាចបង្កើតភាពជាដៃគូបាន និងជំនួសការស្តាប់ក្នុងនាមជាអ្នកសម្ភាស ។ អ្នកស្រីបាននិយាយថា វត្ត

មានរបស់ប្តីប្រពន្ធ គឺជាការបង្ហាញនូវសមានចិត្តដ៏ល្អដែលមិនអាចកាត់ថ្លៃបាន ។ ប្រជាជនបានបង្កើតចំណងមិត្តភាពជាមួយគ្នាតាមរយៈបទពិសោធន៍នៃការរកឃើញក្រុមគ្រួសារទាំងអស់គ្នា និងអាចប៉ះពាល់គ្នាបានដោយមិនប្រកាន់ ។ «ពួកគេមិនដែលនៅក្នុងគំរូរបស់ខ្ញុំ មិនដែលមាននរណាម្នាក់និយាយថា ខ្ញុំមិនដែលស្រឡាញ់មនុស្សម្នាក់នោះ ដូច្នេះខ្ញុំត្រូវបានបង្ខំឲ្យរៀបការឡើយ» ។

«ក្នុងប្រពៃណី មានពេលភ្ជាប់ពាក្យ ដែលពេលខ្លះយើងហៅថាចន្លោះពាក់កណ្តាល ។ ក្រោយពេលភ្ជាប់ពាក្យ អាពាហ៍ពិពាហ៍ត្រូវបានចាប់ផ្តើម» ។ បើតាមប្រពៃណី គេច្រើនធ្វើឡើងក្រៅពីរដូវវស្សា ។ អ្នកស្រីបានបកស្រាយថា ក្នុងករណីខ្លះមេកងអនុញ្ញាតឲ្យគូណា ដែលបានភ្ជាប់ពាក្យហើយរៀបការជាមួយគ្នា ។ លោកស្រី កាហ្សុមី ណាកាហ្គាវ៉ា បានផ្តោតតែលើស្រ្តី ដូច្នេះការស្រាវជ្រាវនោះមានភាពលម្អៀងផ្នែកយ៉េនឌ័រ ដែលផ្ទុយពីវិធីសាស្រ្តរបស់អ្នកស្រី ដេច ឡឺវ៉ាញ ។

លោកស្រីមេធាវី អានតា ហ្គីសេ្ស បានចោទសួរការរៀបការមានប៉ុន្មានបែបកាលពីរបបខ្មែរក្រហម ។ អ្នកស្រីបានឆ្លើយថា បើផ្អែកលើពេលវេលា និងទីកន្លែង វាប្រហែលជាមាន៧របៀប ។ អ្នកស្រីមានបំណងចង់ប្រមូលភ័ស្តុតាងឲ្យបានច្រើនតាមដែលអាចធ្វើទៅបានតាមរយៈកម្រងសំណួរ ។

បើតាមការស្រាវជ្រាវរបស់អ្នកស្រីផ្អែកលើមេកង អ្នកស្រីបាននិយាយថា អ្នកស្រីមិនបានធ្វើការស្រាវជ្រាវលីបលដូចជាការដេញចាប់មេធ្មប់នោះទេ ។ អ្នកស្រីត្រូវបានស្នើឲ្យផ្តល់ឈ្មោះមេកងមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យទាន់ពេល ប៉ុន្តែអ្នកស្រីបានប្រកែក ។ អ្នកស្រីមិនចង់ចូលរួមក្នុងការផ្តល់ឈ្មោះចារី ។

បន្ទាប់មក លោកស្រីមេធាវី ហ្គីសេ្ស បានសួរពីការរួមសង្វាស និងបានអានការដកស្រង់មួយឃ្លាត្រង់ចំនុចដែលលោកស្រីបាននិយាយថា មានប្រជាជនប្រមាណជា៤០ភាគរយបានបង្ខាប់ឲ្យមានការរួមសង្វាស ។ លោកស្រីបានបកស្រាយថា មានក្រៅពីប្រជាជន៣៩.៩ ភាគរយ មាន ០.០៩ ភាគរយត្រូវបានរាយការណ៍ថា មានការចូលដៃចូលជើងក្នុងបញ្ហានេះ ។ ពាក់កណ្តាលនៃពួកគេបានស្គាល់គ្នាពីមុនមក ។ ពួកគេមួយចំនួនបាននិយាយពីសកម្មភាពផ្លូវភេទ ឧទាហរណ៍តាមរយៈការសួរនាំគ្នាពីសមត្ថភាពនៃការបង្កកំណើត ។ អ្នកស្រីក៏បាននិយាយដែរថា នៅប៉ៃកលោកខាងលិច «ក្រោយពីការរៀបការ គឺត្រូវតែមានការរួមដំណេក» ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកស្រីបានចង្អុលបង្ហាញថា ការរួមដំណេកក្រោមរបបខ្មែរក្រហមគឺគ្មានន័យអ្វីឡើយ ។ គ្មាននរណាម្នាក់ក្នុងគំរូរបស់ខ្ញុំបាននិយាយថា នាថ្ងៃបន្ទាប់ពួកគេត្រូវបានសួរនោះឡើយ ហើយក៏គ្មាននរណាម្នាក់ត្រូវបានគំរាមកំហែងដល់ជីវិតប្រសិនបើពួកគេមិនរួមដំណេកដែរ ។

ប្រជាជនភាគច្រើនបាននិយាយការរួមដំណេកត្រូវតែមាន ។ ហើយពួកគេអាចនឹងមានកូនសម្រាប់ឪពុកម្តាយពួកគេ ។ ក្នុងវិហាររ៉ូម៉ាំងកាតូលិក អ្នកស្រីបាននិយាយថា បើគ្មានការរួមដំណេកក្នុងមួយឆ្នាំដំបូងទេនោះ ការរៀបការនឹងត្រូវចាត់ទុកជាមោឃៈ ។ ជាប្រពៃណី គេរំពឹងទុកថាប្តីប្រពន្ធនឹងត្រូវធ្វើការរួមដំណេកក្នុងអំឡុងពេល៣ថ្ងៃ ។

ក្នុងចំណោមប្រជាជនដែលបានរៀបការ ០.៨ភាគរយបានទៅខ្ទមផ្សំដំណេកដែលមាននៅទីនោះ ។ ប្រសិនបើប្រជាជនអាចទៅផ្ទះម្តាយឪពុកពួកគេបាន ពួកគេនឹងទៅ ។ ប្រជាជនដែលបានទៅខ្ទមផ្សំដំណេកគឺសុទ្ធសឹងតែជាអ្នកគ្មានក្រុមគ្រួសារ ។ ដោយសារតែមានការផ្លាស់ប្តូរនៃការរៀបអាពាហ៍ពិពាហ៍ និងក្រោយមកមានផ្លាស់ប្តូរការរំពឹងទុក អ្នកស្រី បានសួរថា តើអ្វីទៅគឺជាគោលបំណងនៅពីក្រោយរឿងនោះ? វាជាការកែប្រែសារជាថ្មីនៃរបៀបដែលការរៀបការគួរតែធ្វើឡើងឬយ៉ាងណា? ខ្ញុំមិនច្បាស់ទេ ។

អ្នកស្រីបាននិយាយថា កាលណាប្រព័ន្ធការរស់នៅថ្នាក់ឃុំបង្កើតកាន់តែច្រើន ពេលនោះខ្ទមជាច្រើនក៏ត្រូវបានសាងសង់ផងដែរក្នុងតំបន់នោះ ។ អ្នកស្រីបាននិយាយថា អ្វីដែលគាត់បាននិយាយគឺបានរំលេចចេញសំណួរដែលសួរថា តើខ្ទមទាំងនោះគឺជាផ្នែកមួយថ្មីមួយនៃការរស់នៅជាប់ឃុំដែរឬទេ ។

លោកប្រធានបានផ្អាកការស្តាប់ ។ សវនាការនឹងបន្តនៅថ្ងៃស្អែក នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ នាវេលាម៉ោង៩ ព្រឹកជាមួយសក្ខីកម្មរបស់អ្នកស្រី ឡឺវ៉ាញ ។

**អាលីស មើហ្គើរ**

# ទស្សនៈប្រជាជនចំពោះការប្រកាសសាលដីកាស្ថាពររបស់តុលាការកំពូលទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង ខៀវ សំផន

កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤កន្លងទៅ នៅក្នុងសំណុំរឿង០០២ វគ្គ០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានសម្រេចកាត់ទោសជនជាប់ចោទទាំងពីរឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ជនជាប់ចោទទាំងពីរបានប្តឹងសារទុក្ខទៅតុលាការកំពូលសុំឲ្យមោឃភាពសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងសម្រេចឲ្យរួចខ្លួនពីបទចោទទាំងអស់ ។

យើងអាចចាត់ទុកថា ថ្ងៃពុធ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នេះ ជាថ្ងៃប្រវត្តិសាស្ត្រមួយ ដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកាសម្រេចចុងក្រោយ ចំពោះបណ្តឹងសារទុក្ខរបស់ជនជាប់ចោទទាំងពីរ ។ តុលាការកំពូលបានសម្រេចថា "តុលាការកំពូលសម្រេចតម្កល់ទោសអស់មួយជីវិតរបស់ជនជាប់ចោទទាំងពីរ ដែលសម្រេចដោយតុលាការដំបូង ហើយជាមួយគ្នានេះតុលាការកំពូលក៏បានច្រានចោលការចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីរក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ និងសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទីបីដែលស្នើដោយសហព្រះរាជអាជ្ញា" ។ ក្នុងថ្ងៃប្រកាសនេះដែរ ក៏មានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់អ្នកសារព័ត៌មានជាតិ អន្តរជាតិ អង្គភាពផ្សេងៗ និងជាពិសេសសាធារណជនដែលមកពីតាមបណ្តាខេត្ត រាជធានីទៀតផង ។ ខាងក្រោមនេះ ជាទស្សនៈផ្ទាល់របស់អ្នកដែលបានមកចូលរួមស្តាប់ការប្រកាសសាលដីកាចុងក្រោយរបស់តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖

◆ កុក ឆាង ៖ មកពីស្រុកកណ្តៀង ខេត្តពោធិ៍សាត់ យល់ស្របនឹងការកាត់សេចក្តីរបស់តុលាការកំពូលនៅពេលនេះ ព្រោះការដាក់ឲ្យជាប់ពន្ធនាគារអស់មួយជីវិតនេះ គឺសមស្របនឹងទង្វើដែលមេដឹកនាំទាំងពីរបានប្រព្រឹត្ត ។ គាត់រីករាយនឹងសាលដីកានេះ ព្រោះគាត់ក៏ជាជនរងគ្រោះម្នាក់ក្នុងរបបខ្មែរក្រហមដែរ ។


សាធារណជនកំពុងរង់ចាំស្តាប់ការប្រកាសសាលក្រមស្ថាពរសំណុំរឿង០០២ វគ្គ១ ទាក់ទងជនជាប់ចោទ នួន ជា និង ខៀវ សំផន

◆ ម៉ាន ម៉ាយ៉ា ៖ ជនជាតិខ្មែរអ៊ីស្លាម មកពីខេត្តកំពង់ឆ្នាំង យល់ថា ការដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតនេះ គឺត្រឹមត្រូវ និងយុត្តិធម៌ ព្រោះវាបានផ្តល់នូវយុត្តិធម៌ដល់អ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងអ្នករួចរស់ជីវិតឲ្យបានស្ងប់ចិត្ត ។ គាត់សង្ឃឹមថា នឹងមិនមានរបបនេះ កើតឡើងទៀតទេ ។

◆ កោះ កើង ៖ មកពីខេត្តពោធិ៍សាត់ បានឲ្យដឹងថា មេដឹកនាំទាំងពីរគួរតែទទួលទោសបែបនេះ ព្រោះឲ្យសមនឹងទង្វើដែលជនជាប់ចោទទាំងពីរបានប្រព្រឹត្ត ។

◆ ទុំ បេះ ៖ មកពីខេត្តកំពង់ឆ្នាំង បានយល់ថា យុត្តិធម៌ពិតជាមាន ហើយក៏សង្ឃឹមថា មេដឹកនាំជំនាន់ក្រោយនឹងមិនយកគំរូតាមនោះទេ ។

◆ ពូ ម៉ៅ ៖ មកពីស្រុកកណ្តៀង ខេត្តពោធិ៍សាត់ យល់ថា ការដាក់ទោសនេះ គឺមានភាពត្រឹមត្រូវ និងយុត្តិធម៌សម្រាប់គាត់ ហើយក្នុងនាមគាត់ជាជនរងគ្រោះនៃរបបខ្មែរក្រហមម្នាក់ ក៏ធូរស្បើយក្នុងចិត្តដែរ ។

◆ ព្រះតេជគុណ សុជាតិ ៖ គង់នៅវត្តឥណ្ឌញាណវង្ស៊ី ក្រុងភ្នំពេញ មានសង្ឃដីកាថា ការសម្រេចរបស់តុលាការនៅពេលនេះ គឺមានភាពសមស្រប និងអាចធ្វើឲ្យប្រជាពលរដ្ឋមានការស្ងប់ចិត្ត ។

◆ សក់ ៖ មកពីខេត្តពោធិ៍សាត់ បានឲ្យដឹងថា គាត់រីករាយនៅពេលដែលដឹងថាតុលាការសម្រេចតម្កល់ទោសមេដឹកនាំទាំងពីរឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ពេលនេះគាត់បានយុត្តិធម៌មួយពិតប្រាកដហើយ ។

◆ លោកយាយ មាន ៖ ជាដូនជី មកពីខេត្តព្រៃវែង បានផ្តល់ជាទស្សនៈថា ការប្រកាសសាលដីការបស់តុលាការកំពូលនេះ គឺមានភាពយុត្តិធម៌ ។ តុលាការបានស្វែងរក និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមពិតប្រាកដ ។ ពេលនេះ លោកយាយមានអារម្មណ៍ត្រេកអរ និងធូរស្រាលក្នុងចិត្តហើយ ។

◆ វៃ ស្មឹម ៖ ជនជាតិខ្មែរអ៊ីស្លាម មកពីខេត្តកំពង់ឆ្នាំង ឲ្យដឹងថា នៅក្នុងរបបនោះ ស្មឹម បានបាត់បង់យាយម្នាក់ ។ ទោះបីជាស្មឹម កើតមិនទាន់របបខ្មែរក្រហម ប៉ុន្តែស្មឹម យល់ថា តុលាការមានភាពយុត្តិធម៌ក្នុងការកាត់ទោសជនជាប់ចោទទាំងពីរ ។

សំណុំរឿង ០០២ វគ្គ១ ចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបើកក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ។ សំណុំរឿងនេះចោទប្រកាន់អំពី "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជនដំណាក់កាលទី២ ដែលត្រូវបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៧ ព្រមទាំងការសម្លាប់រង្គាលលើអតីតទាហាន និងមន្ត្រីរដ្ឋការរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ។

សវនាការលើភ័ស្តុតាងនៃសំណុំរឿង០០២ វគ្គ០១ បានប្រព្រឹត្តទៅអស់រយៈពេល២០ខែ ហើយក្នុងនោះដែរ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សាក្សីកម្មរបស់បុគ្គលចំនួន៩២នាក់ ដែលរួមមាន អ្នកជំនាញ៣នាក់ សាក្សីអង្គហេតុ៥៣នាក់ សាក្សីអត្តចរិត៥នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី៣១នាក់ ។ ឯកសារភ័ស្តុតាងជាង៥.៨០០ឯកសារ ត្រូវបានយកមកពិនិត្យដេញដោល និងទទួលយកដាក់បញ្ចូលក្នុងសំណុំរឿង ដែលសរុបមានឯកសារទាំងបីភាសា (ខ្មែរ-បារាំង-អង់គ្លេស) ជាដូរការមានចំនួនជាង ២២២.០០០ទំព័រ ។ អង្គជំនុំជម្រះក៏បានទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១.១២៤ ជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់ ។ សវនាការលើភ័ស្តុតាងនេះបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ និងសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលត្រូវបានធ្វើឡើងនៅខែតុលា ឆ្នាំ២០១៣ ។ **ធាត សារៈមុនិន្ទ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ការផ្លាស់ប្តូរបរិស្ថាន និងសង្គមក្នុងអន្លង់វែង

ដំណើរទស្សនកិច្ចសន្តិភាពអន្លង់វែងនា ដែលបានរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាចំណែកមួយនៃសកម្មភាពជុំវិញការបង្កើតឡើងនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានផ្តោតទៅលើការផ្លាស់ប្តូរបរិស្ថាន និងសង្គមក្នុងតំបន់ ។

និស្សិតចំនួនដប់ពីររូបមកពីសកលវិទ្យាល័យភ្នំពេញ បានចូលរួមក្នុងដំណើរទស្សនកិច្ចលើកទី៨ ដែលផ្តោតសំខាន់លើការលើកកម្ពស់ផ្នែកយល់ដឹងឲ្យកាន់តែទូលំទូលាយ អំពីភាពខុសប្លែកក្នុងសហគមន៍អន្លង់វែង ដែលធ្លាប់ជាអតីតតំបន់ស្ថិតក្រោមការគ្រប់គ្រងពីសំណាក់យោធាខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៨ ។ ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងទេសចរណ៍ និងក្រោមការឧបត្ថម្ភពីម្ចាស់ជំនួយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអភិវឌ្ឍ និងអភិរក្សទីតាំងប្រវត្តិសាស្ត្រទាំង១៤កន្លែងក្នុងតំបន់ និងបាននាំនិស្សិតធ្វើទស្សនកិច្ចនៅអន្លង់វែង តាមរយៈដំណើរទស្សនកិច្ចសន្តិភាព ។

ក្រៅពីធ្វើបទបង្ហាញស្តីពីប្រវត្តិសាស្ត្រ និងកេរមរតកដែលបន្សល់ទុកពីចលនាខ្មែរក្រហម ក្នុងប្រទេសកម្ពុជាដោយផ្តោតជាពិសេសទៅលើវត្តមានចុងក្រោយបង្អស់របស់ខ្មែរក្រហមក្នុងអន្លង់វែង លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញទាក់ទងនឹងការកសាងសន្តិភាព អំពើហិង្សា ភាពអយុត្តិធម៌ និងបានផ្តល់វិធីសាស្ត្រនៃការធ្វើបទសម្ភាសដល់និស្សិត ។ ក្នុងអំឡុងពេលដែលនិស្សិតទទួលបានការបណ្តុះបណ្តាលពីវិធីសាស្ត្រដើម្បីសាកសួរព័ត៌មានទូទៅអំពីប្រវត្តិរបស់អ្នកផ្តល់បទសម្ភាស និងតួនាទីរបស់ប្រជាជនទាំងនោះក្នុងរបបខ្មែរក្រហម ។ និស្សិតដែលចូលរួមត្រូវបានប្រាប់ឲ្យផ្តោតចំណាប់អារម្មណ៍ជាពិសេសទៅលើការផ្លាស់ប្តូរបរិស្ថាន ក៏ដូចជាសង្គមក្នុងជីវភាពរស់នៅនៃសហគមន៍អន្លង់វែង ។

ថ្ងៃដំបូង និស្សិតខ្លះបានរម្លឹកថា តំបន់នោះធ្លាប់មានភាពល្បីរន្ទឺដោយសារតែភាពសម្បូរនៃព្រៃឈើ ប៉ុន្តែនិស្សិតទាំងនេះបាន


វាគ្មិននិយាយពីបទពិសោធផ្ទាល់ខ្លួនអំឡុងពេលសង្គ្រាមស៊ីវិល ពីឆ្នាំ១៩៧៩-១៩៩៨

ជួបប្រទះបញ្ហាប្រឈមពេលទៅដល់ទីតាំង ដោយសារតែឃើញមានដើមឈើតែប៉ុន្មានដើមប៉ុណ្ណោះ ក្នុងចន្លោះតំបន់ដែលត្រូវបានគេឈូសឆាយ ។ ដោយធ្លាប់មានកិត្តិនាមថា ជាតំបន់ដែលដីមានដីជាតិ ព្រៃស្តុក និងជាតំបន់ដែលការកាន់កាប់ដីមានភាពងាយស្រួល សហគមន៍អន្លង់វែងកំពុងតែរងការគំរាមកំហែងពីការកាប់ព្រៃឈើ និងការរឹបអូសដីធ្លីឥតស្រាកស្រាន្ត ។ ម្យ៉ាងទៀត និស្សិតក៏មានការភ្ញាក់ផ្អើលដែលបានដឹងអំពីគម្រោងសាងសង់នានាដែលត្រូវបានរៀបចំឡើងដោយ តាម៉ុក អតីតមេបញ្ជាការខ្មែរក្រហម ។ «មុនពេលខ្ញុំមកកាន់ទីនេះ ខ្ញុំគិតថា ខ្មែរក្រហមបានបំផ្លិចបំផ្លាញគ្រប់យ៉ាងគ្មានសេសសល់ ។ ក្រោយពីយើងបានធ្វើទស្សនកិច្ចទៅកាន់សាលា និងមន្ទីរពេទ្យដែល តាម៉ុក បានសាងសង់សម្រាប់សហគមន៍មួយនេះ ខ្ញុំគិតថា អ្វីដែលខ្មែរក្រហមធ្វើគឺមិនមែនសុទ្ធតែអាក្រក់ទាំងអស់ឡើយ» ។

ការពិពណ៌នាដែលមានភាពផ្ទុយស្រឡះ និងភាពខុសប្លែកគ្នាទាំងស្រុងអំពីជីវិតរស់នៅក្រោមរបបខ្មែរក្រហមដោយអ្នករស់រានមានជីវិតនាថ្ងៃបន្ទាប់ បានធ្វើឲ្យរឿងរ៉ាវកាន់តែមានភាពស្មុគស្មាញ ។ អតីតកម្មាភិបាលខ្មែរម្នាក់បានមានប្រសាសន៍ថា ជីវភាពរស់នៅរបស់អ្នកស្រីក្រោមរបបខ្មែរក្រហម គឺពិតជាមានភាពល្អប្រសើរ ហើយក៏គ្មានការរើសអើងក្នុងចំណោមប្រជាជន ។ អ្នកស្រីក៏មិនជឿថា មានការកាប់សម្លាប់ដែរ ប៉ុន្តែមានអ្នកផ្តល់បទសម្ភាសខ្លះបានយំ នៅពេលដែលគាត់រម្លឹកពីភាពអត់ឃ្លាន អំពើហិង្សា និងភាពតក់ស្លុតទាំងឡាយដែលរបបនេះបានធ្វើមកលើប្រជាជនទាំងមូល ។ ភាពចម្រុះនៃការយល់ឃើញបែបនេះ ពេលខ្លះបានធ្វើឲ្យមានការភាន់ច្រឡំដល់និស្សិត ដែលបានចូលរួមដំណើរទស្សនកិច្ចនេះ ដោយសារគេបានយល់ថា ដំណើរនេះជាឱកាសក្នុងការទទួលយកព័ត៌មាន «ពិត» និង «ត្រឹមត្រូវ» អំពីជីវិតក្រោមរបបខ្មែរក្រហម ។

គោលដៅនៃដំណើរទស្សនកិច្ចសន្តិភាពសម្រាប់និស្សិត គឺការប្រឈមជាមួយបុរេវិនិច្ឆ័យ និងការប្រឈមជាមួយនឹងការពណ៌នាដ៏ច្រើនលើសលុបដែលពួកគេអាចនឹងជួបប្រទះក្នុងអំឡុងពេលទស្សនកិច្ច ។ ជាឧទាហរណ៍និស្សិតម្នាក់បានធ្វើការដកស្រង់សម្តីពីគម្រោងសាងសង់របស់ខ្មែរក្រហមពន្យល់ប្រាប់ខ្ញុំក្រោយពីបានសម្ភាសជាមួយអ្នកភូមិអន្លង់វែងថា ៖ «ឥឡូវខ្ញុំវង្វេងអស់ហើយ» ខ្ញុំមកទីនេះដើម្បីស្វែងយល់ថា អ្នកណាជាខ្មែរក្រហមពិតប្រាកដ ហើយពេលនេះមានមនុស្សពីរនាក់និយាយយ៉ាងនេះ ពីរនាក់ផ្សេងទៀតនិយាយយ៉ាងនោះ ។ តើអ្វីទៅជារឿងពិត? ។

ដោយសារតែ មាននរណាម្នាក់ត្រូវតែទទួលខុសត្រូវក្នុងការកើតឡើងនៃចលនាខ្មែរក្រហមដែលចលនានេះនៅមានសកម្មភាពក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៩ និងបានបន្តជម្លោះប្រដាប់អាវុធអស់រយៈពេល២០ឆ្នាំទៀតដូច្នេះការទទួលខុសត្រូវអាចនឹងមានការផ្លាស់ប្តូរស្របទៅតាមពេលវេលា ឬប្រហែលជាមានភាពចម្រុះ ។ លោកបណ្ឌិត សុខឃាង បានពន្យល់ថា ដោយសារតែភាពបរាជ័យនៃរបបកម្ពុជាប្រជាធិបតេយ្យដែលផ្តួលរំលំដោយកងទ័ពវៀតណាម ក្នុងឆ្នាំ១៩៧៩ និងពាក្យចចាមអារ៉ាមនៃអំពើសង្គ្រាមរបស់វៀតណាមមកលើប្រជាជនកម្ពុជា ខ្មែរក្រហមបានបង្កើតឲ្យមានការគាំទ្រពីប្រជាជនក្នុងប៉ែកពាយ័ព្យនៃប្រទេសកម្ពុជា ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ដ៏ស្មោះស្ម័គ្រទាំងនោះ ។ ចំណុចនេះក៏បានធ្វើការបញ្ជាក់ក្នុងសក្ខីកម្ម


មាស សុគារ និងអ្នកភូមិ

របស់អតីតកម្មាភិបាលខ្មែរក្រហមពីររូប ដែលបានចូលរួមបដិវត្តន៍ក្នុងឆ្នាំ១៩៨៣ និងឆ្នាំ១៩៨៦ ។ អ្នកទាំងពីរ បានបង្ហាញថា ខ្មែរក្រហមអាចបន្តធ្វើការជ្រើសតាំងកម្លាំងថ្មីៗដើម្បីបម្រើការក្នុងបុព្វហេតុផ្ទាល់ខ្លួន ក្នុងចន្លោះទសវត្សរ៍៨០ ។ លោក នីង ណម អាយុ ៥០ឆ្នាំ បានចូលរួមក្នុងកងកម្លាំងប្រដាប់អាវុធរបស់កងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៨៦ ។ បើទោះបីជាកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ គឺជាហត្ថលេខីនៃសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ១៩៩១ក្ដី ក៏ខ្មែរក្រហមបានសម្រេចចិត្តមិនចូលរួមក្នុងការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់ កាលពីឆ្នាំ១៩៩៣ដែរ និងបានបន្តសកម្មភាពរហូតដល់ចលនាខ្លួនបានដួលរលំ ហើយយោធាខ្មែរក្រហមក៏បានធ្វើសមាហរណកម្មជាមួយកងយោធពលខេមរភូមិន្ទ ។ លោក ណម បានចេញពីកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យមុនសមាហរណកម្មទៅទៀត ។ លោកបាននិយាយថា "ខ្ញុំសប្បាយចិត្តជាខ្លាំងចំពោះសន្ធិសញ្ញាក្រុងប៉ារីស ដោយសារថា វាបានបញ្ចប់សង្គ្រាមជាមួយប្រទេសវៀតណាម ហើយខ្ញុំក៏មានភាពនឿយហត់ពីការប្រយុទ្ធគ្នានេះដែរ ។ ខ្ញុំបានចេញពីជួរទ័ពក្នុងឆ្នាំ១៩៩៣" ។

ប៉ុន្តែមានអ្វីកើតឡើងក្នុងអន្លង់វែងក្រោយឆ្នាំ១៩៩៨? កិត្តិសព្ទនៃព្រៃស្ដុក ដីមានជីជាតិ និងការកាន់កាប់ដីមានភាពងាយស្រួល បានទាក់ទាញគ្រួសារជាច្រើនក្នុងប្រទេសកម្ពុជាដើម្បីទៅរស់នៅក្នុងតំបន់នោះ ក្នុងបំណងមានជីវភាពរស់នៅប្រសើរជាងមុន ។ លើកលែងតែសក្ខីកម្មចំនួនពីរដែលត្រូវបានលើកឡើងក្នុងបទបង្ហាញដោយកម្មាភិបាលជាន់ខ្ពស់នៃរបបខ្មែរក្រហម ចំនួនគ្រួសារភាគច្រើនដែលក្រុមនិស្សិតបានធ្វើការសម្ភាសបានផ្លាស់មករស់នៅអន្លង់វែងក្រោយឆ្នាំ២០០០ ។ ប៉ុន្តែបើទោះបីជាមានការលំបាកក្នុងការប្រៀបធៀបតំបន់អន្លង់វែងក្នុងអំឡុងពេលនៃការដឹកនាំរបស់ខ្មែរក្រហម និងក្រោយពេលនោះក្ដី ប្រជាជនអាចផ្ដល់នូវចំណាប់អារម្មណ៍ដ៏គួរឲ្យចាប់អារម្មណ៍មួយចំនួនដែរ ដោយសារប្រជាជនទាំងនេះជាផ្នែកមួយនៃការផ្លាស់ប្ដូរនៃសង្គមក្នុងតំបន់អន្លង់វែង ។

បញ្ហាប្រឈមមួយទៀតក្នុងទឹកដីអន្លង់វែងគឺ ការកាប់ព្រៃឈើ និងការរឹបអូសដីធ្លីជាបន្តបន្ទាប់ ។ អំឡុងពេលប៉ុន្មានឆ្នាំក្រោយសង្គ្រាម មានគ្រួសារជាច្រើនបានមកតាំងទីលំនៅដោយគ្មានបណ្ណកម្មសិទ្ធិបញ្ជាក់ថា ពួកគេជាម្ចាស់ដីឡើយ ។ គ្រួសារមួយដែលយើងបានសម្ភាស មានស្រុកកំណើតនៅខេត្តកំពង់ចាម ប៉ុន្តែបានផ្លាស់ទីលំនៅមករស់នៅក្នុងស្រុកអន្លង់វែងក្នុងឆ្នាំ២០០៥ ក្នុងគោលបំណងចាប់ដី ។ បើទោះបីជាវាមានភាពលំបាកជាងយើងគិតក៏ពិតមែន ប៉ុន្តែប្រជាជនទាំងនេះនៅតែអាចចាប់បានដីដើម្បីដាំដំណាំចិញ្ចឹមគោពីរក្បាល និងមាន់មួយចំនួន ។ គ្រួសារខ្លះទៀតមកពីខេត្តតាកែវ ក៏បានបញ្ជាក់ពីការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់អន្លង់វែងចាប់តាំងពីការមកដល់របស់គាត់ ក្នុងឆ្នាំ២០០២ ។ ប៉ុន្តែសម្រាប់ប្ដីគាត់ នេះគឺជាផ្នែកមួយនៃបញ្ហា "គួរតែដឹងមុនពេលឈានជើងចូលផ្ទះអ្នកណាម្នាក់ដើម្បីធ្វើការសន្ទនា" ការស្វាគមន៍របស់អ្នកភូមិគឺល្អ ។ ប៉ុន្តែឥឡូវគ្រួសារខ្លះ បានលាក់បញ្ហាជាច្រើនម្យ៉ាងយើងមិនបានធ្វើការដោយបើកចំហជាមួយជនប្លែកមុខដូចមុនឡើយ ។ ខ្ញុំបន្ទោសលើបច្ចេកវិទ្យា និងជាពិសេសគឺ ទូរសព្ទទំនើប ពីព្រោះមនុស្សគ្រប់គ្នាកាន់វានៅក្នុងដៃគ្រប់ពេល ។ បើនិយាយពីកត្តាសេដ្ឋកិច្ចវិញ អ្នកភូមិភាគច្រើនរស់នៅដោយពឹងផ្អែកលើកសិកម្មចិញ្ចឹមជីវិតពីព្រោះក្នុងអន្លង់វែងគ្មានផ្សារនោះទេ ។ យោងតាម គ្រីស្ដូ ហ៊ើ ឌៀរីង បានប្រាប់ខ្ញុំក្នុងឱកាសផ្សេងថា អ្នកភូមិអន្លង់វែងបានរង់ចាំនៅច្រកទ្វារព្រំដែនដើម្បីឆ្លងទៅប្រទេសថៃទិញទំនិញឲ្យបានមុនគេ ។



សារ៉ា ហេមមើល អានកាលប្បវត្តិខ្មែរក្រហម

**សារ៉ា ហេមមើល**

# កេរដំណែលដេះដង់សល់ពីរបបខ្មែរក្រហម

**(តពីលេខមុន)**

**២) ផ្តើមបង្កើតសហករណ៍ភូមិ**

ប្រជាជនខ្មែរយើងទូទាំងប្រទេស ត្រូវបានអង្គការជម្លៀសចុះឡើងគ្មានទីបញ្ចប់ គឺឲ្យទៅរស់នៅតំបន់ដាច់ស្រយាល ព្រៃភ្នំក្រំថ្ម ឬតំបន់ដែលមានជំងឺគ្រុនចាញ់ ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនមូលដ្ឋាន (ប្រជាជនចាស់) និងប្រជាជនថ្មី គឺត្រូវបានខ្មែរក្រហមចាប់យកទៅលាបពណ៌ឲ្យមានការស្អប់ខ្ពើមគ្នា និងឈានទៅរកការបែកបាក់សាមគ្គីជាតិខ្មែរទាំងស្រុងៈ

◆ ពណ៌ទី១ គឺប្រជាជនចាស់ បានន័យថាប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧០ ឬឆ្នាំ១៩៧១ រហូតដល់ថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ។

◆ ពណ៌ទី២ ប្រជាជនថ្មី គឺប្រជាជនស្ថិតនៅតំបន់ដែលកាន់កាប់ដោយរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ ។

របបសាធារណរដ្ឋខ្មែរ បានកាន់កាប់ត្រួតត្រាតែរដ្ឋធានីភ្នំពេញ ដែលមានប្រជាជនរស់នៅប្រមាណជា២លាននាក់ និងបណ្តាទីរួមខេត្តនានានៅក្នុងទូទាំងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។ ដូច្នេះសបញ្ជាក់ថា តំបន់រំដោះ ផ្ទៃដីមានវិសាលភាពធំទូលាយខុសគ្នាឆ្ងាយពីតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល លន់ នល់ ។ ទឹកដីនៃខេត្តសៀមរាបយើងនៅក្នុងរបបសាធារណរដ្ឋខ្មែរដែលក្នុងនោះខាងកើតទល់នឹងភូមិត្រាំនាគ, ខាងលិចគឺស្ថិតនៅរណបតាមផ្លូវជាតិលេខ៦ភ្ជាប់ដល់ខេត្តបាត់ដំបង, ខាងជើងត្រឹមសាលាគរុកោសល្យ និងខាងលិចទល់នឹងបឹងទន្លេសាប ។ ស្ថិតក្នុងស្ថានភាពដូចនេះមានគ្រួសារខ្លះរស់នៅបែកគ្នាម្ខាងម្នាក់ គឺនៅតំបន់ពីរប្រកាន់របបដឹកនាំខុសគ្នា ហើយខ្មែរក្រហមចាត់ទុកប្រជាជន ដែលរស់នៅតំបន់ដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ជាសត្រូវ ។ មានយុវជនយុវនារីខ្លះ បានរត់ចូលទៅបន្តការសិក្សានៅខាងតំបន់លន់ នល់ ហើយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏មិនបានឃើញអ្នកទាំងនោះត្រឡប់មកស្រុកកំណើតវិញដែរ ។

ខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនដោយបង្ខំចេញមកពីទីក្រុងភ្នំពេញ និងពីបណ្តាខេត្តនានា និងបានធ្វើឲ្យមនុស្សស្លាប់អស់យ៉ាងច្រើននៅពេលនោះ ។

នៅតំបន់រំដោះ ខ្មែរក្រហមក៏បានធ្វើការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលភូមិ-ឃុំរួចមកហើយដែរ ដូចជាការបង្កើតនូវមន្ទីរសន្តិសុខ ។ ប្រជាជនមួយចំនួនដែលធ្វើការចេញចូលទៅយកទំនិញពីតំបន់ខាងរដ្ឋាភិបាលលន់ នល់ ក៏ត្រូវខ្មែរក្រហមចាប់យកទៅឃុំឃាំងដែរ ។ ក្រុមគ្រួសារយើងរស់នៅបែកគ្នាចំនួន៥ឆ្នាំ ដោយរូបខ្ញុំ និងឪពុក (សៀវ ជុនលី) រស់នៅឯក្រុងសៀមរាប គ្រប់គ្រងដោយទាហាន លន់ នល់ គឺនៅសិក្សារៀនសូត្រ និងបើករោងម៉ាស៊ីនកិនស្រូវ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ហើយពេលនោះប្រជាជននៅតំបន់រំដោះ អាចចូលមកតំបន់ដែលគ្រប់គ្រងដោយលន់ នល់ដែរ ។ ម្តាយខ្ញុំ (ស ជឿន) និងបង លាន ណូ បានមកលេងមួយលើកពីរលើកដែរ ។ នៅតំបន់នានា ដែលកៀកនឹងទាហាន លន់ នល់ ខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនពីតំបន់ទាំងនោះចេញ ។ តំបន់ទាំងនោះរួមមានៈ ភូមិមាត់ខ្លា ស្ថិតនៅក្នុងឃុំអន្លង់សំណរ ស្រុកជីក្រែង និងប្រជាជននៅក្នុងឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ឲ្យឡើងទៅរស់នៅប៉ែកខាងជើងបឹងទន្លេសាប ។ ក្នុងក្រុមគ្រួសារខ្ញុំ បានស្ម័គ្រចិត្តទៅរស់នៅភូមិក្របីរៀល ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ។ ដោយរស់នៅក្បែរផ្ទះបងស្រីបង្កើតម្តាយរបស់ខ្ញុំឈ្មោះ ស លីម ។ នៅទីនោះ ម្តាយរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យបុកស្រូវ ។ ថ្ងៃមួយ គាត់បានបុកស្រូវលើកអង្រែខ្ពស់ក៏ទៅប៉ះនឹងសន្ទឹកបង្អួចធ្វើឲ្យធ្លាក់ចំឆ្អឹងជង្គង់កាំបិតខាងឆ្វេងគាត់ បន្សល់នូវស្លាកស្នាមមកដល់បច្ចុប្បន្ននេះ ។

ក្រោយពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញអស់ពីឃុំកំពង់ឃ្លាំង ក្នុងស្រុកសូទ្រនិគមរួចមក គឺនៅក្នុងឆ្នាំ១៩៧៣ ហើយព្រមទាំងដុតបំផ្លាញផ្ទះរាប់រយខ្នងឲ្យឆេះអស់គ្មានសេសសល់ ។ អ្នកដែលដុតបំផ្លាញផ្ទះប្រជាជននាកាលនោះមានឈ្មោះ

ថា មិត្ត ម៉ាន់ ឪពុកគាត់មានឈ្មោះ ឈាក និងម្តាយឈ្មោះ ថន ធ្លាប់រត់លេងជាមួយខ្ញុំកាលពីនៅក្មេង ពោលគឺមានស្រុកកំណើតជាមួយគ្នា (គាត់បានឈឺស្លាប់នៅឆ្នាំ២០១២) ។ ប្រជាជននៅឃុំកំពង់ឃ្លាំងត្រូវជម្លៀសទៅនៅស្រុកសូទ្រនិគម និងស្រុកជីក្រែង ។ គ្រួសារខ្ញុំបានកត់សម្គាល់ឃើញថា នៅឯភូមិថ្នល់តាសិត ក្នុងទឹកដីឃុំគោកធ្លកក្រោមដដែល គឺស្ថិតនៅតាមដងផ្លូវជាតិលេខ៦ ចម្ងាយ ៧គីឡូម៉ែត្រខាងលិចស្ពាននាគឆ្លងស្ទឹងជីក្រែង ជាភូមិសាស្រ្តមានអំណោយផលល្អពីធម្មជាតិស្រាប់ បង្កឲ្យការរស់នៅមានលក្ខណៈងាយស្រួលជាង ។ ចំណុចលេចធ្លោទាំងនោះរួមមានៈ ដីស្រែបង្កបង្កើនផលមានទំហំធំ ទទួលបានទិន្នផលខ្ពស់ ដោយមានប្រភពទឹកស្រោចស្រពធ្លាក់មកពីទំនប់ម្កាក់ក្នុងឃុំគោកធ្លកលើ និងនៅប៉ែកខាងក្រោមថ្នល់ជាតិ យើងអាចធ្វើការនេសាទត្រីបានទាំងរដូវប្រាំង និងរដូវវស្សា ។ ដោយមើលឃើញនូវលក្ខណៈសម្បត្តិយ៉ាងដូច្នេះ គ្រួសារខ្ញុំក៏ប្តូរទីកន្លែងរស់នៅភូមិថ្នល់តាសិតវិញ ។ គួរបញ្ជាក់ថា ឪពុកមាបង្កើតខ្ញុំម្នាក់ឈ្មោះ សៀវ ជុនឡៃ ព្រមទាំងគ្រួសារបានរស់នៅក្នុងភូមិថ្នល់តាសិតនេះបានយូរមកហើយដែរ ។ ប្រជាជនទាំងអស់ដែលរស់នៅក្នុងភូមិថ្នល់តាសិតនេះ ក្រៅពីប្រជាជនអ្នកមូលដ្ឋានចាស់ ក៏មានអ្នកថ្មីដូចជាពួកខ្ញុំដែរ ។

ប្រជាជនអ្នកចំណូលថ្មីទាំងអស់នៅភូមិថ្នល់តាសិត បានធ្វើការតាំងលំនៅដ្ឋាននៅខាងជើងផ្លូវជាតិលេខ៦ គឺនៅតម្រៀបគ្នាពីកើតទៅលិចប្រមាណជា១៥ផ្ទះ ។ ភូមិសាស្រ្តខាងជើងថ្នល់ជាតិនេះ ដាំដំណាំជាលក្ខណៈសេដ្ឋកិច្ចគ្រួសារ គឺពុំទទួលបានអំណោយផលល្អទេ ព្រោះមានទឹកលិចជាឧបសគ្គ ។ យ៉ាងដូច្នេះហើយ បានជាប្រជាជនមូលដ្ឋានចាស់ ច្រើនរស់នៅខាងក្រោមថ្នល់ជាតិ ព្រោះមានថ្នល់ជាតិធ្វើជាទំនប់ទប់ទឹកមិនឲ្យធ្លាក់មកចូលភូមិបាន ។ ទន្ទឹមគ្នានោះដីស្រែនៅខាងក្រោមថ្នល់ជាតិក៏មានចំនួនតិចដែរ ហើយភាគច្រើនគឺជាស្រែពង្រោះ ។ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំ និងឪពុកខ្ញុំ ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញរយៈពេល២៨ថ្ងៃ ដែលពោរពេញទៅដោយគ្រោះថ្នាក់ បានមកជួបជុំគ្រួសារនៅភូមិថ្នល់តាសិតនាថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៥ ក្រោយពេលបែកគ្នាដោយសង្រ្គាមអស់រយៈពេល៥ឆ្នាំ (១៩៧០-១៩៧៥) កន្លងមក ។ (គួរបញ្ជាក់ឡើយវិញអំពីប្រជាជនអ្នកមករស់នៅថ្មីលើទឹកដីភូមិថ្នល់តាសិតនេះថា ទាំងអស់គ្នាសុទ្ធតែបានទិញដីស្រែនៅក្នុងភូមិនេះដោយមានទាំងរទេះគោ និងអ៊ីៗគ្រប់បែបយ៉ាង ដើម្បីធានាបានក្នុងការផលិតដំណាំស្រូវ ។ ដោយឡែកក្រុមគ្រួសារយើង បានយកម៉ូតូមួយគ្រឿងម៉ាក *Mobylette* ដូរយកដីស្រែបន្ថែមទៀតឲ្យបានដីកាន់តែច្រើនឡើង ។ ក្រៅពីមានដីស្រែសមល្មមហើយនោះ គ្រួសារយើងបានមានរទេះគោមួយគ្រឿង រទេះក្របីមួយគ្រឿង និងកម្លាំងអូសទាញសត្វគោឈ្មោលចំនួនពីរនឹមថែមទៀតផង) ។

ចាប់ពីពេលនោះមក កាលបើយើងផ្តើមភ្ជួរដីដំបូង ចាស់ៗបានឲ្យនង្គ័លខ្ញុំភ្ជួរដីបើកក្បាលងាវមុនគេ (នៅពីមុខគេ) ស្ទើរតែរៀងរាល់លើក ។ នៅរដូវវស្សាឆ្នាំ១៩៧៥ គ្រប់គ្រួសារទាំងអស់បានខិតខំធ្វើស្រែលើដីកម្មសិទ្ធិដែលយើងម្នាក់ៗ យ៉ាងស៊ុតស៊ុញបំផុត គឺពុំចាញ់អ្នកមូលដ្ឋានចាស់ប៉ុន្មានឡើយ ។ ក្នុងគ្រួសារយើងបងប្រុស លានណូ បានធ្វើជាជំហរក្នុងការធ្វើស្រែដូចជាៈ កាប់គាស់គល់ឈើ ភ្ជួររាស់ សាបព្រោះ ដកស្ទូង ដែលជាការងារថ្មីថ្មោងបំផុតសម្រាប់ពួកយើង ។ គ្រួសារយើង ក៏ដូចជាគ្រួសារដទៃៗទៀតដែរ គ្មានអ្នកណាទំនេរម្នាក់ទេគឺខិតខំធ្វើស្រែណាស់ ។ ពេលដែលមានសត្វឈ្លើងទាមជើងឪពុកខ្ញុំ គាត់តែងពោលពាក្យថា ឲ្យទាមតាមចិត្តវាទៅចុះ ដើម្បីបឺតឈាមចង្រៃឲ្យអស់ ។ ឪពុកខ្ញុំ គាត់ចូលចិត្តប្រើបំពង់ប៉ុយជាជាងការប្រើដែកកេះដើម្បីអុចភ្លើងបារី ។ នៅជំនាន់នោះ ថ្នាំជក់ក៏ជាបញ្ហាប្រឈមធំមួយដែរ ពោលគឺមិនខុសគ្នាពីបញ្ហាស្រូវអង្ករប៉ុន្មានឡើយ ហើយភាគច្រើនគេនិយមថ្នាំជក់ណាដែលខ្លាំងមានក្រញាមពណ៌ស ។ រសៀលថ្ងៃមួយ ប្អូនស្រី សៀវ សុវុឌ្ឍា ទំនងជាធុញទ្រាន់នឹងការធ្វើស្រែ បានទៅផ្ទះដើម្បីដាំបបរយកមកឲ្យក្រុមគ្រួសារយើងកំពុងស្ទូងស្រូវបរិភោគ ។ កាលនោះ វុឌ្ឍា ស្ថិតនៅក្នុងវ័យជំទង់ ដើរទៅបានឆ្ងាយបន្តិច ក៏ស្រែកសួរមកកាន់បងស្រី សៀវ សាវត វិញថាៈ បង វត តើកាប់ជួងដាក់ដែរអត់? រំពេចនោះ យើងទាំងអស់គ្នាក៏ផ្ទុះសំណើចឡើង ។ រាល់ពេលដែលខ្ញុំដើរមកពីក្រោយផ្ទះពេលត្រឡប់មកពីស្រែវិញ អង្គុយក្នុងផ្ទះសំយុងជើងទៅលើផ្ទះបាយ ក្មួយប្រុសតូចៗពីរនាក់គឺ គង់ សូណោ និង គង់ សូនិច តែងមកបត់ជើងបេះស្មៅកន្ទើយចេញពីជើងខោខ្ញុំម្នាងម្នាក់ ។ នៅឆ្នាំ១៩៧៥នេះ មធ្យោបាយធ្វើដំណើរដោយជិះកង់

នៅតែជាអាទិភាពនៅឡើយ ហើយខ្ញុំតែងតែជិះកង់ពីភូមិថ្នល់តាសិត ទៅលេងជីតាឈ្មោះ ស គឹមសេង និងម្តាយធំឈ្មោះ ស លឹម នៅភូមិក្របីរៀល ។ ល្ងាចថ្ងៃមួយខ្ញុំជិះកង់ទៅលេងនៅភូមិក្របីរៀល ដូចសព្វមួយដង ហើយបានជួបបុរសម្នាក់ឈ្មោះ ឡៅ ហេង នៅដើមពោធិ៍ក្បែរភូមិក្របីរៀលនោះដែរ ដែលពីដើមមកធ្លាប់រៀនជាមួយគ្នានៅស្រុកកំណើតឯឃុំកំពង់ឃ្លាំង ។ ឪពុករបស់ ឡៅ ហេង ឈ្មោះ ឡៅ តាំង ជាជនជាតិចិន រកស៊ីចាក់គុយទាវលក់នៅលើផ្ទះដែលជាផ្ទះបណ្តែតទឹកនៅមុខវត្តឃ្លាំង ។ កាលនោះខ្ញុំស្លៀកពាក់ខ្មៅ ស្បែកជើងកង់ឡាន លោក ឡៅ ហេង គេស្រែកហៅចំៗឈ្មោះតែម្តង ខ្ញុំស្មានតែគេភ្លេចព្រោះបែកគ្នាយូរឆ្នាំមកហើយ ។ លុះក្រោយមកទើបខ្ញុំយល់បានថា ឈ្មោះ ហេង នេះ កាលជួបដំបូងគេនឹកស្មានថារូបខ្ញុំធ្វើជាខ្មែរក្រហម ដើម្បីបានគេធ្វើការពឹងពាក់ តែក្រោយពីដឹងថា ខ្ញុំជាអ្នក១៧មេសា គេក៏ស្ងប់ឈប់និយាយរក ហើយថែមទាំងលែងមើលមុខខ្ញុំទៀតផង ។

អំឡុងពេលនោះ ជីដូនជីតាយើងរស់នៅបែកគ្នា គឺជីតាយើងគាត់រស់នៅជាមួយកូនស្រីច្បងឈ្មោះ ស លឹម នៅភូមិក្របីរៀល និងជីដូនគាត់រស់នៅជាមួយកូនស្រីពៅឈ្មោះ ស ជឿន នៅភូមិថ្នល់តាសិតមានចម្ងាយពីគ្នា៧គីឡូម៉ែត្រ តែស្ថិតនៅក្នុងឃុំគោកធ្លកក្រោមតែមួយ ។ នៅល្ងាចថ្ងៃមួយ បងប្រុសជីដូនមួយឈ្មោះ ជា សូវេត បានជិះកង់ចេញពីភូមិក្របីរៀលដើម្បីមកលេងនៅភូមិថ្នល់តាសិតដូចរាល់ដង ។ លុះគាត់ជិះកង់ផុតផ្ទះអ្នកភូមិដូនរាជមកដល់ចុងភូមិខាងលិច ស្រាប់តែនៅចំពីមុខ ឃើញមានយោធាខ្មែរក្រហមប្រមាណពី៥ ទៅ៦នាក់ ប្រដាប់ដោយកាំភ្លើងគ្រប់ដៃកាន់ខ្សែដឹកបណ្តើរមនុស្សមួយក្រុមឆ្លងកាត់ថ្នល់ជាតិលេខ៦ ពីជើងទៅត្បូង ។ ឃើញដូច្នោះ បង ជា សូវេត ទុចដំណើរ និងចុះបណ្តើរកង់ចេញឲ្យផុតពីផ្លូវជាតិ ទៅឈរកំបាំងខ្លួននៅក្បែរគល់ឈើទាលមួយដើម លួចមើលសភាពការណ៍នោះបន្តទៅទៀត ។ គាត់ឃើញអ្នកទាំងនោះសុទ្ធតែជាមនុស្សប្រុសប្រមាណ១៥នាក់ ស្លៀកខោខ្លីអត់មានអាវ ចងដៃក្រពាត់ស្លាបសេកទៅក្រោយ ចងក្រណាត់សំពត់បិទភ្នែក និងចងខ្សែតគ្នាពីម្នាក់ទៅម្នាក់ ។ ក្រោយពេលយើងដឹងដំណឹងនេះរួចមក ម្នាក់ៗមានការសង្វេគក្នុងចិត្តជាខ្លាំងនឹកអាណិតដល់អ្នកទាំងនោះណាស់ ។ បង ជា សូវេត ដឹងសុខដឹងទុក្ខរបស់បងប្អូនណាស់ ពេលទៅណាមកណា គាត់តែងចូលលេងផ្ទះយើង នៅពេលខ្លះមានតែមនុស្សស្រី និងកូនៗនៅផ្ទះ គាប់ជួនជាពុំមានទឹកនៅក្នុងពាង គាត់ទាញយកដងរែកទៅរែកទឹកដាក់ពាងឲ្យទៀតផង ។ ពេលនោះ គឺពុំមានចាយប្រាក់ទេ ដូច្នេះយើងធ្វើការដោះដូរសម្ភារឲ្យគ្នាទៅវិញទៅមក ដូចជាថ្នាំពេទ្យ មាស អង្ករ ស្ករអំបិល ថ្នាំជក់ និងខោអាវ ។ នៅក្នុងគ្រួសារយើងមានម្តាយខ្ញុំ និងប្អូនស្រីជាអ្នកដើរដូរម្ហូបអាហារ ។ គ្រួសារយើងតែងបរិភោគបបរខាប់ល្មម តែបើចង់ដាំបាយវិញ គឺត្រូវហាន់ត្រកួន ឬហាន់ដំឡូងមីលាយទើបបាន ព្រោះអង្ករពិបាករកណាស់ ។ ប្រជាជន ១៧មេសា និងអ្នកមូលដ្ឋានចាស់ខ្លះទៀតត្រូវដឹកដំឡូងព្រៃ មើមដឹស និងមើមក្តួចយកមកបរិភោគ ។ លុះទល់ច្រកមែនទែនទៅ គ្រួសារខ្លះហាន់គល់ចេកយកទៅអាំង ឬលីងកន្ទុកបរិភោគក៏មានដែរ ។ ភាពអត់ឃ្លានទាំងនេះ គួបផ្សំនឹងគ្មានអំបិលទៀតនោះ បានធ្វើឲ្យមនុស្សមួយចំនួនហើមខ្លួនដូចសប់ ។ ពូ ពិន ជាប្រជាជនថ្មីម្នាក់មានសម្បុរសណ្តែកបាយ តែងឃើញស្លៀកខោជើងខ្លី រស់នៅចុងខាងកើតភូមិថ្នល់តាសិត មានទឹកមុខស្លេកស្លាំង ខ្យល់បក់មកចំស៊ើររលំដួល ។ ជារៀងរាល់ព្រឹក យើងតែងឃើញគាត់ដើររើសខ្យងក្តាមនៅតាមភ្លឺស្រែ ព្រមទាំងដកដើមប្រាប់ ហើយជួនកាលឃើញគាត់កាន់ដំឡូងមីមួយមើម ដើរទំពាហូបទាំងឆៅទៀតផង ។ ពូពិនពីមុនគាត់រៀនដល់ថ្នាក់ឱប្ចមសាលាបាលី និងក្រោយមកស្រាប់តែបាត់មុខ ពូ ពិន ដោយឮគេថា អង្គការស្នើយកពូ ពិន ទៅបាត់ហើយ ។ ក្រោយពេលទំនេរពីការធ្វើស្រែវស្សាឆ្នាំ១៩៧៥ រួចមក ឪពុកម្តាយខ្ញុំបានជិះកង់ម្នាក់មួយ ទៅរកដោះដូរសេដ្ឋកិច្ច រហូតដល់ភូមិប្រឡាយ ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ។ នៅទីនោះ គាត់ទាំងពីរបានជួបលោកសាស្ត្រាចារ្យ អាំង អេងថ្ងាវ និងប្រពន្ធកូន ព្រមទាំងលោក អាំង វុឌ្ឍោ និស្សិតឆ្នាំទីបីនៃមហាវិទ្យាល័យច្បាប់ ដែលជាប្អូនបង្កើត រស់នៅរួមគ្នាជាមួយផ្ទះអ្នកភូមិម្នាក់ឈ្មោះ ចិន គឹម ។ អ្នកទាំងអស់គ្នាជាប្រជាជនថ្មី និងត្រូវជាប់បងប្អូនជាមួយម្តាយខ្ញុំដែរ ។ គ្រូ អាំង អេងថ្ងាវ អង្គុយរាបបញ្ឈរក្បាលជង្គង់ទៅលើពាក់វែនតាមីញ៉ូប និងយកដៃទាំងពីរច្រតទៅក្រោយដោយពោលពាក្យប្រាប់ទៅម្តាយខ្ញុំថា «ពេលដែលខ្ញុំអង្គុយចុះ ស៊ើរតែទប់ខ្លួនឯងពុំជាប់ ចង់ផ្ងារខ្លួនទៅក្រោយណាបង11? ។ ព្រមទាំងបាន

រៀបរាប់ពីទុក្ខលំបាកប្រចាំថ្ងៃប្រាប់ផង ។ ឮយ៉ាងដូច្នេះ ម្ដាយខ្ញុំបានសុំយកកូនមួយមកចិញ្ចឹមក្នុងការចែករំលែកដើម្បីសម្រាលបន្ទុក ។ តែលោកគ្រូ អាំង អេងថ្ពាវ បដិសេធដោយសុខចិត្តស្លាប់រស់ទាំងអស់គ្នា ។ ក្រោយឆ្នាំ១៩៧៩ គ្រួសាររបស់លោកគ្រូ អាំង អេងថ្ពាវ រួមជាមួយប្អូនប្រុសឈ្មោះ អាំង វុឌ្ឍោ ផង ត្រូវបាត់ខ្លួនទាំងអស់ ។

ល្ងាចមួយ ខ្ញុំត្រឡប់មកពីមើលសន្ទូចនៅក្នុងសន្ទូងក្រោយផ្ទះវិញ ជាប់បានកូនត្រីផ្ទុកជាច្រើនក្បាល ដោតមួយត្រណោតវែងដើរអួសតាមពីក្រោយ ធ្វើឲ្យអ៊ីស្រីឈ្មោះ អុង ផ្ទះនៅខាងលិចជាប់គ្នា ក្អួតចេញតែខ្យល់ឮវិកៗ លុះក្រោយមកទើបខ្ញុំដឹងថា គាត់ខ្ពើមសត្វជន្លេន ដែលយើងបិតធ្វើជានុយបង្កៃត្រី ។ នាល្ងាចថ្ងៃមួយទៀតនោះ ខ្ញុំពីរនាក់បង លាន ណូ បានជិះកង់ឌុបគ្នាទៅរាយមងនៅខាងត្បូងស្ពានរួចមក យើងបានឡើងមកដាំបាយនៅគល់ស្ពានខាងលិចក្រោមដើមឈើធំមួយដើម ។ លុះដល់ពេលទៅមើលត្រីដែលជាប់មងវិញនោះ ស្រាប់តែមានមនុស្សស្រាវលួចយកមងយើងអស់ពាក់កណ្ដាលពីខាងឆ្ងាយនោះមក ព្រោះយប់ងងឹតពេកចាក់ភ្នែកមិនយល់ ។ ពេលកំពុងដាំបាយនៅក្រោមដើមឈើនោះ ខ្ញុំបានជួបលោក ហៀង គឹមហាត ធ្លាប់រៀនជាមួយគ្នានៅក្នុងក្រុងសៀមរាប តែក្រោយឆ្នាំ១៩៧៩ គឺបាត់ឈ្មោះគេសូន្យឈឹងមិនដឹងស្លាប់ឬរស់ ។ មិនយូរប៉ុន្មានមេភូមិថ្នល់តាសិត បានកោះហៅប្រជាជនប្រជុំប្រកាសដាក់ជាទ្រព្យសម្បត្តិរួមទាំងអស់ដែលមាននៅក្នុងភូមិព្រមទាំងប្រកាសថានឹងបង្កើតសហករណ៍នៅក្នុងពេលដ៏ខ្លីខាងមុខ ។ ចំពោះស្រូវពង្រោះយើងចំនួនមួយហិកតា ដែលខ្ញុំពីរនាក់បងលានណូបររទេះទៅដេកភ្ជួរ ព្រោះនៅឯផ្ទះយាយ កៀវ ក្នុងភូមិដីរនួន ម្ដុំវត្តប៉ុច ក្នុងឃុំសង្វើយក៏ត្រូវគេរឹងអូសយកទៅដាក់រួមក្នុងភូមិដីរនួនអស់ដែរ ។ លុះស្រូវយើងនៅក្រោយផ្ទះទុំបានខ្លះហើយនោះ យើងទាំងប្រាំនាក់គឺ ឪពុកយើង រូបខ្ញុំផ្ទាល់ និងប្អូនស្រីខ្ញុំបីនាក់ទៀត ទៅលួចបូតស្រូវខ្លួនឯងដាក់ក្នុងការុងយកមកផ្ទះពេលយប់ៗ ។ ការលួចបូតស្រូវខ្លួនឯងនេះជាទោសឧក្រិដ្ឋ សូម្បីតែឪពុកមាបង្កើត សៀវ ដុនឡៃ ផ្ទះនៅខាងកើតជាប់គ្នាក៏មិនហ៊ានឲ្យគាត់ដឹងផង ព្រោះខ្លាចឮដល់ក្មេងៗ ។ បញ្ហាទាំងនេះ គឺបិទបាំងពុំជិតឡើយ ព្រោះឮអ្នកភូមិនិយាយដ្លែក្លាឲ្យថា ស្រូវនៅខាងជើងថ្នល់ជាតិ មានសត្វសេកហើរមកស៊ីយប់ៗ ព្រោះគួរស្រូវចង្អុលត្រង់ទៅលើមេឃអស់ហើយ ។ ឮយ៉ាងដូច្នេះ ធ្វើឲ្យយើងស្ទាក់ស្ទើរក្នុងចិត្ត តែសម្រេចចិត្តចុងក្រោយ នឹងទៅបូតស្រូវខ្លួនឯងបន្ដតែមួយលើកទៀតប៉ុណ្ណោះ ។ យប់ស្អែកឡើង ពួកយើងទាំងប្រាំនាក់ដដែល បានបន្ដទៅលួចបូតស្រូវខ្លួនឯងទៀត តែនៅលើកនេះ ពេលទៅដល់កន្លែងបូតស្រូវស្រាប់តែប្អូនស្រីខ្ញុំមើលឃើញមនុស្សម្នាក់ដើរលបស្ទុងៗ ក្នុងគុម្ពស្រូវក្បែរនោះ ហើយក៏ខ្សឹបប្រាប់គ្នាឲ្យត្រឡប់ទៅផ្ទះវិញជាបន្ទាន់ ។ ខ្ញុំរហ័សរហួនជាងគេដោយភ្នែកមីញ្ញូបផង ក្រោកដើរចោលថង់ដាក់ស្រូវដែលបូតបានខ្លះហើយនោះ នៅកណ្ដាលស្រែ ព្រោះខ្លាចឈ្លបភូមិវាចាប់បាន ។ ម្រាមដៃយើងម្នាក់ៗរលាត់ដាច់ចេញឈាម នៅតាមថ្នាំងដៃនីមួយៗ ជាពិសេសគឺនៅចង្អុលដៃនាំឲ្យយើងរុំវាគ្រប់ៗគ្នា ។ មើលឃើញយើងស្ថិតក្នុងសភាពដូច្នេះ បងស្រីឈ្មោះ ស៊ិន់ផ្ទះនៅក្បែរបានមានការសង្ស័យក៏សួរនាំយើងរួចសើចព្រមទាំងលើកបង្ហាញនូវចង្អុលដៃរបស់គាត់ក៏មានស្នាមរបួសដែរ បង្ហាញយើងមើល ។ ទីបញ្ចប់ទើបដឹងថា នៅយប់នោះបងស្រីឈ្មោះ ស៊ិន់ ក៏ទៅលួចបូតស្រូវរបស់គាត់ដែរ ដែលមានស្រែនៅជាប់គ្នាជាមួយស្រែយើង ។ ស្រមោលមនុស្សម្នាក់ដែលដើរលបៗនៅក្នុងស្រែនោះ គឺជាស្រមោលបងស្រី ស៊ិន់ ដែលឃើញយើងទៅក៏នឹកស្មានថាជាឈ្លបភូមិ ហើយក៏ដើរលបៗដើម្បីគេចខ្លួនរត់ចេញពីទីនោះ ។ ដូច្នេះបានន័យថា យើងទាំងអស់គ្នាខ្លាចគ្នាទៅវិញទៅមក បង្កើតបានជាអនុស្សាវរីយ៍កំប្លែងសួតមួយនៅខណៈដែលយើងបានជួបគ្នាម្ដងៗ ជំណាលឡើងវិញអំពីរឿងចោរផ្អើលនឹងចោរគ្នាឯង ឬខ្លាចគ្នាទៅវិញទៅមក ដែលមិនអាចបំភ្លេចបានឡើយ ។ ល្ងាចថ្ងៃមួយគេបានហៅយុវជន យុវនារីទាំងអស់ដែលមាននៅក្នុងភូមិមកប្រជុំ ។ ទីស្នាក់ការសង្កាត់គោកធ្លកក្រោមមានទីតាំងនៅក្នុងភូមិថ្នល់តាសិត ខាងត្បូងផ្លូវជាតិលេខ៦ ដែលទើបនឹងសាងសង់រួចថ្មី ហើយអ្នកភូមិនិយមហៅថា ផ្ទះថ្មីដែលមានមិត្ត ភី ជាប្រធានសង្កាត់ និងមិត្ត ពុត ជាអនុប្រធាន ។ ពេលនោះមិត្ត ពុត ជាអ្នកប្រជុំ ដោយអង្គុយនៅលើកៅអីបង់ក្រមា បង្ហុយផ្សែងបារីស្លឹកសង្កែដែលមានតុមួយនៅពីមុខ ហើយក៏ទល់មុខគ្នានឹងអ្នកដែលមកប្រជុំដោយអង្គុយនៅលើកៅអីវែងៗមានតុវែងនៅចំពីមុខផង ។ ក្រោយពីចាត់តាំងប្រធាននារីឈ្មោះ សាគឿន

ជាប្រធានយុវជនភូមិថ្នល់តាសិតរួចមក មិត្តពុត ចាប់ផ្តើមពន្យល់យើងអំពីពាក្យថា “អង្គការ” ។ ខ្មែរក្រហមតែងយកពាក្យអង្គការ ឬអង្គការថ្នាក់លើមកនិយាយជាញឹកញាប់ ។ មិត្តពុត គេនិយាយមួយៗ អាចស្តាប់បាន តែមិនបានក្បោះក្បាយល្អទេ បើផ្អែកតាមបងប្រុសៗ ជា សូវេត ធ្លាប់ស្គាល់មកនោះ មិត្តពុត ដើមឡើយជាកសិកររស់នៅភូមិក្បាលដំរី ក្នុងឃុំពង្រលើ ស្រុកដីក្រហម ។ ក្រោយពេលប្រជុំរួមគ្នាក្នុងភូមិមួយលើកជាពីរលើករួចមក ឃើញមានកម្លាំងមហាជននៅក្នុងភូមិ បានរួមសហការគ្នាសាងសង់ជង្រុកស្រូវរួម និងផ្ទះបាយរួមដែលគេហៅថា សហករណ៍ភូមិ ។ សហករណ៍នេះ ស្ថិតនៅខាងជើងជាប់មាត់ត្រពាំងមួយមានឈ្មោះថា ត្រពាំងក្បាលស្វា ហើយក៏នៅខាងស្តាំដៃផ្ទះយើង ខាងត្បូងថ្នល់ជាតិចម្ងាយពីគ្នាប្រមាណជា១៥០ម៉ែត្រប៉ុណ្ណោះ ។ ប្រធានភូមិកាលនោះមានឈ្មោះថា មិត្ត ភោគ គេអាចហៅថាជាប្រធានសហករណ៍ក៏បានដែរ ហើយសហករណ៍កើតចេញពីពាក្យថា សហកម្ម គឺការរួមគ្នាធ្វើ ។ អង្គការផ្តើមឲ្យយើងធ្វើការងាររួម ដោយឲ្យកម្លាំងនៅតាមបណ្តាក្រុមក្នុងភូមិទៅរែកដីជួសជុលដៃទំនប់ម្កាក់ នៅក្នុងឃុំគោកធ្លកលើ ។ យុវជន យុវនារី ដែលមាននៅក្នុងភូមិទាំងអស់ ត្រូវអង្គការចាត់តាំងឲ្យទៅដាំដំឡូងមីនៅព្រៃតាជា ស្ថិតនៅក្នុងព្រៃខាងលិចភូមិទ័ពសៀម ប្រមាណពីរគីឡូម៉ែត្រ ។ គឺនៅទីនោះហើយ ដែលយើងផ្តើមបរិភោគបាយខ្ទះត្នោតរួមគ្នាជាលើកដំបូង ។ ប្អូនស្រីខ្ញុំពីរនាក់គឺ សៀវ សុវុត្ថា និង សៀវ សុវុឌ្ឍា ក៏មានវត្តមានជាមួយខ្ញុំនៅទីនោះដែរ ។ នៅពេលមួយនោះ សៀវ សុវុឌ្ឍា បានដើរទាត់កន្ទុយអុសដុតបែកផ្កាភ្លើងរងើដល់ខ្ទះត្នោត ធ្វើឲ្យគេងាកមើលគ្រប់គ្នា ។ ចាប់ពីធំដឹងក្តីមក ខ្ញុំពុំដែលមានទម្លាប់ដេកថ្ងៃឡើយ មានថ្ងៃមួយ ពោលគឺក្រោយពេលបាយថ្ងៃត្រង់រួច អង្គុកពេក ខ្ញុំដើរម្នាក់ឯងទៅលេងឆ្ងាយក្បែរប្រឡាយទឹកមួយដែលមានទឹកហូរវិញៗ ហៀរចូលទៅក្នុងដុបព្រៃដោយយកកាំបិតកាប់បានត្រីអណ្តែងជាច្រើនក្បាល យកមកកាន់កន្លែងស្នាក់នៅវិញ ។ ពេលមកដល់ ខ្ញុំបានប្រគល់ត្រីអណ្តែងទាំងនោះទៅឲ្យប្អូនស្រីខ្ញុំអាំង ស្របពេលជាមួយគ្នានោះ ឃើញយុវជនម្នាក់ បុកពារខែងរែង ហើយសំដីរបុិលរប៉ូច យកដៃគេទៅចង្អុលទៅកាន់ត្រីកំពុងអាំងដោយនិយាយថា ត្រីនេះ បើមិនត្រីទ្រូទេឲ្យកោត ។ ពុសំដីនេះ ខ្ញុំមានទោមនស្សក្នុងចិត្តខ្លះដែរ តែធ្វើជាមិនពុត្បិតតែខ្លួនឯងជាប្រជាជនថ្មី ។ ក្រោយមកទើបដឹងថា ម្នាក់នោះមានឈ្មោះ ហុក សៀង ជាអ្នកមូលដ្ឋានចាស់ដែរ តែដើមឡើយឪពុកម្តាយរបស់គេរស់នៅតាមដងស្ទឹងដីក្រហមឯណោះ ។ រដូវប្រូតកាត់បានមកដល់ អង្គការឲ្យយើងទាំងអស់គ្នាត្រឡប់ទៅភូមិវិញ ដើម្បីចូលរួមប្រូតកាត់ បោកបែន យកផលស្រូវដាក់ជង្រុករួម ។ មួយរយៈក្រោយមកទៀត ខ្ញុំបានក្លាយទៅជាមិត្តភក្តិជាមួយលោក តាន់ ហុកសៀង និងឪពុកមាររបស់គេម្នាក់ទៀតឈ្មោះ តាន់ស៊ីងន់ ហៅ ញ កើតនៅឆ្នាំ១៩៥៣ ត្រូវនឹងឆ្នាំមមី អាយុដំណាលគ្នាទាំងបីនាក់ ។ បន្ទាប់មក យើងទាំងបីនាក់បានមានមិត្តរួមគ្នាម្នាក់ទៀតឈ្មោះ សាំង ស៊ាន ជាកូនកាត់ចិន-យួន មកពីភូមិមាត់ខ្លា គេមានអាយុប្អូនពួកយើងមួយឆ្នាំ ។

**(តទៅលេខក្រោយ)**

**សៀវ សុផុន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷


ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










*មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។*

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

*១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។*

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

*១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។*

*ដើម្បីយុត្តិធម៌និងការចងចាំ*
*ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ*


*ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក* (USAID)
*អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩*

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
*ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨*

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 203, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.